ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport


វិទ្យាស្ថានជាតិអប់រំ

National Institute of Education


# និក្ខេបបទ

# ស្ថានភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំនៅ វិទ្យាស្ថានគរុកោសល្យ

## ករណីសិក្សា៖ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងវិទ្យាស្ថានគរុកោសល្យបាត់ដំបង

The Situation of Teacher Training for Bachelor of Education

at Teacher Education Colleges.

Case Study៖ Phnom Penh Teacher Education College and Battambang

Teacher Education College


ដោយ/By

ឆាយ បូនី/Mrs. CHHAY BONY


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៧- ២០១៩


ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា

Supported by Cambodia International Education Support Foundation (CIESF)

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំនៅ
# វិទ្យាស្ថានគរុកោសល្យ
# ករណីសិក្សា៖ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ
# និងវិទ្យាស្ថានគរុកោសល្យបាត់ដំបង

The Situation of Teacher Training for Bachelor of Education at Teacher Education Colleges.

Case Study៖ Phnom Penh Teacher Education College and Battambang Teacher Education College

ដោយ/By

ឆាយ បូនី/Mrs. CHHAY BONY

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៧- ២០១៩

សាស្ត្រាចារ្យដឹកនាំ៖ ឯកឧត្តម ឆៀ សុផន

សាស្ត្រាចារ្យដឹកនាំរង៖ លោក ម៉ន មុនិន្ទ

ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា

Supported by Cambodia International Education Support Foundation ( CIESF )

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៥៧២៩ អយក. ក
(ការសម្ងាត់)

## លិខិតឧទ្ទេសនាម

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត ទូវ រីក | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យូន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក នី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារ៉ុម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត នី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត សិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈូក ច័ន្ទឆាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី ផ្កា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។ 

ថ្ងៃ សុក្រ ១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

**កន្លែងទទួល៖**
-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

# **សេចក្ដីអះអាងរបស់បេក្ខជន**

នាងខ្ញុំសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា «**ស្ថានភាពនៃការបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំនៅវិទ្យាស្ថានគរុកោសល្យ ករណីសិក្សាៈ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងវិទ្យាស្ថានគរុកោសល្យបាត់ដំបង**» សម្រាប់បំពេញ លក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់នាងខ្ញុំទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សា សម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្ដីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាត្រូវបាន ស្រាវជ្រាវនិងចងក្រងដោយនាងខ្ញុំពិតប្រាកដមែន។

ថ្ងៃអង្គារ ១៥កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩

**ហត្ថលេខា**

**ឆាយ មូនី**

# លិខិតបញ្ជាក់

| | |
|---|---|
| ឯកឧត្តម នៀ សុផន | ជាសាស្ត្រាចារ្យដឹកនាំ |
| លោក ម៉ន មុនិន្ទ | ជាសាស្ត្រាចារ្យដឹកនាំរង |

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

លោកស្រី **ឆាយ បូនី** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ «**ស្ថានភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំនៅវិទ្យាស្ថានគរុកោសល្យ**» ពិតប្រាកដមែន។

ថ្ងៃ អង្គារ ១៤កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩

| | |
|---|---|
| ........................................ | ........................................ |
| **ឯកឧត្តម នៀ សុផន** | **លោក ម៉ន មុនិន្ទ** |
| ប្រធាននាយកដ្ឋានបុគ្គលិក | ប្រធានដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ |

# សេចក្តីថ្លែងអំណរគុណ

ជាបបមនាងខ្ញុំសូមថ្លែងអំណរគុណដល់ វិទ្យាស្ថានជាតិអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា និងអង្គការមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា Cambodia International Education Support Foundation (CIESF) ដែលបានរៀបចំ និងផ្តល់អាហារូបករណ៍ ក៏ដូចជាផ្តល់ឱកាសដល់រូបនាងខ្ញុំបានសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំនាពេលកន្លងមកនេះ ។

នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះគណៈគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំព្រមទាំងសាស្ត្រាចារ្យទាំងអស់ដែលបានខិតខំចំណាយពេលវេលាដ៏មមាញឹកនិងមានតម្លៃបំផុតមក បង្ហាត់បង្រៀន និងពន្យល់គ្រប់មេរៀនដល់យើងខ្ញុំទាំងអស់គ្នាដោយមិនគិតពីការលំបាក និងពេលវេលាដ៏មានតម្លៃឡើយ។ ជាពិសេសនាងខ្ញុំសូមថ្លែងអំណរគុណចំពោះ **ឯកឧត្តម នៀ សុផន** និង **លោកសាស្ត្រាចារ្យ ម៉ន មុនិន្ទ** ដែលតែងតែចំណាយពេលវេលាដ៏មានតម្លៃដើម្បីពន្យល់ និងណែនាំដល់រូបខ្ញុំគ្រប់ជំហានទើបធ្វើឱ្យការសិក្សាស្រាវជ្រាវរបស់ខ្ញុំនាពេលនេះ ទទួលបានជោគជ័យ និងបញ្ចប់ដោយភាពរលូន។

នាងខ្ញុំសូមថ្លែងអំណរគុណដល់ គណៈគ្រប់គ្រង ប្រធាន អនុប្រធានការិយាល័យ/ដេប៉ាតឺម៉ង់ វិទ្យាស្ថានគរុកោសល្យភ្នំពេញ និងវិទ្យាស្ថានគរុកោសល្យបាត់ដំបង គ្រូឧទ្ទេស និងគរុនិស្សិតបរិញ្ញាបត្រអប់រំជំនាន់ទី១នៃវិទ្យាស្ថានគរុកោសល្យទាំងពីរ ដែលបានចូលរួមសហការក្នុងពេលដំណើរការប្រមូលទិន្នន័យ ដែលធ្វើឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។

ជាទីបញ្ចប់នាងខ្ញុំសូមប្រសិទ្ធពរជ័យ ជូនចំពោះឯកឧត្តម លោក លោកស្រី នាងកញ្ញា និងគរុនិស្សិតទាំងអស់គ្នា សូមមានសុខភាពល្អបរិបូរណ៍ កម្លាំងពលំមាំមួន ប្រកបការងារទទួលបានជោគជ័យគ្រប់ភារកិច្ច ព្រមទាំងទទួលបាននូវពុទ្ធពរទាំង៤ប្រការគឺអាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**

# មូលន័យសង្ខេប

ថ្មីៗនេះក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់លើការបណ្ដុះបណ្ដាលគ្រូបង្រៀនដោយបានប្រែក្លាយមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យ និងវិក្រឹតការចំនួន៨ឱ្យទៅជាវិទ្យាស្ថានគរុកោសល្យចំនួនពីរ និងបានដាក់ឱ្យអនុវត្តកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំតាមរូបមន្ត១២+៤ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងវិទ្យាស្ថានគរុកោសល្យបាត់ដំបង។ កំណែទម្រង់នេះអាចនឹងជួបប្រទះនូវបញ្ហាប្រឈមខ្លះៗជាមិនខាន។ ការស្រាវជ្រាវនេះមានគោលបំណងសិក្សាពីៈ

១.ស្ថានភាពបច្ចុប្បន្នរបស់វិទ្យាស្ថានគរុកោសល្យទាំងពីរក្នុងការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំ។

២.បញ្ហាប្រឈមនានារបស់វិទ្យាស្ថានទាំងពីរក្នុងដំណើរការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំ។

ភាគសំណាកក្នុងការស្រាវជ្រាវនេះ ត្រូវបានជ្រើសរើសចេញពីវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងវិទ្យាស្ថានគរុកោសល្យបាត់ដំបង ដែលមានចំនួនសរុប**៣០៨**នាក់ ក្នុងនោះមានគណៈគ្រប់គ្រង**០៨**នាក់ ប្រធាន/អនុប្រធានការិយាល័យ**០៦**នាក់ ប្រធាន/អនុប្រធានដេប៉ាតឺម៉ង់ ឬគ្រូឧទ្ទេស**៩៨**នាក់ និងគរុនិស្សិត**២៩៦**នាក់ ដោយជ្រើសរើសតាមកម្មវិធីYamaneជាមួយភាពជឿជាក់៩៥%។

ឧបករណ៍ស្រាវជ្រាវមានពីរប្រភេទគឺកម្រងសំណួរបំពេញជាទម្រង់បិទ និងទម្រង់បើក (សម្រាប់ប្រធាន/អនុប្រធានដេប៉ាតឺម៉ង់/គ្រូឧទ្ទេស និងគរុនិស្សិត) និងសម្ភាសន៍ (សម្រាប់គណៈគ្រប់គ្រង និងប្រធាន/អនុប្រធានការិយាល័យ)។

ទិន្នន័យដែលប្រមូលបាន អ្នកស្រាវជ្រាវធ្វើការវិភាគដោយប្រើ Descriptive statistic, Mean, Standard deviation និងcompute veriable ក្នុងកម្មវិធី SPSS និងចាប់ជាក្រុមទៅតាមបញ្ហាប្រឈមធំៗ និងតាមប្រភេទភាគសំណាក។

លទ្ធផលសំខាន់ៗត្រូវបានបង្ហាញដូចខាងក្រោមៈ

១.ស្ថានភាពបច្ចុប្បន្នរបស់វិទ្យាស្ថានគរុកោសល្យទាំងពីរៈ ក្នុងចំណោមចំណុចធំៗទាំង៧ ចំណុចដែលអ្នកចូលរួមយល់ថាស្ថិតក្នុងកម្រិតល្អណាស់គឺ ចំណុចគុណភាពគរុនិស្សិត រីឯចំណុចការងារគ្រប់គ្រងនិងដឹកនាំ ការបង្រៀននិងរៀន កម្មវិធីសិក្សា និង

គុណភាពគ្រូឧទ្ទេស ស្ថិតក្នុងកម្រិតល្អ ហើយធនធានសិក្សា និងធនធានរូបវន្តស្ថិតក្នុងកម្រិតត្រូវយកចិត្តទុកដាក់។ បើពិនិត្យបន្ថែមលើសូចនាទាំង៣៩ក្នុងកម្រងសំណួរនៃផ្នែកទាំង៧ ចំណុចដែលស្ថិតក្នុងកម្រិតមធ្យមខ្ពស់ជាងគេគឺគរុនិស្សិតត្រូវបានជ្រើសរើសតាមរយៈការប្រឡងប្រជែង និងការត្រួតពិនិត្យម៉ត់ចត់ក្នុងការជ្រើសរើសអ្នកមានសមត្ថភាពពិតប្រាកដឱ្យចូលរៀន (Mean= ៤.៥១) រីឯចំណុចដែលពិន្ទុស្ថិតក្នុងកម្រិតទាបបំផុតគឺអន្តេវាសិកដ្ឋាន និងសម្ភារៈក្នុងអន្តេវាសិកដ្ឋាន (Mean=២.៦២) ប៉ុណ្ណោះ។

២.បញ្ហាប្រឈមនានារបស់វិទ្យាស្ថានទាំងពីរមានដូចជាៈ ក្របខណ្ឌកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត បរិមាណនិងគុណវុឌ្ឍិគ្រូឧទ្ទេស លិខិតបទដ្ឋានគតិយុត្តិ ការជ្រើសរើសគ្រូឧទ្ទេសថ្មីសម្រាប់បម្រើការនៅវិទ្យាស្ថាន បណ្ណាល័យខ្វះឯកសារក្នុងការស្រាវជ្រាវកិច្ចការស្រាវជ្រាវសម្រាប់គរុនិស្សិតច្រើន ខ្វះឯកសារជាភាសាជាតិ សមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសរបស់គ្រូឧទ្ទេសនិងគរុនិស្សិតមួយចំនួននៅមានកម្រិត ធនធានសិក្សា និងធនធានរូបវន្ត។

ដូចនេះដើម្បីចូលរួមជំរុញការងារបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំឱ្យទទួលបាននូវគុណភាព និងប្រសិទ្ធភាពខ្ពស់ ក្រសួងអប់រំ ក៏ដូចជាដៃគូរអភិវឌ្ឍនានា ឬអ្នកពាក់ព័ន្ធផ្សេងៗត្រូវជួយពង្រឹង និងកែលំអបន្ថែមទៀតនូវចំណុចអវិជ្ជមានទាំងឡាយដូចបានរៀបរាប់ខាងលើ។

## ABSTRACT

More recently, the Ministry of Education, Youth and Sport has reformed teacher training, transforming four teacher training centers into two teacher education colleges and has launched a teacher training for Bachelor of education, the formula 12 + 4 at Phnom Penh Teacher Education College and Battambangteacher Teacher Education College. The reform may face some challenges.The research aims to study:

1. Current situation of both Teacher Education Colleges (TEC) in the implementation of teacher training for Bachelor of education.

2. Challenges of both Teacher Education Colleges in the implementation of teacher training for Bachelor of education.

The study sample was selected from the Phnom PenhTeacher Education College and the Battambang Teacher Education College, with a total of 308 samples, including 8 government of teacher education colleges, 6 head/deputy of offices, 48 head/deputy of departments/teacher educators and 246 student teachers are recruited through the Yamane Program with a 95% credibility.

There are two types of research tools: closed and open-ended questionnaires (for head/deputy of departments, teacher educators and student teachers) and interviews (for government of teacher education colleges and head/deputy of offices)

The data collected, the researchers analyzed using the Descriptive Statistic, Mean, Standard deviation and compute veriable in the SPSS program and grouped the major challenges and sample types.

The main results are shown below:

1. The current status of the two teacher education colleges: Among the top seven points that participants feel to be very good are the quality of the student teachers, while the management and administration, teaching and learning, curriculm and the quality of the teacher educators are at a good level, learning resources and physical infrastruture are in insufficient. The 39 questionnaires of the top seven-point questionnaire at the highest mean were student teacher-selected through a competitive examination and rigorous selection of qualified candidates (Mean = 4.51). At the point where the score was the lowest, the dormitory and the material in the dormitory were only Mean (2.62).
2. Challenges of the two teacher education colleges are: Curriculum Framework, Curriculum, Quantity and Qualification of the teacher educators, legal standard letters, recruiting new teacher educators to work in Teacher education colleges, Lack of documents in the library , lots of research works for the student teachers, is lacking in the national language documents, the limited English language ability of some student teachers and teacher educators, learning resources and physical resources.

Therefore, in order to promote teacher training for Bachelor of education of high quality and effective, the Ministry of Education, as well as development partners or stakeholders, must strengthen and improve more on the negative side as mentioned above.

# មាតិកា

សេចក្តីអះអាងរបស់បេក្ខជន.......................................................................................i
លិខិតបញ្ជាក់ ..........................................................................................................ii
សេចក្តីថ្លែងអំណរគុណ ............................................................................................ iii
មូលន័យសង្ខេប........................................................................................................iv
ABSTRACT ...........................................................................................................vi
មាតិកា ................................................................................................................ vii
បញ្ជីតារាង ............................................................................................................ix

## ជំពូកទី១៖ សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ..................................................................................១
១.២ ចំណោទបញ្ហា.....................................................................................................២
១.៣ គោលបំណងនៃការស្រាវជ្រាវ ...............................................................................៤
១.៤ សំណួរស្រាវជ្រាវ..................................................................................................៥
១.៥ សារៈសំខាន់នៃការស្រាវជ្រាវ ...............................................................................៥
១.៦ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ...........................................................៦
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ..................................................................................៦

## ជំពូកទី២៖ រំលឹកទ្រឹស្តី

២.១ និយមន័យពាក្យគន្លឹះ............................................................................................៨
២.២ ក្របខណ្ឌកម្មវិធីសិក្សាបរិញ្ញាបត្រអប់រំ (១២+៤) ..................................................... ១០
២.៣  គន្លងអាជីពគ្រូបង្រៀន...................................................................................... ១៥
២.៤  តួនាទី និងភារកិច្ចរបស់គ្រូបង្រៀន ...................................................................... ១៦

២.៥ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅបណ្តាប្រទេសមួយចំនួន ................................. ១៧
២.៦ ស្តង់ដាទាំង៩នៃការធានាគុណភាពផ្ទៃក្នុងរបស់វិទ្យាស្ថានគរុកោសល្យ .......... ២៣
២.៧ ប្រវត្តិ និងស្ថានភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀននៅកម្ពុជា .................... ២៩

## ជំពូកទី៣៖ វិធីសាស្ត្រនៃការស្រាវជ្រាវ

៣.១ ការរៀបចំការស្រាវជ្រាវ.......................................................................... ៣៣
៣.២ ឧបករណ៍ស្រាវជ្រាវ................................................................................ ៣៣
៣.៣ ការប្រមូលទិន្នន័យ................................................................................. ៣៥
៣.៤ ដំណាក់កាលនៃការប្រមូលទិន្នន័យ ............................................................ ៣៦
៣.៥ ការវិភាគទិន្នន័យ ................................................................................... ៣៧
៣.៦ លក្ខណៈរបស់ភាគសំណាក......................................................................... ៣៨
៣.៧. ក្រមសីលធម៌នៃការស្រាវជ្រាវ .................................................................. ៤៣

## ជំពូកទី៤៖ លទ្ធផលស្រាវជ្រាវ

៤.១ លទ្ធផលការស្រាវជ្រាវសំណួរទី១៖................................................................ ៤៤
៤.២ លទ្ធផលការស្រាវជ្រាវសំណួរទី២៖ ............................................................... ៥៧
៤.៣ មតិដើម្បីជំរុញការងារបណ្តុះបណ្តាលឱ្យកាន់តែមានភាពល្អប្រសើរ និងមានការអភិវឌ្ឍសម្រាប់រយៈពេលខាងមុខ៖........................................................................ ៥៩

## ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ

៥.១ សេចក្តីសន្និដ្ឋាន .................................................................................... ៦២
៥.២ សំណូមពរ............................................................................................. ៦៤
ឯកសារយោង ............................................................................................. ៦៦

# បញ្ជីតារាង


តារាងទី ១៖ រចនាសម្ព័ន្ធនៃកម្មវិធីបរិញ្ញាបត្រអប់រំ (១២+៤) ........................................ ១២

តារាងទី ២៖ បំណែងចែកក្រេឌីតសិក្សា (១៣០ក្រេឌីត) ក្នុងរយៈពេល៤ឆ្នាំ................. ១៣

តារាងទី ៣៖ ចំនួនសំណាកដែលត្រូវបានជ្រើសរើសក្នុងសិក្សាស្រាវជ្រាវ................... ៣៦

តារាងទី៤៖ ស្ថានភាពបុគ្គលិកនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ................... ៣៩

តារាងទី៥៖ ស្ថានភាពបុគ្គលិកនៅវិទ្យាស្ថានគរុកោសល្យបាត់ដំបង ............................ ៤១

តារាងទី៦៖ ឋានៈ និងកម្រិតបណ្តុះបណ្តាលនៃភាគសំណាក ..................................... ៤២

តារាងទី៧៖ ការងារគ្រប់គ្រង និងដឹកនាំ (N= ២៩៤) ..................................................... ៤៤

តារាងទី៨៖ គុណភាពគ្រូឧទ្ទេស (N= ២៩៤) ............................................................... ៤៦

តារាងទី៩៖ កម្មវិធីសិក្សា (N= ២៩៤) ......................................................................... ៤៧

តារាងទី១០៖ គុណភាពគរុនិស្សិត (N= ២៩៤)............................................................. ៤៩

តារាងទី១១ ៖ ការបង្រៀននិងរៀន (N= ២៩៤) ............................................................ ៥០

តារាងទី១២៖ ធនធានសិក្សា (N= ២៩៤) ..................................................................... ៥២

តារាងទី១៣៖ ធនធានរូបវន្ត (N= ២៩៤) ...................................................................... ៥៥

តារាងទី១៤៖ សរុបរួម(N= ២៩៤) .............................................................................. ៥៦

# ជំពូកទី១៖ សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

បណ្តាប្រទេសលើសកលលោកធ្វើការប្រកួតប្រជែងគ្នាឥតឈប់ឈរពីមួយថ្ងៃ ទៅមួយថ្ងៃ លើគ្រប់វិស័យ ជាពិសេសវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ បច្ចេកវិទ្យា ផលិតកម្មនិងសេវាកម្ម ដើម្បីឱ្យប្រទេសខ្លួនអាចបំពេញតម្រូវការសង្គមជាតិ និងដើរទាន់ការរីកចម្រើននៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ វិស័យទាំងនោះរីកចម្រើនទៅបានគឺ មិនអាចខ្វះការអប់រំបានឡើយ ដូចនេះហើយទើបការអប់រំត្រូវបានគេចាត់ទុកថាជាកត្តាសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្ស ដើម្បីឆ្លើយតបទៅនឹងបម្រែបម្រួលទីផ្សារការងារយ៉ាងឆាប់រហ័សនៅក្នុងសង្គមពុទ្ធិ និងបរិបទសកលភាវូបនីយកម្ម (វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ, ផែនការយុទ្ធសាស្ត្រ២០១៩-២០២៣, ២០១៨)។

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវចក្ខុវិស័យ ដើម្បីប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេស ដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ (រាជរដ្ឋាភិបាលកម្ពុជា, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣, ២០១៩) ដោយកសាងជាជំហានៗនូវសង្គមកម្ពុជាមួយដែលមានស្ថិរភាព សុខសន្តិភាព សណ្តាប់ធ្នាប់ គោរពគោលការណ៍ប្រជាធិបតេយ្យ សិទ្ធិមនុស្ស នីតិរដ្ឋ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស មានការអភិវឌ្ឍប្រកបដោយចីរភាព មានកោសិកាផ្សារភ្ជាប់គ្នាមានប្រជាជនប្រកបដោយសុខដុមរមនាក្នុងសង្គមគ្រួសារសង្គមជាតិ និងមានកិត្យានុភាពខ្ពស់លើឆាកអន្តរជាតិ ។

វិស័យអប់រំដើរតួនាទីសំខាន់បំផុតដើម្បីធានាថា ប្រទេសកម្ពុជាមានមូលធនមនុស្សគ្រប់គ្រាន់ប្រកបដោយគុណភាពក្នុងការបម្រើការអភិវឌ្ឍជាតិ។ ក្រសួងអប់រំ យុវជន និងកីឡា បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការពង្រឹងគុណភាពអប់រំ បង្កើតបរិយាកាស និងក្តីសង្ឃឹមក្នុងការបង្កើនគុណភាពធនធានមនុស្សឱ្យស្របទៅនឹងសកលភាវូបនីយកម្មអប់រំទាំងនៅក្នុងតំបន់ និងលើសកលលោកតាមតម្រូវការទីផ្សារការងារនាសតវត្សរ៍ទី២១ ដោយការអភិវឌ្ឍធនធានមនុស្សដែលប្រកបដោយសមត្ថភាព គុណភាព និងគុណធម៌។ ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនក៏ជាផ្នែកមួយនៃកំណែទម្រង់ព្រឹត្តបត្រវិស័យអប់រំ ដើម្បីធានាបាននូវធនធានសក្តានុពល និងបំណិនវិជ្ជាជីវៈសម្រាប់ផ្ទេរវិជ្ជាសម្បទា បំណិន

សម្បទា ចរិយាសម្បទា និងសមត្ថភាពដល់សិស្សានុសិស្ស។ ការអប់រំគ្រូបានល្អត្រូវបាន គេចាត់ទុកថា ជាកត្តាសំខាន់ក្នុងការរួមចំណែក លើកកម្ពស់គុណភាពអប់រំនៅកម្ពុជា។

ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើននៃវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ការអប់រំនិងការបណ្តុះបណ្តាលគ្រូបង្រៀនមានការកែលម្អជាបន្តបន្ទាប់តាមរូបមន្តផ្សេងៗដូចជា៖ គ្រូបង្រៀន រូបមន្ត ៧+១ (ឆ្នាំ១៩៨៣) រហូតដល់១២+២បច្ចុប្បន្ន (វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ, សៀវភៅណែនាំកម្មសិក្សាគរុកោសល្យ, ២០១៩)។ ដោយសារតែកម្មវិធីបណ្តុះបណ្តាលនេះមិនទាន់បានសមស្របតាមគុណវុឌ្ឍិ គ្រូបង្រៀននៅថ្នាក់តំបន់ និងសកលលោកនៅឡើយ ទើបរាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៧២ និង៧៣អនក្រ.បក ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដំឡើងកម្រិតបណ្តុះបណ្តាល និងផ្លាស់ប្តូរមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូមានស្រាប់ចំនួនបួន ឱ្យទៅជាវិទ្យាស្ថានគរុកោសល្យចំនួនពីរដែលមួយនៅរាជធានីភ្នំពេញ និងមួយទៀតនៅខេត្តបាត់ដំបង។ ការកែទម្រង់បណ្តុះបណ្តាលគ្រូពីរូបមន្ត ១២+២ ទៅជា ១២+៤ (បរិញ្ញាបត្រអប់រំ) គឺដើម្បីពង្រឹងការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀននៅក្នុងប្រទេស ឱ្យកាន់តែមានគុណភាពខ្ពស់ជាគ្រូដែលទទួលបានជោគជ័យ តាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន (នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ, ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន, ២០១៦) ដែលជាស្តង់ដាអប្បបរមា។

នៅក្នុងប្រព័ន្ធអប់រំគ្រូបង្រៀនតាមរូបមន្ត ១២+៤ គរុនិស្សិតត្រូវបានតម្រូវឱ្យបំពេញកាតព្វកិច្ចសិក្សាចំណេះទូទៅជាផ្លូវការរយៈពេល១២ឆ្នាំ ដោយបានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) ទើបមានសិទ្ធិប្រឡងចូលរៀន។ គរុនិស្សិតដែលប្រឡងជាប់អាចទទួលការបណ្តុះបណ្តាល រយៈពេលបួនឆ្នាំ (១២+៤) នៅវិទ្យាស្ថានគរុកោសល្យ ហើយទទួលបានសញ្ញាបត្រវិជ្ជាជីវៈគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំ ដែលខុសពីពេលកន្លងមករៀនតែ០២ឆ្នាំប៉ុណ្ណោះ តែសញ្ញាបត្រដែលទទួលបានមានតម្លៃស្មើបរិញ្ញាបត្ររងប៉ុណ្ណោះ។ បន្ទាប់ពីគរុនិស្សិតទទួលការបណ្តុះបណ្តាលបានជោគជ័យ គរុនិស្សិតទាំងនោះនឹងត្រូវចេញទៅបម្រើការងារតាមការកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡានៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។

### ១.២ ចំណោទបញ្ហា

ផ្អែកតាមការស្រាវជ្រាវជាច្រើនបង្ហាញថា គ្រូបង្រៀនមានសញ្ញាបត្រកាន់តែខ្ពស់ ការបង្រៀនក៏កាន់តែមានគុណភាពខ្ពស់។ ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ភាគច្រើន គ្រូ

បង្រៀនត្រូវមានសញ្ញាបត្របរិញ្ញាបត្រ+២ (ក្រសួងអប់រំយុវជននិងកីឡា, ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន, ២០១៨)។

កម្ពុជានៅមិនទាន់អាចឈានដល់កម្រិតប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ នៅឡើយ ទោះបីជាការបណ្តុះបណ្តាលគ្រូបង្រៀនមានការវិវត្តជាច្រើនយ៉ាងណាក៏ដោយ ក៏គ្រូបង្រៀន ភាគច្រើនមិនទាន់មានសញ្ញាបត្របរិញ្ញាបត្រនៅឡើយ មិនតែប៉ុណ្ណោះថែមទាំងមានបញ្ហាប្រឈមមួយចំនួនទាក់ទងនឹងការពង្រឹងគុណភាពគ្រូបង្រៀន ការទាក់ទាញអ្នកមានឧបនិស្ស័យ និងសិស្សដែលមាននិទ្ទេសល្អៗ ឱ្យចូលបម្រើការងារជាគ្រូបង្រៀន ការរក្សាគ្រូបង្រៀនដែលមានស្រាប់ឱ្យនៅបម្រើការងារក្នុងវិស័យអប់រំបានយូរ ឬរហូតដល់ពេលចូលនិវត្តន៍។ ជាមធ្យម ក្រសួងអប់រំ យុវជន និងកីឡា បាត់បង់បុគ្គលិកអប់រំប្រមាណជាង ២០០០នាក់ ក្នុង១ឆ្នាំៗ ដែលក្នុងនោះអ្នកចូលនិវត្តន៍មានប្រមាណ១៥០០នាក់ លុបឈ្មោះចោលពីក្របខណ្ឌចំនួន ៥០០នាក់ និងសុំផ្ទេរទៅក្រសួងផ្សេងៗមានចំនួន២០០នាក់ (ក្រសួងអប់រំយុវជននិងកីឡា, ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន, ២០១៨)។

គ្រូបង្រៀនមួយចំនួនដែលចូលក្នុងក្របខណ្ឌអប់រំកាលពីឆ្នាំ១៩៩២- ១៩៩៣ មានសញ្ញាបត្រ ៨+១ (បង្រៀនថ្នាក់មត្តេយ្យ) ៨+២ បង្រៀននៅកម្រិតបឋមសិក្សា) ១១+២ (ថ្នាក់មធ្យមសិក្សាបឋមភូមិ) ១០+៤ និងបរិញ្ញាបត្រ (ថ្នាក់មធ្យមសិក្សាទុតិយភូមិ)។ ក្នុងឆ្នាំ ២០១៦-២០១៧ ការបណ្តុះបណ្តាលគ្រូបង្រៀនអនុវត្តប្រព័ន្ធ ១២+២ ទាំងអស់សម្រាប់គ្រប់កម្រិតសិក្សា លើកលែងតែកម្រិតមធ្យមសិក្សាទុតិយភូមិដែលអនុវត្តប្រព័ន្ធបរិញ្ញាបត្រ+១។

ក្នុងសម័យបច្ចេកវិទ្យាទំនើបនាសតវត្សរ៍ទី២១ កម្ពុជាត្រូវការគ្រូបង្រៀនគ្រប់កម្រិតមានសញ្ញាបត្រយ៉ាងហោចណាស់បរិញ្ញាបត្រ ដើម្បីបង្រៀនចាប់ពីមត្តេយ្យសាលារហូតដល់មធ្យមសិក្សាទុតិយភូមិ។ ដូច្នេះគរុនិស្សិតកម្រិតបរិញ្ញាបត្រអប់រំទាំងអស់ត្រូវត្រៀមខ្លួន ក្នុងការចាប់យកបំណិនសិក្សាសតវត្សរ៍ទី២១ ដែលមានដូចជា៖ ភាពច្នៃប្រឌិត ការគិតឱ្យបានល្អិតល្អន់ ការដោះស្រាយបញ្ហា ទំនាក់ទំនង ការសហការ អក្ខរកម្ម Digital (ជំនាញបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍មូលដ្ឋាន អក្ខរកម្មព័ត៌មាន អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ បំណិនស្រាវជ្រាវ បំណិនសង្គមវប្បធម៌ បំណិនតាមដាន និងគ្រប់គ្រងឥរិយាបថខ្លួនឯង) ដែលបំណិនទាំងនេះមានគោលបំណងជួយបណ្តុះបណ្តាលគ្រូបង្រៀនឱ្យមានសមត្ថភាពជាប្រព័ន្ធ។

គ្រូបង្រៀនជាមូលដ្ឋានគ្រឹះក្នុងការលើកកម្ពស់គុណភាពអប់រំ។ ការបណ្តុះបណ្តាលគ្រូបង្រៀនឱ្យមានគុណភាព និងប្រសិទ្ធភាពខ្ពស់គឺជារឿងដ៏ស្មុគស្មាញ និងលំបាកបំផុត ជាពិសេសការបណ្តុះបណ្តាលគ្រូបង្រៀននៅវិទ្យាស្ថានគរុកោសល្យ ដែលជាវិទ្យាស្ថានដំបូងនៅព្រះរាជាណាចក្រកម្ពុជា ព្រោះវាទាមទារឱ្យវិទ្យាស្ថានទាំងពីរត្រូវ៖

- មានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់
- មានធនធានសាស្ត្រាចារ្យ (គ្រូឧទ្ទេស) តាមមុខវិជ្ជានីមួយៗគ្រប់គ្រាន់
- មានរចនាសម្ព័ន្ធកម្មវិធីបណ្តុះបណ្តាល និងកម្មវិធីសិក្សាច្បាស់លាស់ ត្រឹមត្រូវដែលឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅមូលដ្ឋាន គោលនយោបាយអប់រំ និងការអប់រំប្រកបដោយចីរភាព
- មានការជ្រើសរើសគរុនិស្សិតប្រកបទៅដោយសមត្ថភាព និងតម្លាភាព
- មានធនធានរូបវន្តគ្រប់គ្រាន់ (អគារ បន្ទប់ពិសោធន៍ បន្ទប់ICT បណ្ណាល័យ...)
- មានការសហការគ្នាយ៉ាងល្អជាមួយនឹងសាលាសហការ
- មានការត្រួតពិនិត្យ តាមដាន វាយតម្លៃ និងកែលម្អការសិក្សារបស់គរុនិស្សិតជាប់ជាប្រចាំ។ល។

ដោយសារតែកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនតាមរូបមន្ត ១២ + ៤ នេះជាកម្មវិធីថ្មីដែលក្រសួងទើបដាក់ឱ្យអនុវត្តនៅវិទ្យាស្ថានគរុកោសល្យទាំងពីរ និងផ្តើមចេញពីស្ថានភាពខាងលើ ទើបធ្វើឱ្យអ្នកស្រាវជ្រាវផ្តោតការចាប់អារម្មណ៍ទៅលើការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំនេះ ថាតើការអនុវត្តកម្មវិធីថ្មីមានស្ថានភាពដូចម្តេច និងមានបញ្ហាប្រឈមអ្វីខ្លះ?

### ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះមានគោលបំណងដូចខាងក្រោម៖

១.សិក្សាពីស្ថានភាពបច្ចុប្បន្នរបស់វិទ្យាស្ថានគរុកោសល្យទាំងពីរ ក្នុងការអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំ។

២.សិក្សាពីបញ្ហាប្រឈមនានារបស់វិទ្យាស្ថានទាំងពីរ ក្នុងដំណើរការអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំ។

## ១.៤ សំណួរស្រាវជ្រាវ

ផ្អែកគោលបំណងខាងលើការស្រាវជ្រាវនឹងឆ្លើយតបសំណួរដូចខាងក្រោម៖

១.តើស្ថានភាពបច្ចុប្បន្នរបស់វិទ្យាស្ថានគរុកោសល្យទាំងពីរក្នុងការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំមានលក្ខណៈដូចម្តេច?

២.តើវិទ្យាស្ថានទាំងពីរជួបប្រទះនូវបញ្ហាប្រឈមអ្វីខ្លះក្នុងដំណើរការអនុវត្តកម្មវិធីបណ្តុះបណ្តាលនេះ?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះនឹងបង្ហាញពីសារៈសំខាន់ និងភាពឆ្លើយតបនៃកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំ និងរួមចំណែកមួយផ្នែក ក្នុងការផ្តល់ជាព័ត៌មានដល់ក្រសួងអប់រំ នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនទូទាំងរាជធានី-ខេត្ត និងដៃគូរអភិវឌ្ឍនានាក្នុងការស្វែងយល់ពីវិទ្យាស្ថានគរុកោសល្យទាំងពីរ។

លទ្ធផលដែលបានមកពីការសិក្សាស្រាវជ្រាវនេះ នឹងក្លាយជាព័ត៌មានដ៏មានអត្ថប្រយោជន៍ សម្រាប់ជាជំនួយក្នុងការចែករំលែកនូវបទពិសោធន៍ល្អៗ ដែលបានរកឃើញនៅក្នុងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងវិទ្យាស្ថានគរុកោសល្យបាត់ដំបង ទៅដល់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូដទៃទៀត ដែលនឹងបង្កើតជាវិទ្យាស្ថានគរុកោសល្យនៅពេលក្រោយៗ។ ការសិក្សាស្រាវជ្រាវនេះ ក៏ជាទុនមួយសម្រាប់អ្នកស្រាវជ្រាវ និងអ្នកសិក្សាជំនាន់ក្រោយអាចសិក្សាបន្តឱ្យបានកាន់តែមានលក្ខណៈលម្អិត ស៊ីជម្រៅ ដើម្បីជាប្រយោជន៍ក្នុងការចូលរួមចំណែកផ្តល់នូវបទពិសោធ និងព័ត៌មានល្អៗ សម្រាប់ថ្នាក់ដឹកនាំគណៈគ្រប់គ្រងវិទ្យាស្ថានក្នុងការបន្តនិរន្តរភាពនៃការអនុវត្តកម្មវិធីបណ្តុះបណ្តាលនេះ ស្វែងយល់បន្ថែមសម្រាប់កែលម្អនូវរាល់ចំណុចអវិជ្ជមានផ្សេងៗ និងដើម្បីបង្កើនប្រសិទ្ធភាព ប្រសិទ្ធផល នៃធាតុចេញក្នុងវិស័យអប់រំ តាមរយៈការលើកកម្ពស់គុណភាពគ្រូបង្រៀន សម្រាប់ជំនាន់ក្រោយៗក្នុងពេលបច្ចុប្បន្ន និងពេលខាងមុខដើម្បីអាចឈានទៅប្រកួតប្រជែងជាមួយថ្នាក់តំបន់ និងពិភពលោក។

### ១.៦ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ដើម្បីឱ្យការសិក្សាស្រាវជ្រាវដំណើរការទៅបានល្អ និងវិភាគបានគ្រប់ជ្រុងជ្រោយទៅលើប្រធានបទ៖ «**ស្ថានភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំ នៅវិទ្យាស្ថានគរុកោសល្យ**» អ្នកស្រាវជ្រាវបានកំណត់យកវិទ្យាស្ថានគរុកោសល្យទាំងពីរមកធ្វើការស្រាវជ្រាវ។ ដោយវិទ្យាស្ថានគរុកោសល្យក្នុងពេលបច្ចុប្បន្ន មានការបណ្តុះបណ្តាលគ្រូបង្រៀនទាំង ១២+២ និង១២+៤ អ្នកស្រាវជ្រាវបានជ្រើសរើសយកសំណាកតែអ្នកពាក់ព័ន្ធមួយចំនួនប៉ុណ្ណោះគឺ៖ គណៈគ្រប់គ្រង ប្រធានឬអនុប្រធានការិយាល័យ ប្រធានឬអនុប្រធានដេប៉ាតឺម៉ង់ គ្រូឧទ្ទេសដែលបង្រៀន១២+៤ និងគរុនិស្សិតបរិញ្ញាបត្រអប់រំជំនាន់ទី១នៃវិទ្យាស្ថានគរុកោសល្យទាំងពីរក្នុងឆ្នាំសិក្សា២០១៨- ២០១៩ សម្រាប់ធ្វើការវិភាគ។ ការវិភាគនេះផងដែរអ្នកស្រាវជ្រាវវិភាគពីស្ថានភាពរួម ដោយមិនបានញែកចេញពីគ្នារវាងវិទ្យាស្ថានទាំងពីរឡើយ។

### ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ស្នាដៃសិក្សាស្រាវជ្រាវនេះ ត្រូវបានចែកចេញជា៥ជំពូកធំៗគឺ៖

**ជំពូកទី១៖** សេចក្តីផ្តើម

នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងលើកឡើងពីលំនាំបញ្ហា ចំណោទបញ្ហា សំណួរស្រាវជ្រាវ គោលបំណង សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូកទី២៖** រំលឹកទ្រឹស្តី

នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងប្រមូលយកទ្រឹស្តីពីអ្នកសិក្សាស្រាវជ្រាវមុនៗ និងឯកសារនានាដែលពាក់ព័ន្ធទៅនឹងប្រធានបទនេះ ដើម្បីធ្វើជាគំនិតសម្រាប់ធ្វើការស្រាវជ្រាវ និងបង្កើតស្នាដៃថ្មី។

**ជំពូកទី៣៖** វិធីសាស្ត្រស្រាវជ្រាវ

នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញនូវឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រប្រមូលទិន្នន័យ វិធីជ្រើសរើសគំរូ វិធីសាស្ត្រក្នុងការវិភាគទិន្នន័យ លក្ខណៈរបស់ភាគសំណាក និងក្រមសីលធម៌នៃការស្រាវជ្រាវ។

**ជំពូកទី៤៖** លទ្ធផលស្រាវជ្រាវ

នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងយកទិន្នន័យដែលប្រមូលបានមកវិភាគ និងបកស្រាយដើម្បីរកឱ្យឃើញនូវចំណុចល្អ និងចំណុចដែលត្រូវធ្វើការកែលម្អនៅក្នុងស្ថានភាពជាក់ស្តែងរបស់វិទ្យាស្ថានគរុកោសល្យទាំងពីរ។

**ជំពូកទី៥៖** សេចក្តីសន្និដ្ឋាន និងសំណូមពរ

ក្នុងផ្នែកនេះ អ្នកស្រាវជ្រាវនឹងធ្វើសេចក្តីសន្និដ្ឋានទៅលើចំណុចទាំងអស់ដែលបានយកមកវិភាគ ព្រមទាំងលើកជាសំណូមពរមួយចំនួនទៅកាន់អ្នកពាក់ព័ន្ធ ក្នុងគោលបំណង រួមចំណែកធ្វើឱ្យការអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងវិទ្យាស្ថានគរុកោសល្យបាត់ដំបងកាន់តែល្អប្រសើរថែមទៀត ព្រមទាំងចំណុចដែលគ្រឹះស្ថានបណ្តុះបណ្តាលគ្រូក្រោយៗគួរត្រៀមពេលដែលគ្រឹះស្ថានរបស់ខ្លួនក្លាយទៅជាវិទ្យាស្ថានគរុកោសល្យ។

# ជំពូកទី២៖ រំលឹកទ្រឹស្តី

## ២.១ និយមន័យពាក្យគន្លឹះ

### ក.គ្រូបង្រៀន

គ្រូបង្រៀនមានន័យច្រើនបែបច្រើនយ៉ាង អាស្រ័យទៅលើការកំណត់របស់មនុស្សម្នាក់ៗ ឬក្រុមណាមួយជាអ្នកឱ្យតម្លៃ។ ន័យទាំងនោះមានដូចជា៖

-គ្រូបង្រៀនគឺជាអ្នកចេះដឹង គួរជាទីគោរពសម្រាប់មហាជនទូទៅក្នុងមូលដ្ឋាន និងជាទីចាប់អារម្មណ៍នៃសិស្សានុសិស្ស មាតាបិតាសិស្ស អាជ្ញាធរមូលដ្ឋានដែលតែងតែកត់សម្គាល់ និងវាយតម្លៃខ្ពស់ចំពោះគ្រប់សកម្មភាព (វិទ្យាស្ថានជាតិអប់រំ, ២០១៦)។

-យោងតាមបទបញ្ញត្តិនៃក្រុមប្រឹក្សាគ្រូបង្រៀនរបស់ប្រទេសថៃ បានកំណត់និយមន័យនៃពាក្យគ្រូបង្រៀនថា ជាប្រភេទមនុស្សដែលអាជីពដំបូង ឬសំខាន់របស់គាត់ទាក់ទងទៅនឹងដំណើរការនៃការបង្រៀននិងរៀន និងការលើកកម្ពស់ការសិក្សារបស់អ្នករៀន តាមរយៈការប្រើប្រាស់វិធីសាស្ត្រសំបូរបែប ទាំងក្នុងគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនចំពោះការអប់រំកុមារ អប់រំមូលដ្ឋាន និងឧត្តមសិក្សាហើយស្ថិតនៅក្រោយកម្រិតសញ្ញាបត្រដែលខ្លួនទទួលបាន (Wisalaporn, 2005) ។

-គ្រូបង្រៀនគឺជាបុគ្គលដែលរដ្ឋទុកចិត្តហើយប្រគល់ភារកិច្ចឱ្យបង្រៀន និងអប់រំកុមារទូទៅ។ (មាសសុភឿន, ២០១៧)

-គ្រូបង្រៀនសំដៅដល់ បុគ្គលិកបង្រៀននៃបុគ្គលិកអប់រំនៅគ្រឹះស្ថានសិក្សាសាធារណៈ និងគ្រឹះស្ថានសិក្សាឯកជនដែលមានអាជ្ញាប័ណ្ណអប់រំ (រាជរដ្ឋាភិបាលកម្ពុជា, អនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន, ២០០៨)។

-គ្រូបង្រៀនគឺសំដៅទៅដល់មន្ត្រីដែលបម្រើការងារនៅក្នុងវិស័យអប់រំ និងបានឆ្លងកាត់ការបណ្តុះបណ្តាលគរុកោសល្យ នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនណាមួយដោយមានការទទួលស្គាល់ពីក្រសួងអប់រំ (មាសសុភឿន, ២០១៧)។

### ខ.បរិញ្ញាបត្រអប់រំ

បរិញ្ញាបត្រអប់រំគឺជាកម្មវិធីបណ្តុះបណ្តាលផ្នែកអប់រំ ដែលគរុនិស្សិតត្រូវសិក្សារយៈពេល៤ឆ្នាំបន្ថែមក្រោយពីបញ្ចប់ការសិក្សាថ្នាក់ទី១២ដោយជោគជ័យ។ បរិញ្ញាបត្រអប់រំមានលក្ខណៈពិសេសដូចជា៖

- អភិវឌ្ឍជំនាញមុខវិជ្ជាឯកទេសដែលចាំបាច់ដើម្បីក្លាយជាគ្រូបង្រៀនអាជីព

- ផ្តោតលើការអនុវត្តទ្រឹស្តីក្នុងបរិបទសាលារៀន ដើម្បីទទួលបានជាក់ស្តែង
- អភិវឌ្ឍសមត្ថភាពគិតស៊ីជម្រៅ និងឆ្លុះបញ្ចាំងលើបទពិសោធការសិក្សានិងអនុវត្តន៍
- បញ្ចូលខ្លឹមសារនៃការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពក្នុងកម្មវិធីសិក្សា
- បញ្ចូលនូវវគ្គសិក្សាស្រាវជ្រាវ ភាសាបរទេស និងបច្ចេកវិទ្យាពត៌មានវិទ្យា ដល់គរុនិស្សិតទាំងអស់សម្រាប់ការធ្វើការ និងការរស់នៅក្នុងសតវត្សរ៍ទី២១ (វិទ្យាស្ថានគរុកោសល្យ, ក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំ, ២០១៧)។

**គ. វិទ្យាស្ថានគរុកោសល្យ**

វិទ្យាស្ថានគរុកោសល្យជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ អប់រំគ្រូបង្រៀនថ្នាក់បរិញ្ញាបត្រកម្រិតបឋមសិក្សា និងកម្រិតមូលដ្ឋានបង្រៀននៅអនុវិទ្យាល័យ (វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ, វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ, ២០១៩)។ វិទ្យាស្ថានមានៈ

**ចក្ខុវិស័យៈ** ជាវិទ្យាស្ថានឈានមុខគេក្នុងសតវត្សរ៍ទី២១។

**បេសកកម្មៈ**

- អប់រំគរុនិស្សិត និងអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនឱ្យមានគុណសម្បទាពេញលេញ
- លើកកម្ពស់ការស្រាវជ្រាវអប់រំដើម្បីបង្កើនគុណភាពការបង្រៀននិងរៀន
- ផ្តល់សេវាសហគមន៍ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍគ្រូបង្រៀន។

**គុណតម្លៃៈ**

- ការគោរពៈ ការបង្ហាញពីអារម្មណ៍វិជ្ជមាន និងការទទួលស្គាល់សីលតម្លៃផ្ទាល់ខ្លួន និងអ្នកដទៃតាមរយៈសកម្មភាព និងពាក្យសម្តី។
- សុចរិតៈ សេចក្តីស្មោះត្រង់របស់បុគ្គលម្នាក់ៗដែលស្តែងឡើងតាមរយៈ ការគិត ការបញ្ចេញយោបល់ និងសកម្មភាពវិជ្ជមានប្រកបដោយទំនួលខុសត្រូវខ្ពស់។
- នវានុវត្តន៍ៈ ការអភិវឌ្ឍខ្លួនឯងជាប្រចាំតាមរយៈការពិសោធជាក់ស្តែង និងការច្នៃប្រឌិតឱ្យទាន់តម្រូវការសង្គម និងសកលលោកដែលរីកចម្រើនឥតឈប់ឈរ។
- ការប្តេជ្ញាចិត្តៈ ការតាំងចិត្តខ្ពស់ដើម្បីឈានទៅដល់ ការសម្រេចចក្ខុវិស័យ បេសកកម្ម និងគោលបំណងរបស់វិទ្យាស្ថាន។

- ប្រសិទ្ធផលៈ សមិទ្ធផលការងារដែលសម្រេចបានប្រកបដោយគុណភាព ប្រសិទ្ធភាព និងចំណេញពេលវេលា ធនធាន ឬថាមពល។ (វិទ្យាស្ថានគរុកោសល្យ, ក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំ, ២០១៧)

## ២.២ ក្របខណ្ឌកម្មវិធីសិក្សាបរិញ្ញាបត្រអប់រំ (១២+៤)

### ២.២.១ លក្ខណៈនៃកម្មវិធីបណ្តុះបណ្តាល

ក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំនៅវិទ្យាស្ថានគរុកោសល្យ ផ្អែកលើកម្មវិធីកម្រិតបរិញ្ញាបត្រ (អប់រំ) នៅវិទ្យាស្ថានជាតិអប់រំរបស់ប្រទេសសិង្ហបូរី (NTU/NIE, 2017)។ កម្មវិធីបណ្តុះបណ្តាលនេះមានមុខវិជ្ជាមួយចំនួនដែលកំពុងបង្រៀននៅតាមសាលាគរុកោសល្យ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងមុខវិជ្ជាមួយចំនួនទៀតមាននៅថ្នាក់ទី១ដល់ទី១២នៃកម្មវិធីសិក្សាចំណេះទូទៅ និងការអប់រំបច្ចេកទេសរបស់ក្រសួងអប់រំ យុវជន និង កីឡា (វិទ្យាស្ថានគរុកោសល្យ, ក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំ, ២០១៧)។

- **កម្មវិធីសិក្សាលម្អិត (១២+៤)** គឺបានមកពីកម្មវិធីសិក្សាបរិញ្ញាបត្រអប់រំរបស់ NIE សឹង្ហបូរី កម្មវិធីសិក្សាបរិញ្ញាបត្ររបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងគ្រឹះស្ថានអប់រំឧត្តមសិក្សាផ្សេងៗទៀត កម្មវិធីសិក្សាចំណេះទូទៅថ្នាក់ទី១ ដល់ទី១២ (២០១៦) កម្មវិធីសិក្សាបរិញ្ញាបត្រអប់រំរបស់សាកលវិទ្យាល័យជប៉ុន និងជំនួយសហាប្រតិបត្តការរបស់គម្រោង ETEC/JICA និងVVOB។
- **គោលបំណងនៃកម្មវិធីបណ្តុះបណ្តាល១២+៤**

កម្មវិធីនេះបង្កើតឡើងក្នុងគោលបំណង ធ្វើសមាហរណកម្មល្អបំផុតមួយនៃសញ្ញាបត្របរិញ្ញាបត្រដែលមានមូលដ្ឋានគ្រឹះល្អលើផ្នែកអប់រំ ផលិតគរុនិស្សិតបញ្ចប់ការសិក្សាដោយជោគជ័យ ពេញដោយចំណេះដឹង និងជំនាញពូកែក្នុងអាជីពជាអ្នកអប់រំ និងរៀបចំគរុនិស្សិតសម្រាប់បង្រៀននៅកម្រិតបឋមសិក្សា ឬកម្រិតមធ្យមសិក្សាបឋមភូមិ។

- **ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន**

គរុនិស្សិតដែលបញ្ចប់ការសិក្សាដោយជោគជ័យ លើកម្មវិធីបរិញ្ញាបត្រអប់រំគឺជាគ្រូបង្រៀនដែលសម្រេចបានស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន (ក្រសួងអប់រំយុវជននិងកីឡា, ស្តង់

ជាវិជ្ជាជីវៈគ្រូបង្រៀន, ២០១០)។ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន (ចំណេះដឹងវិជ្ជាជីវៈ ការប្រតិបត្តិវិជ្ជាជីវៈ ការសិក្សាវិជ្ជាជីវៈ និងសីលធម៌វិជ្ជាជីវៈ) គឺជាមូលដ្ឋានគ្រឹះនៃការអនុវត្ត និងត្រូវបានផ្សារភ្ជាប់គ្រប់មុខវិជ្ជាទាំងអស់នៃកម្មវិធីបណ្តុះបណ្តាល១២+៤។ កម្រិតស្តង់ដានេះមានគោលបំណងលើកស្ទួយការបង្រៀននិងរៀនរបស់គ្រូបង្រៀន ដោយផ្តល់ «បរិស្ថានសិក្សាដែលមានសុវត្ថិភាព និងធ្វើឱ្យគរុនិស្សិតមានភាពក្លាហានក្នុងការសិក្សាបានល្អប្រសើរ»។

- **បំណិនសិក្សាសតវត្សរ៍ទី២១**

ពិភពលោកមានការផ្លាស់ប្តូរជាបន្តបន្ទាប់ ហើយការសិក្សាក៏គ្មានទីបញ្ចប់ដែរ។ ដូច្នេះគរុនិស្សិតត្រូវត្រៀមជាស្រេច ក្នុងការចាប់យកបំណិនសិក្សាសតវត្សរ៍ទី២១ ដូចជា ភាពច្នៃបង្កើត ការគិតឱ្យបានល្អិតល្អន់ ការដោះស្រាយបញ្ហា ទំនាក់ទំនង ការសហការ អក្ខរកម្មDigital (ជំនាញបច្ចេកវិទ្យាពត៌មាន និងសារគមនាគមន៍ (មូលដ្ឋាន) អក្ខរកម្មពត៌មាន អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ) បំណិនសង្គម វប្បធម៌ បំណិនតាមដាន និងគ្រប់គ្រងឥរិយាបថខ្លួនឯង។

បំណិនទាំងអស់នេះ នឹងជួយជំរុញឱ្យគរុនិស្សិតមានការត្រៀមខ្លួនជាស្រេចក្នុងសតវត្សរ៍ទី២១។ បំណិនសតវត្សរ៍ទី២១មានគោលបំណងបណ្តុះបណ្តាលគ្រូបង្រៀនឱ្យមានសមត្ថភាពជាប្រព័ន្ធ។ បំណិនទាំងនេះ នឹងបញ្ជ្រាបគ្រប់មេរៀនតាមលក្ខណៈពិសេស និងជាក់លាក់របស់វានៅក្នុងថ្នាក់រៀនដោយឡែកៗពីគ្នា។

- **ការស្រាវជ្រាវ**

គរុនិស្សិតនឹងទទួលបានការយល់ដឹងពីគោលបំណង ដំណើរការ លទ្ធផលនៃការអនុវត្តការស្រាវជ្រាវផ្នែកអប់រំ និងផ្នែកសិក្សា។ គរុនិស្សិតឆ្នាំទី៣នឹងរៀបចំធ្វើផែនការដឹកនាំ និងធ្វើបទបង្ហាញអំពីការស្រាវជ្រាវតូចមួយលើផ្នែកអប់រំនៅក្នុងបន្ទប់រៀន ឬវិទ្យាស្ថានរបស់ពួកគេ ដែលជាផ្នែកមួយជួយពួកគេក្នុងការបញ្ចប់ការសិក្សាបរិញ្ញាបត្រអប់រំ។

### ២.២.២ រចនាសម្ព័ន្ធនៃកម្មវិធីបរិញ្ញាបត្រអប់រំ (១២+៤)

កម្មវិធីសម្រាប់បណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំ មានរយៈពេល៤ឆ្នាំ សិក្សាតាមប្រព័ន្ធក្រេឌីតដែលមានចំនួន១៣០ក្រេឌីត ហើយបែងចែកជា២ដំណាក់គឺៈ

ថ្នាក់មូលដ្ឋាន១ឆ្នាំសិក្សា (មិនតិចជាង៣០ក្រេឌីត) និងថ្នាក់ជំនាញ៣ឆ្នាំសិក្សា (ច្រើនជាង ៩០ក្រេឌីត)។

**តារាងទី១៖ រចនាសម្ព័ន្ធនៃកម្មវិធីបរិញ្ញាបត្រអប់រំ (១២+៤)**

| ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ |
|---|---|---|---|
| ឆ្នាំមូលដ្ឋានមុខវិជ្ជារួមនិងឯកទេស | ការអប់រំគ្រូបង្រៀនកម្រិតបឋមសិក្សា | | |
| | ការអប់រំគ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិ | | |
| កម្មសិក្សាគរុកោសល្យនឹងធ្វើរៀងរាល់ឆ្នាំសិក្សានៃការអប់រំគ្រូបង្រៀន | | | |

គរុនិស្សិតទាំងអស់ត្រូវគោរពឱ្យបានខ្ជាប់ខ្ជួននូវលក្ខន្តិកៈប្រឡងចូល ដោយបែកចែកជាពីរផ្នែកគឺ ផ្នែកបង្រៀននៅបឋមសិក្សា និងផ្នែកបង្រៀននៅមធ្យមសិក្សាបឋមភូមិ។

### ២.២.៣ ប្រព័ន្ធក្រេឌីតសិក្សា

**ក្រេឌីតសិក្សា** ផ្តល់នូវការវាស់ស្ទង់បានភ្លាមៗនូវទំហំការសិក្សារបស់គរុនិស្សិតដែលទាក់ទងទាំងវត្តមាននៅក្នុងម៉ោងសិក្សា និងការសិក្សាដោយឯករាជ្យ។ ស្តង់ដា១ក្រេឌីតសម្រាប់មុខវិជ្ជាក្នុងថ្នាក់រៀនស្មើនឹង៤៥ម៉ោងនៃការសិក្សា( ទាំងរៀនក្នុង និងក្រៅថ្នាក់)។

ផ្អែកតាមគោលការណ៍នេះ ចំនួនម៉ោងក្នុងថ្នាក់នីមួយៗ អាស្រ័យទៅតាមប្រភេទថ្នាក់ក្នុងករណីបង្រៀនសុទ្ធនៅក្នុងថ្នាក់១ក្រេឌីតស្មើនឹង១៥ម៉ោងក្នុង១ឆមាស មានន័យថា ៣០ម៉ោងទៀតគរុនិស្សិតមានពេលគ្រប់គ្រាន់លើការសិក្សាស្រាវជ្រាវបន្ថែមទៅលើមេរៀននីមួយៗ រៀបចំបទបង្ហាញ ពិភាក្សាមេរៀន រំឭកមេរៀនឡើងវិញ និងធ្វើកិច្ចការដែលគ្រូដាក់ឱ្យ។ ថ្នាក់មន្ទីរពិសោធន៍/សិក្ខាសាលា ចំនួន៣០ម៉ោងក្នុងថ្នាក់រៀន និង១៥ម៉ោងស្វ័យសិក្សា និងកម្មសិក្សាគរុកោសល្យចំនួន៤៥ម៉ោងក្នុង១ឆមាស។

### តារាងទី២៖ បំណែងចែកក្រេឌីតសិក្សា (១៣០ក្រេឌីត) ក្នុងរយៈពេល៤ឆ្នាំ

| ឆ្នាំ | ក្រេឌីតសិក្សា | | ក្រេឌីតកម្មសិក្សា | |
|---|---|---|---|---|
| | កម្រិតបឋមសិក្សា | មធ្យមសិក្សាបឋមភូមិ | កម្រិតបឋមសិក្សា | មធ្យមសិក្សាបឋមភូមិ |
| ឆ្នាំទី១ | ៣៣ | ៣១ | ២ (២សប្តាហ៍) | ២ (២សប្តាហ៍) |
| ឆ្នាំទី២ | ២៩ | ២៨ | ៥ (៥សប្តាហ៍) | ៥ (៥សប្តាហ៍) |
| ឆ្នាំទី៣ | ២៦ | ២៦ | ៥ (៥សប្តាហ៍) | ៥ (៥សប្តាហ៍) |
| ឆ្នាំទី៤ | ២០ | ២៣ | ១០(១០សប្តាហ៍) | ១០(១០សប្តាហ៍) |
| សរុបក្រេឌីតតាមផ្នែក | **១០៨** | **១០៨** | **២២** | **២២** |
| **សរុបរួម** | **១៣០ក្រេឌីត** | | | |

### ២.២.៤ មុខវិជ្ជាសំខាន់ៗនៃកម្មវិធីបរិញ្ញាបត្រអប់រំ (១២+៤)

កម្មវិធីសម្រាប់បណ្តុះបណ្តាលគ្រូបង្រៀនឱ្យមានកម្រិតបរិញ្ញាបត្រអប់រំ មានមុខវិជ្ជាសិក្សា ៦សមាសភាគធំៗរួមមាន៖

**១.ការសិក្សាពីការអប់រំ៖** តម្រូវឱ្យគរុនិស្សិតសិក្សាពីបញ្ញត្តិសំខាន់ៗ និងគោលការណ៍អប់រំដែលចាំបាច់សម្រាប់ការបង្រៀនប្រកបដោយប្រសិទ្ធភាព និងឆ្លើយតបទៅនឹងការអនុវត្តនៅក្នុងសាលារៀន។

**២. ការសិក្សាពីកម្មវិធីសិក្សា៖** តម្រូវឱ្យគរុនិស្សិតសិក្សាពីចំណេះដឹងចិត្តគរុកោសល្យ និងបំណិនក្នុងការបង្រៀនមុខវិជ្ជាឯកទេសឱ្យស្របទៅតាមកម្មវិធីសិក្សាចំណេះទូទៅ។

**៣. ចំណេះដឹងលើខ្លឹមសារ**

- មុខវិជ្ជាឯកទេស៖ តម្រូវឱ្យគរុនិស្សិតសិក្សាឱ្យកាន់តែស៊ីជម្រៅ រឹងមាំនូវចំណេះដឹងខ្លឹមសារ បញ្ញត្តិមូលដ្ឋាន និងគោលការណ៍គ្រឹះតាមមុខវិជ្ជា។

- ចំណេះដឹងលើមុខវិជ្ជា៖ តម្រូវឱ្យគរុនិស្សិតពង្រឹងឡើងវិញលើខ្លឹមសារមុខវិជ្ជា នៅកម្រិតភូមិសិក្សា ដែលគរុនិស្សិតត្រូវបង្រៀនដើម្បីឱ្យគេមានសមត្ថភាព ពេញលេញក្នុងការបង្រៀន។

**៤. ការលើកកម្ពស់បំណិនភាសា បំណិនសរសេរ និងឧទ្ទេស៖** គរុនិស្សិតទទួលបាននូវទេពកោសល្យក្នុងការប្រើប្រាស់ភាសាមូលដ្ឋាន និងបំណិនប្រើភាសា ពន្យល់បកស្រាយក្នុងការបង្រៀនដូចជាបំណិនក្នុងការសរសេរកិច្ចតែងការបង្រៀន និក្ខេបបទ និងធ្វើសកម្មភាពស្រាវជ្រាវ។

**៥. មុខវិជ្ជារួម៖** សមាសភាគនេះ ណែនាំគរុនិស្សិតឱ្យយល់ពីភាពពាក់ព័ន្ធនឹងការរស់នៅក្នុងសង្គម។

**៦. កម្មសិក្សាគរុកោសល្យ៖** គរុនិស្សិតនឹងត្រូវបានបញ្ជូនទៅសាលារៀនចំណេះទូទៅតាមដំណាក់ៗ ជារួមមានរយៈពេល២២សប្តាហ៍ ដើម្បីឱ្យគរុនិស្សិតសង្កេត សម្របខ្លួនទៅតាមបរិបទជាក់ស្តែងនៃការបង្រៀន ជាពិសេសការបង្រៀនទៅតាមកម្រិតអភិវឌ្ឍរបស់សិស្ស។ ក្នុងរយៈពេលនៃកម្មសិក្សាគរុកោសល្យ គ្រូឧទ្ទេសនៅវិទ្យាស្ថានគរុកោសល្យធ្វើអធិការកិច្ចយ៉ាងហ្មត់ចត់ ដោយផ្តោតទៅលើការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្ត ហើយគរុនិស្សិតក៏ទទួលបានបទពិសោធន៍របស់គ្រូប្រចាំថ្នាក់រួមមានការបង្រៀន និងដំណើរការគ្រប់គ្រងថ្នាក់រៀន និងសាលារៀនផងដែរ។

ទិដ្ឋភាពទូទៅនៃកម្មសិក្សាគរុកោសល្យរយៈពេល៤ឆ្នាំ៖

- កម្មសិក្សាគរុកោសល្យឆ្នាំទី១៖ ការប្រមូលបទពិសោធ
- កម្មសិក្សាគរុកោសល្យឆ្នាំទី២៖ ភាពជាអ្នកជំនួយការ
- កម្មសិក្សាគរុកោសល្យឆ្នាំទី៣៖ អនុវត្តការបង្រៀនលើកទី១
- កម្មសិក្សាគរុកោសល្យឆ្នាំទី៤៖ អនុវត្តការបង្រៀនលើកទី២

### ២.២.៥ មុខវិជ្ជាឯកទេសសម្រាប់មធ្យមសិក្សាបឋមភូមិ

មុខវិជ្ជាឯកទេសសម្រាប់មធ្យមសិក្សាបឋមភូមិ ត្រូវបែងចែកទៅតាមឯកទេសអាស្រ័យលើការជ្រើសរើសរបស់គរុនិស្សិតនៅពេលប្រឡងចូលរៀន។ មុខវិជ្ជាឯកទេសទាំងនោះរួមមាន៖

**សម្រាប់ឯកទេសមិនមែនភាសាបរទេស**

- ឯកទេសភាសាខ្មែរ
- ឯកទេសគណិតវិទ្យា
- ឯកទេសរូបវិទ្យា
- ឯកទេសគីមីវិទ្យា
- ឯកទេសជីវវិទ្យា
- ឯកទេសផែនដី- បរិស្ថាន
- ឯកទេសប្រវត្តិ- ភូមិវិទ្យា
- ឯកទេសសីលធម៌ពលរដ្ឋ- គេហសេដ្ឋកិច្ចវិទ្យា
- ឯកទេសសុខភាពសិក្សា- គេហសេដ្ឋកិច្ចវិទ្យា
- ឯកទេសសិល្បៈ

**សម្រាប់ឯកទេសភាសាបរទេស**

- ឯកទេសភាសាអង់គ្លេស- ICT
- ឯកទេសភាសាបារាំង- ICT

(វិទ្យាស្ថានគរុកោសល្យ, ក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំ, ២០១៧)

## ២.៣ គន្លងអាជីពគ្រូបង្រៀន

គន្លងអាជីពគ្រូបង្រៀនជាប្រព័ន្ធលើកទឹកចិត្តគ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងអ្នកឯកទេសអប់រំ។ អាជីពជាគ្រូបង្រៀនចែកជាបីគន្លងគឺ គន្លងគ្រូបង្រៀន គន្លងគណៈគ្រប់គ្រងសាលារៀន និងគន្លងអ្នកឯកទេសអប់រំ។

គន្លងគ្រូបង្រៀន ត្រូវបានរៀបចំសម្រាប់គ្រូបង្រៀនដែលមានឧបនិស្ស័យបង្រៀនសិស្សក្នុងថ្នាក់រៀន និងចែកជាបីកម្រិតៈ

**១.គ្រូឈានមុខៈ** មានគុណផលការងារធ្វើឱ្យប្រសើរឡើងនូវការអនុវត្តកម្មវិធីសិក្សា ការបង្រៀន ការវាយតម្លៃ និងគុណផលសិក្សារបស់សិស្សនៅកម្រិតសាលារៀន។

**២.គ្រូគំរូៈ** មានគុណផលការងារធ្វើឱ្យប្រសើរឡើងនូវការអនុវត្តកម្មវិធីសិក្សា ការបង្រៀន ការវាយតម្លៃ និងគុណផលសិក្សារបស់សិស្សនៅតាមសាលារៀនកម្រិតស្រុក ឬខេត្ត។

**៣.គ្រូឆ្នើម៖** មានគុណផលការងារធ្វើឱ្យប្រសើរឡើងដល់គោលនយោបាយ និង អន្តរាគមន៍ពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីសិក្សា ការបង្រៀន ការវាយតម្លៃគុណផលសិក្សា របស់សិស្ស និងគុណផលសាលារៀននៅកម្រិតជាតិ (ក្រសួងអប់រំយុវជននិងកីឡា, ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន, ២០១៨)។

## ២.៤ តួនាទី និងភារកិច្ចរបស់គ្រូបង្រៀន

គ្រូបង្រៀនមានតួនាទីច្រើនបែប ច្រើនសណ្ឋាន អាស្រ័យទៅលើការយល់ឃើញ របស់បុគ្គលម្នាក់ៗ ឬក្រុមណាមួយជាអ្នកកំណត់។ យោងទៅតាមការសិក្សារបស់លោក (Hamer, 2005) តួនាទីរបស់គ្រូបង្រៀនមានប្រាំបីចំណុច៖ អ្នកតាមដានត្រួតពិនិត្យ អ្នករៀបចំចាត់ចែង អ្នកវាយតម្លៃ អ្នកផ្ទៀងផ្ទាត់គាំទ្រ អ្នកចូលរួម អ្នកមានធនធាន អ្នកបង្ហាត់ និងអ្នកសង្កេត។

ផ្អែកទៅលើឯកសាររបស់ក្រសួងអប់រំវិញ (នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ, ការគ្រប់គ្រងរដ្ឋបាល, ២០០៩) បានពន្យល់អំពីភារកិច្ចរបស់គ្រូបង្រៀនមានដូចជា៖

- គ្រូបង្រៀនក្នុងភារកិច្ចជាសិក្ខាបនធារី ជាកម្លាំងអប់រំចម្បងជួយសិស្សានុសិស្ស ដោយផ្ទាល់ ឱ្យសម្រេចភារកិច្ចរៀនសូត្ររបស់ខ្លួនដែលជាភារកិច្ចស្នូលរបស់សាលារៀន។
- គ្រូបង្រៀនក្នុងឋានៈជាសិក្ខាបនធារី ជាអ្នកបច្ចេកទេសត្រូវតែបង្រៀនមុខវិជ្ជានីមួយៗ តាមវិធីសាស្ត្រដែលក្រសួងអប់រំ យុវជន និងកីឡា បានកំណត់។
- គ្រូបង្រៀនក្នុងឋានៈជាសិក្ខាបនធារី ត្រូវទទួលខុសត្រូវក្នុងការបញ្ចប់កម្មវិធីសិក្សាប្រកបទៅដោយគុណភាព។

យោងទៅលើតួនាទីរបស់គ្រូបង្រៀន ដែលមានចែងនៅក្នុងសៀវភៅសីលធម៌វិជ្ជាជីវៈរបស់ វិទ្យាស្ថានជាតិអប់រំទំព័រ៥៣ បានកំណត់តួនាទីរបស់គ្រូបង្រៀនដូចខាងក្រោម៖

- ជាអ្នកសិក្សាម្នាក់ដ៏សកម្ម
- ជាធនធាននិងជាអ្នកចាំជួយសិស្ស
- ជាអ្នកត្រួតពិនិត្យ និងគ្រប់គ្រង (វិទ្យាស្ថានជាតិអប់រំ, ២០១៦)

សរុប មកយើងអាចកំណត់នូវតួនាទី និងភារកិច្ច របស់គ្រូបង្រៀនដូចខាងក្រោម៖

- គ្រូបង្រៀនមានតួនាទីជាអ្នកដឹកនាំសកម្មភាពបង្រៀននិងរៀន ក្នុងថ្នាក់និងក្រៅថ្នាក់ និងលើកទឹកចិត្តដល់សិស្សជាប្រចាំ។ គ្រូបង្រៀនត្រូវសម្រួលដល់សិស្សានុសិស្ស

ក្នុងការទទួលបាននូវផលប្រយោជន៍សង្គមដោយស្មើភាព និងមានទំនាក់ទំនងជាមួយ មាតា បិតា ឬអាណាព្យាបាលសិស្សដើម្បីតាមដាននូវរាល់សកម្មភាពសិក្សារបស់ពួកគេ។

- គ្រូបង្រៀនមានតួនាទីពិនិត្យ ស្តាប់ កែលម្អ ឱ្យដំបូន្មាន ឬធ្វើជាអាណាព្យាបាលអ្នកសិក្សាទូទៅ ដោយមិនលំអៀង និងមិនប្រកាន់អំពីប្រភព ភេទ អាយុ ពូជសាសន៍ ពណ៌សម្បុរ ជំនឿ សាសនា ភាសា និន្នាការនយោបាយ ធនធាន និងឋានៈសង្គមឡើយ។

- គ្រូបង្រៀនមានតួនាទីស្វ័យសិក្សា ស្រាវជ្រាវ បង្កើនចំណេះដឹងរបស់ខ្លួន និងចូលរួមក្នុងគ្រប់សកម្មភាពបណ្តុះបណ្តាលជាប្រចាំ (ការសិក្សាពេញមួយជីវិត)។

- គ្រូបង្រៀនមានតួនាទីយកចិត្តទុកដាក់លើការបង្រៀននិងរៀន ការពន្យល់ ការបកស្រាយ សម្របសម្រួល និងជួយលើកទឹកចិត្តសិស្សឱ្យខិតខំរៀន ស្រាវជ្រាវបន្ថែម ដល់សិស្សានុសិស្សនូវចំណេះដឹងនានាស្របតាមមុខវិជ្ជា ឬឯកទេសដែលខ្លួនកំពុងបង្រៀន។

- គ្រូបង្រៀនមិនត្រូវធ្វើឱ្យបាត់បង់មនសិការវិជ្ជាជីវៈក្នុងការបំពេញករណីកិច្ច និងកាតព្វកិច្ចរបស់ខ្លួនឡើយក្នុងការប្រកបវិជ្ជាជីវៈគ្រូបង្រៀន ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ក្រោមកិច្ចសន្យា ឬលក្ខន្តិកៈជាមួយស្ថាប័នសាធារណៈ ឬស្ថាប័នឯកជន ។

## ២.៥ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅបណ្តាប្រទេសមួយចំនួន

### ក.ស្តង់ដាវិជ្ជាជីវគ្រូបង្រៀននៅប្រទេសថៃ

ស្តង់ដាវិជ្ជាជីវគ្រូបង្រៀននៅប្រទេសថៃផ្តោតទៅលើសមាសភាគធំៗ ចំនួនបួនគឺ៖

**១. ស្តង់ដានៃចំណេះដឹងរបស់គ្រូបង្រៀន៖** គឺសំដៅទៅលើចំណេះដឹងផ្សេងៗរបស់គ្រូបង្រៀនដូចជា ភាសា និងបច្ចេកវិទ្យាសម្រាប់គ្រូបង្រៀន ការអភិវឌ្ឍកម្មវិធីសិក្សា ការគ្រប់គ្រងការរៀនសូត្ររបស់សិស្ស ចិត្តវិទ្យាសម្រាប់គ្រូបង្រៀន ការវាស់វែង និងការវាយតម្លៃក្នុងវិស័យអប់រំ ការគ្រប់គ្រងថ្នាក់រៀន ការស្រាវជ្រាវក្នុងវិស័យអប់រំ ការបញ្ចូលរបៀបថ្មី និងព័ត៌មានបច្ចេកវិទ្យា មិត្តភាពគ្រូបង្រៀន។

**២.ស្តង់ដានៃបទពិសោធន៍វិជ្ជាជីវៈរបស់គ្រូបង្រៀន៖** មានន័យថាគ្រូបង្រៀនគឺជាបុគ្គលដែលបានបញ្ចប់ជាស្ថាពរនូវការបណ្តុះបណ្តាលនៅក្នុងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ក្នុងនោះមានការអនុវត្តនូវកម្មវិធីបណ្តុះបណ្តាលពេញមួយឆ្នាំ និងការទទួលបានលទ្ធផលជាប់ជាស្ថាពរក្នុងការវាយតម្លៃពីស្ថាប័នបណ្តុះបណ្តាលគ្រូបង្រៀនដោយផ្អែកទៅលើច្បាប់ ដំណើរការ និងលក្ខខណ្ឌដែលបានកំណត់ដោយក្រុមប្រឹក្សាគ្រូបង្រៀននៃប្រទេសថៃដូចខាងក្រោម៖

- ការបណ្តុះបណ្តាលទៅលើការអនុវត្តវិជ្ជាជីវៈក្នុងអំឡុងពេលសិក្សា
- ការបណ្តុះបណ្តាលមុខវិជ្ជាជំនាញ នៅក្នុងគ្រឹះស្ថានអប់រំគ្រូបង្រៀន

**៣.ស្តង់ដានៃការអនុវត្តការងារប្រចាំថ្ងៃរបស់គ្រូបង្រៀន**

- អនុវត្តសកម្មភាពបង្រៀនជាប្រចាំដោយមានទំនាក់ទំនងទៅនឹងការអភិវឌ្ឍសមត្ថភាពបង្រៀនរបស់គ្រូ
- មានការសម្រេចចិត្តអនុវត្តនូវសកម្មភាពផ្សេងៗ
- ប្តេជ្ញាអភិវឌ្ឍអ្នកសិក្សាឲ្យសម្រេចនូវសក្តានុពល
- អភិវឌ្ឍផែនការបង្រៀនផ្សេងៗ សម្រាប់ការអនុវត្តប្រកបទៅដោយប្រសិទ្ធភាព អភិវឌ្ឍជាប្រចាំនូវប្រព័ន្ធផ្សព្វផ្សាយការបង្រៀនប្រកបទៅដោយប្រសិទ្ធភាព
- រៀបចំសកម្មភាពបង្រៀនដោយផ្តោតទៅលើលទ្ធផលសិក្សារបស់សិស្ស
- ធ្វើរបាយការណ៍ពីគុណភាពនៃការសិក្សារបស់សិស្ស ដែលមានលក្ខណៈជាប្រព័ន្ធ
- ធ្វើជាគំរូល្អសម្រាប់អ្នកសិក្សា
- បង្កើតកិច្ចសហប្រតិបត្តិការជាមួយនឹងបណ្តាគ្រឹះស្ថានអប់រំដទៃទៀត
- បង្កើតទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយនឹងសហគមន៍ផ្សេងៗ
- ស្វែងរក និងប្រើប្រាស់នូវព័ត៌មានសម្រាប់ការអភិវឌ្ឍ
- បង្កើតឱកាសសិក្សាឱ្យបានច្រើនសម្រាប់អ្នករៀនក្នុងការសិក្សាគ្រប់កាលៈទេសៈ

**៤. ស្តង់ដានៃការធ្វើទំនាក់ទំនងមានដូចជា**

- ក្រមសីលធម៌ផ្ទាល់ខ្លួន
- ក្រមសីលធម៌វិជ្ជាជីវៈ
- ក្រមសីលធម៌សង្គម (មាសសុភឿន, ២០១៧)

**ខ.ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅប្រទេសនវេស**

សម្រាប់ប្រទេសនវេសស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនបានកំណត់នូវសមាសភាគធំៗចំនួន៧គឺ៖

ស្តង់ដាទី១៖ ចំណេះដឹងឯកទេស

ស្តង់ដាទី២៖ ការផ្ទេរចំណេះដឹង

ស្តង់ដាទី៣៖ ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងឥរិយាបថផ្ទាល់ខ្លួន

ស្តង់ដាទី៤៖ ការអភិវឌ្ឍ និងការសិក្សា

ស្តង់ដាទី៥៖ ជំនាញក្នុងការទំនាក់ទំនង

ស្តង់ដាទី៦៖ ការពិនិត្យតាមដាន វាយតម្លៃ និងផ្តល់ព័ត៌មានត្រឡប់

ស្តង់ដាទី៧៖ ការបង្កើតទំនាក់ទំនង សហប្រតិបត្តិការ (មាសសុភឿន, ២០១៧)

**គ.ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅប្រទេសកម្ពុជា**

ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនរបស់កម្ពុជាយើងបានកំណត់នូវសមាសភាគធំៗចំនួន៤ គឺ៖ ចំណេះដឹងវិជ្ជាជីវៈ ការប្រតិបត្តិវិជ្ជាជីវៈ ការសិក្សាវិជ្ជាជីវៈ និងសីលធម៌វិជ្ជាជីវៈ។ នៅក្នុងសមាសភាគនីមួយៗ មានអនុសមាសភាគជាច្រើនទៀតដូចជា៖

**១.ចំណេះដឹងវិជ្ជាជីវៈ**

ចំណេះដឹងវិជ្ជាជីវៈរបស់គ្រូបង្រៀនសំដៅទៅលើ ចំណេះដឹងផ្នែកឯកទេសរបស់គ្រូបង្រៀន និងចំណេះដឹងទូទៅផ្សេងៗទៀតៗដ៏សំបូរបែបដូចជា យល់ដឹងច្បាស់ពីតម្រូវការនៃការសិក្សាបន្ថែម ប្រវត្តិសិក្សា និងឥរិយាបថរបស់សិស្សម្នាក់ៗ ព្រមទាំងធ្វើការស្វែងយល់ពីប្រវត្តិរបស់សិស្ស ស្ថានភាពគ្រួសាររបស់សិស្ស និងកត្តាផ្សេងៗដទៃទៀតដែលមានឥទ្ធិពលលើការសិក្សារបស់សិស្សដូចជា បញ្ហាយេនឌ័រ កត្តាសង្គម សេដ្ឋកិច្ច ពិការភាពរបស់សិស្ស សិស្សជាជនជាតិភាគតិច និងតម្រូវការផ្សេងៗរបស់សិស្ស។

ម្យ៉ាងទៀតគ្រូបង្រៀនត្រូវធ្វើការសិក្សាពីគោលនយោបាយនានា របស់ក្រសួងអប់រំ ដូចជា គោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ គោលបំណងនៃការអប់រំចំណេះទូទៅ និងរៀបរាប់បានពីវិធីផ្សេងៗដើម្បីធ្វើឱ្យសម្រេចនូវគោលនយោបាយទាំងនោះ។ យោងតាមមាត្រាទី៨នៃក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនបានកំណត់ថា គ្រូបង្រៀនមានករណីកិច្ចរៀបចំកិច្ចតែងការបង្រៀន កំណត់ការពន្យល់ សំដៅធានាគុណភាព និងប្រសិទ្ធភាពនៃការរៀន (នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ, ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន, ២០១៦) ។

លើសពីនេះទៀតគ្រូបង្រៀនត្រូវតែយល់ឱ្យស៊ីជម្រៅទៅលើកិច្ចតែងការបង្រៀន ពីរបៀបកំណត់វត្ថុបំណងមេរៀន និងធាតុសំខាន់ៗដែលមាននៅក្នុងកិច្ចតែងការបង្រៀន

ហើយកំណត់វិធីសាស្ត្រក្នុងការបង្រៀនដោយផ្អែកលើគោលវិធីសិស្សមជ្ឈមណ្ឌល។ មិនតែប៉ុណ្ណោះគ្រូបង្រៀនត្រូវចេះអំពីរបៀបវាយតម្លៃការសិក្សារបស់សិស្ស ថាតើសិស្សមានការយល់ដឹងកម្រិតណា ហើយលទ្ធផលអាចទទួលយកបានឬទេ និងមានវិធានការកែលម្អទាន់ពេលវេលា ព្រមទាំងមានការរៀបចំនូវសម្ភារៈបង្រៀនឱ្យសំបូរបែប និងស្របតាមខ្លឹមសារមេរៀននីមួយៗ (នាយកដ្ឋានបណ្ដុះបណ្ដាលនិងវិក្រឹតការ, ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន, ២០១៦)។

### ២.ការប្រតិបត្តិវិជ្ជាជីវៈ

ការប្រតិបត្តិប្រកបដោយប្រសិទ្ធភាព លុះត្រាតែគ្រូបង្រៀនបានត្រៀមនូវកិច្ចតែងការសកម្មភាពបង្រៀន វិធីសាស្ត្របង្រៀន និងសម្ភារៈបង្រៀនឱ្យបានច្បាស់លាស់ស្របតាមកម្មវិធីសិក្សារបស់ក្រសួងអប់រំ ដោយផ្អែកលើសៀវភៅសិក្សាគោលទាំងសិស្សទាំងគ្រូ។ ដើម្បីសម្រេចបាននូវវត្ថុបំណងមេរៀន គ្រូត្រូវចេះច្នៃប្រឌិតសម្ភារៈបង្រៀនងាយៗ ដែលអាចរកបាននៅក្នុងស្រុក ហើយរៀបចំសម្ភារៈបង្រៀននិងរៀនទាំងនោះប្រកបដោយប្រសិទ្ធភាពដើម្បីដឹកនាំសិស្សទាំងអស់ឱ្យទទួលបាននូវលទ្ធផលគួរជាទីពេញចិត្ត។ បន្ថែមលើនេះទៀតគ្រូបង្រៀនត្រូវតាមដានការចូលរួមរបស់សិស្ស តាមរយៈការសង្កេត ធ្វើកំណត់ត្រា ព្រមទាំងថែរក្សាកំណត់ត្រារបស់សិស្សអំពីការចូលរួម និងសកម្មភាពនៃការសិក្សារបស់ពួកគេ។ គ្រូបង្រៀនត្រូវផ្ដល់ព័ត៌មានត្រឡប់ទៅសិស្ស មាតាបិតា ឬអាណាព្យាបាលសិស្សអំពីការអភិវឌ្ឍចំណេះដឹង បំណិន និងឥរិយាបថរបស់សិស្សដោយផ្ទាល់មាត់ ឬជាលាយលក្ខអក្សរតាមរយៈសន្លឹកកិច្ចការ ឬទំនាក់ទំនងផ្សេងៗដូចជារបាយការណ៍ សៀវភៅតាមដានសិក្សារបស់សិស្ស ឬទៅជួបផ្ទាល់ក្នុងករណីចាំបាច់។

គ្រូបង្រៀនត្រូវផ្ដល់ឱ្យសិស្សគ្រប់ៗរូបទទួលបាននូវ បរិស្ថានសិក្សាដែលប្រកបទៅដោយសុវត្ថិភាព និងធ្វើឱ្យមានការប្រឹងប្រែងអស់ពីសមត្ថភាព ព្រមលើកទឹកចិត្តសិស្សឱ្យកាន់តែមានការទទួលខុសត្រូវខ្ពស់លើការសិក្សារបស់ខ្លួន។ គ្រូបង្រៀនត្រូវប្រើវិធីបង្រៀន

ផ្សេងៗ និងមានការផ្លាស់ប្តូរជាប្រចាំដូចជាការប្រើប្រាស់នូវវិធីអនុមានរួម អនុមានញែក ការងារក្រុម ពន្យល់បង្ហាញពីដំណោះស្រាយបញ្ហាផ្សេងៗ។ គ្រូបង្រៀនគួរជ្រើសរើសវិធីបង្រៀនដោយគិតអំពីសិស្សផងដែរ នូវរបៀបរៀនរបស់សិស្សពូកែ សិស្សមធ្យម និងសិស្សខ្សោយ ព្រោះវាជាមធ្យោបាយដឹកនាំសិស្ស ឱ្យសម្រេចគោលដៅសិក្សា។ ក្នុងនោះក៏ត្រូវមានការរៀបចំ និងផ្តល់ឱកាសសិក្សាដោយភាពច្នៃប្រឌិត និងការបង្រៀនដោយការប្រើបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ទៅដល់សិស្សផងដែរ (នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ, ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន, ២០១៦)។

គ្រូបង្រៀនក៏ត្រូវជៀសវាងនូវការប្រតិបត្តិណា ដែលអាចប៉ះពាល់ដល់កិត្តិយសគ្រូបង្រៀន។ យោងតាមមាត្រាទី១២នៃក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនគឺថា គ្រូបង្រៀនមិនត្រូវសមគំនិតតាមផ្លូវកាយ ឬតាមផ្លូវចិត្ត ឬសម្ភារៈ ឬតាមរយៈការផ្តល់មធ្យោបាយដែលធ្វើឱ្យខូចប្រយោជន៍អ្នកសិក្សាក្នុងសេវាអប់រំឡើយ។ គ្រូបង្រៀនមិនត្រូវដាក់ទណ្ឌកម្មខាងផ្លូវកាយ និងផ្លូវចិត្តដែលនាំឱ្យប៉ះពាល់ដល់អ្នកសិក្សាឡើយ គ្រូបង្រៀនជាមនុស្សអព្យាក្រឹតមានភាពសណ្តោសប្រណី និងជាអ្នកផ្តល់នូវភាពយុត្តិធម៌ដល់សិស្ស ហើយមានសេចក្តីថ្លៃថ្នូរដែលមនុស្សគ្រប់រូបគោរព និងស្រឡាញ់។ ដូច្នេះគ្រូបង្រៀនមិនត្រូវរៃអង្គាសប្រាក់ ឬប្រមូលប្រាក់ ក្រៅផ្លូវការ ឬធ្វើអាជីវកម្មនានាក្នុងថ្នាក់រៀនឡើយ។ គ្រូបង្រៀនត្រូវជៀសវាងការប្រកបមុខរបរផ្សេងៗក្នុងបរិវេណគ្រឹះស្ថានសិក្សា។ (នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ, ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន, ២០១៦)

### ៣. ការសិក្សាវិជ្ជាជីវៈ

គ្រូបង្រៀនមានតួនាទីជាអ្នកលើកទឹកចិត្ត និងធានាបាននូវភាពជោគជ័យរបស់សិស្សក្នុងការសិក្សា។ ដើម្បីឱ្យការសិក្សារបស់សិស្សប្រព្រឹត្តទៅបានល្អ គ្រូបង្រៀនត្រូវចេះរៀបចំស្វ័យវាយតម្លៃការសិក្សារបស់សិស្ស ការបង្រៀននិងរៀនរបស់ខ្លួន មានផែនការសិក្សាច្បាស់លាស់ ដើម្បីអភិវឌ្ឍវិជ្ជាជីវៈផ្ទាល់ខ្លួនប្រកបទៅដោយគុណភាព និង

ប្រសិទ្ធិភាព។ លើសពីនេះទៀតគ្រូបង្រៀនក៏ត្រូវមានចំណេះដឹងផ្នែកបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ សម្រាប់អនុវត្តក្នុងបង្រៀននិងរៀនរបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

**៤. សីលធម៌វិជ្ជាជីវៈ**

សីលធម៌វិជ្ជាជីវៈគឺសំដៅទៅលើគ្រប់ទិដ្ឋភាពដែលទាក់ទងទៅនឹងវិជ្ជាជីវៈរបស់គ្រូបង្រៀនដូចជាចំណេះដឹងឯកទេស ក្រមសីលធម៌ និងមនសិការវិជ្ជាជីវៈជាដើម។ គ្រូបង្រៀនត្រូវដឹកនាំសកម្មភាពសិក្សាក្នុងនិងក្រៅថ្នាក់ និងលើកទឹកចិត្តដល់អ្នកសិក្សា ជាប្រចាំ មិនត្រូវដាក់សម្ពាធយកជាប្រយោជន៍លើអ្នកសិក្សាឡើយ។ គ្រូបង្រៀនត្រូវជួយសម្រួលដល់អ្នកសិក្សាឱ្យទទួលបាននូវផលប្រយោជន៍សង្គមដោយមិនលំអៀង និងត្រូវមានទំនាក់ទំនងល្អជាមួយសិស្ស ជាមួយសហការី ជាមួយអាណាព្យាបាលរបស់សិស្ស និងជាមួយសហគមន៍ផងដែរ។

គ្រូបង្រៀនត្រូវស្តាប់ ពិនិត្យ និងឱ្យដំបូន្មាន ឬធ្វើជាអាណាព្យាបាលអ្នកសិក្សាទូទៅដោយមិនលំអៀង និងមិនប្រកាន់អំពីប្រភព អាយុ ភេទ ភាសា ពូជសាសន៍ ដើមកំណើត ពណ៌សម្បុរ ពិការភាព យេនឌ័រ ជំនឿ សាសនា និន្នាការនយោបាយ ឬឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតៗនៅក្នុងការអប់រំ និងសេវាអប់រំ។ គ្រូបង្រៀនត្រូវនិយាយស្តីដោយប្រុងប្រយ័ត្ន និងគិតទៅដល់ប្រតិយាតនៃពាក្យសម្តីរបស់ខ្លួន ចំពោះអ្នកសិក្សា និងសាធារណៈជនក្នុងការផ្តល់ព័ត៌មានអំពីការអប់រំទាំងសាធារណៈ ទាំងឯកជន តាមគ្រប់មធ្យោបាយផ្សព្វផ្សាយ។ គ្រូបង្រៀនមិនត្រូវធ្វើប្រជាភិថុតិចំពោះអ្នកសិក្សាឡើយ ត្រូវបង្ហាញពីការប្តេជ្ញាចិត្ត និងចូលរួមចំណែកក្នុងវិជ្ជាជីវៈគ្រូបង្រៀនប្រកបទៅដោយស្មារតីទទួលខុសត្រូវខ្ពស់។ គ្រូបង្រៀនត្រូវបង្រៀន និងចូលរួមព្រឹត្តិការណ៍ផ្សេងៗឱ្យបានទៀងទាត់ ទាន់ពេលវេលាព្រមទាំងបង្ហាញអកប្បកិរិយារាក់ទាក់ និងចិត្តសម្បុរសធម៌។ (នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ, ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន, ២០១៦) ។

## ២.៦ ស្តង់ដាទាំង៩នៃការធានាគុណភាពផ្ទៃក្នុងរបស់វិទ្យាស្ថានគរុកោសល្យ

### ២.៦.១ ស្តង់ដាទី១៖ ការគ្រប់គ្រង និងដឹកនាំវិទ្យាស្ថាន

- វិទ្យាស្ថានមានរចនាសម្ព័ន្ធច្បាស់លាស់បង្ហាញពីសិទ្ធិអំណាច និងទំនាក់ទំនងការងារ ក្នុងវិទ្យាស្ថាន។
- ការកំណត់នូវតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលច្បាស់លាស់ ដោយអនុវត្តតាមបទបញ្ញត្តិពាក់ព័ន្ធ។
- ការអភិវឌ្ឍរបស់វិទ្យាស្ថានមានសង្គតិភាពជាមួយនឹង ចក្ខុវិស័យ បេសកកម្ម និងគោលដៅដែលបានកំណត់។
- បុគ្គលិករដ្ឋបាលមានគុណវុឌ្ឍិ សមត្ថភាព និងបទពិសោធន៍ស្របនឹងភារកិច្ចដែលខ្លួនទទួលខុសត្រូវ។
- តួនាទី និងភារកិច្ចរបស់សមាជិកក្រុមប្រឹក្សាភិបាល ត្រូវកំណត់ដាច់ដោយឡែកពីតួនាទីនិងភារកិច្ចនៃកិច្ចការរដ្ឋបាល និងកិច្ចការរបស់វិទ្យាស្ថាន។
- ក្រុមប្រឹក្សាភិបាលវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តការងាររបស់ដេប៉ាតឺម៉ង់ និងការិយាល័យរបស់ខ្លួនមានភាពទៀងទាត់។

### ២.៦.២ ស្តង់ដាទី២៖ លទ្ធផលសិក្សា

- អត្រាជាប់ និងអត្រាត្រួតថ្នាក់ត្រូវបានបង្កើតឡើង ពិនិត្យតាមដាននិងកំណត់គោលដៅដើម្បីកែលម្អ
- រយៈពេលមធ្យមដើម្បីបញ្ចប់ការសិក្សាគឺត្រូវបានបង្កើតឡើង ត្រួតពិនិត្យ និងកំណត់គោលដៅសម្រាប់ការកែលម្អ។
- របាយការណ៍វាយតម្លៃបញ្ចប់ការសិក្សាត្រូវបានបង្កើតឡើង បន្ទាប់ពីគរុនិស្សិតត្រូវបានទៅបង្រៀននៅតាមសាលាដែលបានកំណត់របស់វិទ្យាស្ថាន។
- ប្រភេទ និងបរិមាណនៃសកម្មភាពស្រាវជ្រាវត្រូវបានអនុវត្តដោយគរុនិស្សិត។
- ឯកសារស្នាដៃចុះកម្មសិក្សាគរុកោសល្យនិងនិក្ខេបបទរបស់គរុនិស្សិតត្រូវបានបង្កើត
- កម្រិតនៃការពេញចិត្តរបស់ភាគីពាក់ព័ន្ធត្រូវបានពិនិត្យ។

### ២.៦.៣ ស្តង់ដាទី៣៖ កម្មវិធីសិក្សា

- វិទ្យាស្ថានមានគណៈកម្មាធិការអភិវឌ្ឍកម្មវិធីសិក្សា ដែលប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព។
- កម្មវិធីសិក្សាមានលក្ខណៈស្របតាមគោលនយោបាយជាតិ ក្របខណ្ឌគុណវុឌ្ឍិជាតិ និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សង្គម។
- មុខវិជ្ជានីមួយៗក្នុងកម្មវិធីសិក្សា មានការសសេរកម្មវិធីសិក្សាលម្អិតច្បាស់លាស់ ដោយផ្អែកលើសៀវភៅគោល សៀវភៅយោង គេហទំព័រ ឯកសារសិក្សា និងឯកសារបង្រៀនផ្សេងៗទៀត។
- វិទ្យាស្ថានមានយន្តការកំណត់ចំនួនក្រេឌីតសិក្សា និងគោលនយោបាយ ឬគោលការណ៍នៃការផ្ទេរក្រេឌីតស្របតាមបទបញ្ញត្តិជាធរមាន។
- គ្រប់កម្មវិធីអប់រំមានការពិពណ៌នាច្បាស់លាស់អំពី លទ្ធផលសិក្សារបស់និស្សិត ដោយបញ្ជាក់ពីចំណេះដឹង ជំនាញ និងឥរិយាបថដែលគរុនិស្សិតនឹងទទួលបាន។
- វិទ្យាស្ថានប្រើវិធីសាស្ត្រ និងមធ្យោបាយច្រើនយ៉ាងក្នុងការវាយតម្លៃលើការសិក្សារបស់គរុនិស្សិត ដោយអនុលោមតាមលក្ខណវិនិច្ឆ័យដែលបានកំណត់។
- វិទ្យាស្ថានគរុកោសល្យពិនិត្យ និងកែលម្អកម្មវិធីអប់រំបានទៀងទាត់ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ។

### ២.៦.៤ ស្តង់ដាទី៤៖ គុណភាពបុគ្គលិកអប់រំ និងការគាំទ្រ

- បុគ្គលិកអប់រំមានគុណវុឌ្ឍិ និងបទពិសោធន៍សមស្របទៅនឹងមុខជំនាញឯកទេស និងកម្រិតនៃភារកិច្ចការងាររបស់ពួកគាត់ និងឆ្លើយតបនឹងគុណវុឌ្ឍិអប្បរមាដែលតម្រូវដោយវិទ្យាស្ថានគរុកោសល្យ។
- ភាគរយនៃចំនួនបុគ្គលិកមានចំនួនច្រើនគ្រប់គ្រាន់ក្នុងការធានាប្រសិទ្ធភាពនៃការបង្រៀន ណែនាំគរុនិស្សិត និងការអនុវត្តនៅក្នុងវិទ្យាស្ថាន។
- វិទ្យាស្ថានគរុកោសល្យមានដំណើរការច្បាស់លាស់ និងតម្លាភាពក្នុងការជ្រើសរើស អភិវឌ្ឍ វាយតម្លៃ លើកទឹកចិត្ត និងរក្សាទុកគ្រូឧទ្ទេស និងបុគ្គលិក។
- វិទ្យាស្ថានគរុកោសល្យរក្សាទុកឯកសាររបស់គ្រូឧទ្ទេសបង្រៀនពេញម៉ោង វេលាការ និងបុគ្គលិកបានត្រឹមត្រូវ។

- វិទ្យាស្ថានមានកញ្ចប់ថវិកាសមស្រប សម្រាប់គាំទ្រការអភិវឌ្ឍជំនាញដល់គ្រូឧទ្ទេស និងបុគ្គលិក។
- ការចាត់តាំងការងារមានសមធម៌សមហេតុផល និងគ្របដណ្ដប់តួនាទី និងការទទួលខុសត្រូវរបស់បុគ្គលិកទាំងអស់ ដោយផ្អែកលើការពិពណ៌នាការងាររបស់គាត់។
- របាយការណ៍វាយតម្លៃការងារប្រចាំឆ្នាំរបស់បុគ្គលិកអប់រំម្នាក់ៗ
- មានយុទ្ធសាស្ត្រដើម្បីគាំទ្រការស្រាវជ្រាវ និងសកម្មភាពសិក្សា។
- គោលនយោបាយ និងនីតិវិធីនានាពាក់ព័ន្ធនឹងការទ្រទ្រង់វិទ្យាស្ថាន សម្រាប់សកម្មភាពស្រាវជ្រាវ និងសកម្មភាពសិក្សា ត្រូវបានទាក់ទងយ៉ាងច្បាស់លាស់ដល់បុគ្គលិកបង្រៀន និងបុគ្គលិកមិនបង្រៀនទាំងអស់។

**២.៦.៥ ស្តង់ដាទី៥៖ គុណភាពអប់រំគរុនិស្សិត និងការគាំទ្រ**

- គោលនយោបាយ ឬគោលការណ៍ស្តីពីការជ្រើសរើសនិស្សិតចូលរៀន បានកំណត់ច្បាស់លាស់ និងអនុវត្តបានត្រឹមត្រូវ។
- សិស្សដែលមានសមត្ថភាពត្រូវបានអនុញ្ញាតឱ្យសិក្សានៅវិទ្យាស្ថានគរុកោសល្យ
- អ្នកគ្រប់គ្រង និងបុគ្គលិកប្រតិបត្តិត្រូវមានគុណវុឌ្ឍិ បទពិសោធន៍សមស្រប និងមានកំណត់នូវតួនាទីភារកិច្ចច្បាស់លាស់ ។
- វិទ្យាស្ថានផ្តល់សេវាប្រឹក្សា សេវាសុខភាព និងកម្មវិធីអប់រំសុខភាពដល់និស្សិតស្របតាមតម្រូវការជាក់ស្តែង។
- វិទ្យាស្ថានមានគោលនយោបាយ ឬគោលការណ៍ស្តីពីការផ្តល់អាហារូបករណ៍ដោយមានថែងលក្ខខណ្ឌច្បាស់លាស់ និងអនុវត្តបានត្រឹមត្រូវ។
- និស្សិតចូលរៀនថ្មី នៅគ្រប់កម្រិតសញ្ញាបត្រទទួលបានការណែនាំ ឬការតម្រង់ទិសពេញលេញ។
- វិទ្យាស្ថានបង្កើត និងធានាដំណើរការប្រព័ន្ធប្រឹក្សាយោបល់លើការសិក្សា ហើយវាយតម្លៃលើប្រព័ន្ធនោះបានទៀងទាត់។
- គរុនិស្សិតទទួលបានឱកាសក្នុងការចូលរួមក្នុងសកម្មភាពកម្មសិក្សាគរុកោសល្យ។
- ធ្វើផែនការអភិវឌ្ឍអាជីព និងជួយរកការងារឱ្យគរុនិស្សិត ព្រមទាំងតាមដានអំពី លទ្ធផលការងាររបស់គរុនិស្សិត តាមរយៈការបណ្តុះបណ្តាលវិក្រឹតការសម្រាប់គ្រូបង្រៀននៅតាមសាលាដែលជួបបញ្ហា។

- ផ្តល់ព័ត៌មានត្រឡប់ពីការបង្រៀនរបស់លោកគ្រូ អ្នកគ្រូតាមសាលា ត្រូវបានដាក់ពង្រាយឱ្យបម្រើការតាមសាលារៀនដែលបានកំណត់។
- គរុនិស្សិតទទួលបានឱកាសក្នុងការចូលរួមជួយបម្រើសហគមន៍ និងសកម្មភាពសង្គមផ្សេងៗ។
- វិទ្យាស្ថានមានគោលនយោបាយ ឬគោលការណ៍ស្តីពីការរក្សាទុកគរុនិស្សិត និងអត្រាបញ្ចប់ការសិក្សាបានកំណត់ច្បាស់លាស់ និងអនុវត្តបានត្រឹមត្រូវ។

**២.៦.៦ ស្តង់ដាទី៦៖ ការបង្រៀននិងរៀន**

- ដំណើរការនៃការបង្រៀននិងរៀន វង្វាយតម្លៃគរុនិស្សិតត្រូវបានពិនិត្យឡើងវិញ និងវាយតម្លៃដើម្បីធានាទំនាក់ទំនង និងការបន្សុីគ្នា។
- លទ្ធផលនៃការស្រាវជ្រាវត្រូវបានប្រើដើម្បីលើកកម្ពស់ការបង្រៀននិងរៀន។
- សេចក្តីត្រូវការ និងមតិយោបល់របស់ភាគីពាក់ព័ន្ធ
- ការរៀបចំនិងការអភិវឌ្ឍកម្មវិធីសិក្សាត្រូវបានបង្កើតឡើង និងលើកជាប្រធានបទក្នុងការវាយតម្លៃ និងការជំរុញឱ្យដល់គោលដៅ។
- ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត គម្រោងមេរៀនតាមមុខវិជ្ជា និងកិច្ចតែងការបង្រៀន។
- ការរៀនសូត្រតាមគម្រោងត្រូវបានអនុវត្តដើម្បីបង្កើនគុណភាពអប់រំ និងដើម្បីលើកកម្ពស់ការអប់រំសម្រាប់ការអភិវឌ្ឍការប្រកបដោយចីរភាពនៅក្នុងវិទ្យាស្ថាន។
- សកម្មភាពអប់រំសម្រាប់ការអភិវឌ្ឍការងារប្រកបដោយចីរភាពត្រូវបានលើកកម្ពស់វិទ្យាស្ថានក្នុងការធានាបរិស្ថាននៃការបង្រៀននិងរៀនប្រកបដោយប្រសិទ្ធភាព។

**២.៦.៧ ស្តង់ដាទី៧៖ ធនធានសិក្សា**

- បណ្ណាល័យមានកន្លែងអានគ្រប់គ្រាន់ និងបរិយាកាសអំណោយផលដល់ការសិក្សា និងស្រាវជ្រាវ។
- បណ្ណាល័យមានសៀវភៅសិក្សា ឯកសារយោង ទស្សនាវដ្តីវិទ្យាសាស្ត្រ និងសម្ភារសិក្សាផ្សេងៗសម្រាប់គាំទ្រដល់កម្មវិធីអប់រំ។
- បណ្ណាល័យមានបណ្ណារក្សជំនាញ និងបុគ្គលិកបម្រើការគ្រប់គ្រាន់នឹងទទួលបានការបណ្តុះបណ្តាលផ្នែកជំនាញគ្រប់គ្រងបណ្ណាល័យ ហើយមានសមត្ថភាពបម្រើតម្រូវការរបស់គរុនិស្សិត និងគ្រូបង្រៀននៅតាមដេប៉ាតឺម៉ង់។

- ចំនួនម៉ោងបើកបម្រើសេវារបស់បណ្ណាល័យស្របទៅនឹងតម្រូវការរបស់គរុនិស្សិត និង ដេប៉ាតឺម៉ង់។
- គរុនិស្សិតនិងគ្រូឧទ្ទេស ទទួលបានការណែនាំនិងការតម្រង់ទិស អំពីរបៀបប្រើប្រាស់បណ្ណាល័យ ព្រមទាំងធនធានសិក្សាផ្សេងៗ។
- គរុនិស្សិត និងគ្រូឧទ្ទេសទទួលបានឱកាសក្នុងការប្រើប្រាស់ធនធានសិក្សា ក្នុងប្រព័ន្ធបណ្ណាល័យ ទូរនិម្មិតសម្រាប់បំពេញតម្រូវការសិក្សា និងស្រាវជ្រាវស្របតាមកម្មវិធីអប់រំ។
- បណ្ណាល័យមានថវិកាគ្រប់គ្រាន់សម្រាប់គាំទ្រផែនការរយៈពេលវែង និងរយៈពេលខ្លី ដើម្បីអភិវឌ្ឍបណ្ណាល័យឱ្យកាន់តែប្រសើរឡើង។
- វិទ្យាស្ថានមានបន្ទប់ពិសោធន៍ទូទៅ និងឯកទេសប្រកបដោយបរិក្ខារពេញលេញ សម្រាប់គាំទ្រដល់ការបង្រៀន ការសិក្សា និងការស្រាវជ្រាវស្របតាមកម្មវិធីអប់រំ។
- វិទ្យាស្ថានមានផែនការយៈពេលវែង និងរយៈពេលខ្លីសម្រាប់អភិវឌ្ឍបន្ទប់ពិសោធន៍ ដែលមានស្រាប់ ។
- វិទ្យាស្ថានមានបុគ្គលិកដែលបានឆ្លងកាត់ការបណ្តុះបណ្តាលត្រឹមត្រូវ និងមានចំនួនគ្រប់គ្រាន់សម្រាប់បម្រើតម្រូវការ និងដំណើរការរបស់បន្ទប់ពិសោធន៍ ដើម្បីគាំទ្រដល់ការបង្រៀន និងការសិក្សា។
- វិទ្យាស្ថានមានគោលនយោបាយ ឬគោលការណ៍អំពីសុវត្ថិភាព និងអនុវត្តប្រកបដោយប្រសិទ្ធភាព។
- មានធនធានបច្ចេកវិទ្យា និងអ៊ីនធឺណែតគ្រប់គ្រាន់សម្រាប់គាំទ្រការសិក្សា ដោយរាប់បញ្ចូលទាំងបន្ទប់កុំព្យូទ័រសម្រាប់បម្រើតម្រូវការទូទៅ និងឯកទេសដើម្បីបំពេញតម្រូវការតាមកម្មវិធីអប់រំរបស់វិទ្យាស្ថាន។
- វិទ្យាស្ថានផ្តល់វគ្គបណ្តុះបណ្តាលសមស្របអំពីការប្រើប្រាស់ធនធានបច្ចេកវិទ្យា ដែលមានក្នុងគ្រឹះស្ថានដល់គ្រូឧទ្ទេស បុគ្គលិក និងគរុនិស្សិត ។
- វិទ្យាស្ថានមានបុគ្គលិកដែលបានឆ្លងកាត់ការបណ្តុះបណ្តាលគ្រប់គ្រាន់ សម្រាប់គាំទ្រ និងជួយសម្រួលលើផ្នែកបច្ចេកទេសគ្រប់ម៉ោងសិក្សា។

## ២.៦.៨ ស្តង់ដាទី៨៖ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

- វិទ្យាស្ថានមានធនធានរូបវន្តគ្រប់គ្រាន់ សម្រាប់បំពេញបេសកកម្ម កម្មវិធីអប់រំ សកម្មភាពផ្សេងៗរួមទាំងសកម្មភាពសិក្សា កម្មវិធីសិក្សា និងកម្មវិធីសិក្សាបន្ថែម លើការសិក្សារបស់គរុនិស្សិតដែលកំពុងសិក្សាបច្ចុប្បន្ន។
- វិទ្យាស្ថានមានបរិស្ថានប្រកបដោយផាសុកភាព និងសុវត្ថិភាពដែលបំពេញតាម លក្ខខណ្ឌស្តីពីសុវត្ថិភាព។
- បទបញ្ជា និងសេចក្តីណែនាំស្តីពីសុខភាព សុវត្ថិភាព សន្តិសុខ ត្រូវបានផ្សព្វផ្សាយ អនុវត្ត និងវាយតម្លៃជាប្រចាំ។
- វិទ្យាស្ថានមានផែនការជម្លៀសបន្ទាន់ជាក់ស្តែង ដើម្បីដោះស្រាយគ្រាមានអាសន្ន ផ្សេងៗដោយពិនិត្យបានទៀងទាត់។
- វិទ្យាស្ថានមានគោលនយោបាយ ឬគោលការណ៍សុវត្ថិភាពស្តីពីការគ្រប់គ្រង ថែរក្សា ប្រព័ន្ធព័ត៌មានអេឡិចត្រូនិចផ្លូវការរួមទាំងឃ្លាំងការពារអគ្គីភ័យ និងការថតចម្លងទុក
- វិទ្យាស្ថានមានផែនការមេធនធានរូបវ័ន្តរយៈពេលវែង រយៈពេលខ្លី សម្រាប់អភិវឌ្ឍ ធនធានរូបវន្តរបស់ខ្លួន។

## ២.៦.៩ ស្តង់ដាទី៩៖ ព័ត៌មានផ្សព្វផ្សាយ

- ឱកាសសិក្សាសម្រាប់បុគ្គលិក និងគរុនិស្សិតដែលបានចុះផ្សាយក្នុងគេហទំព័ររបស់ វិទ្យាស្ថាន និងព្រឹត្តបត្រព័ត៌មាន។
- សេចក្តីប្រកាសអំពីតម្រូវការជ្រើសរើសគ្រូឧទ្ទេស ត្រូវបានចែកផ្សាយនៅក្នុងគេហ ទំព័រ របស់ក្រសួងអប់រំ យុវជន និងកីឡា។
- ការបង្ហាញស្នាដៃស្រាវជ្រាវរបស់គ្រូឧទ្ទេស និងគរុនិស្សិតត្រូវបានចូលរួមនៅក្នុង សន្និសីទថ្នាក់ក្រោម ឬសិក្ខាសាលាស្តីពីការស្រាវជ្រាវ។
- បុគ្គលិកអប់រំ និងគរុនិស្សិតធ្វើការជាមួយគ្នា ដើម្បីលើកកម្ពស់សកម្មភាពអប់រំ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពរបស់វិទ្យាស្ថាន។ (វិទ្យាស្ថានគរុកោសល្យ, សេចក្តីព្រាងស្តីពីសេចក្តីណែនាំការធានាគុណភាពផ្ទៃក្នុង, ២០១៨)

## ២.៧ ប្រវត្តិ និងស្ថានភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀននៅកម្ពុជា

នៅសតវត្សទី១៩ និងពាក់កណ្ដាលទី១នៃសតវត្សទី២០ សាលាវត្តគឺជាប្រភពដ៏សំខាន់នៃប្រព័ន្ធអប់រំនៅកម្ពុជា ក៏ប៉ុន្តែសាលាវត្តទាំងនោះនៅមិនទាន់អាចផ្ដល់នូវការអប់រំតាមបែបទំនើបបាននៅឡើយទេ (ហង់ជួនណារ៉ុន, ២០១៦)។ យុទ្ធសាស្ត្ររយៈពេលវែងរបស់បារាំងក្នុងការបណ្តុះបណ្តាលធនធានមនុស្សនៅកម្ពុជានាដើមសតវត្សទី២០គឺការធ្វើទំនើបភាវូបនីយកម្មវិស័យអប់រំតាមរយៈ ការបង្កើតសាលារដ្ឋផ្លូវការបារាំង-ខ្មែរ។ បន្ទាប់ពីមានការរីកចម្រើននូវចំនួនសាលាផ្លូវការបារាំង-ខ្មែរ រដ្ឋាភិបាលអាណានិគមបារាំងបានបង្កើតសាលាគរុកោសល្យមួយនៅក្នុងសាលាអនុវិទ្យាល័យព្រះស៊ីសុវត្ថិ ដែលគេហៅថាឧបសម្ព័ន្ធអនុវិទ្យាល័យព្រះស៊ីសុវត្ថិ សម្រាប់បណ្តុះបណ្តាលគ្រូបង្រៀនថ្នាក់បឋមសិក្សាតាមអនុក្រឹត្យចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩២២។ បេក្ខជនដែលប្រឡងជាប់ចូលរៀននៅសាលាឧបសម្ព័ន្ធអនុវិទ្យាល័យព្រះស៊ីសុវត្ថិ ត្រូវមានអាយុមិនលើសពី២០ឆ្នាំឡើយ (សម្រាប់សិស្សខ្មែរ) ចំពោះសិស្សវៀតណាមវិញគឺត្រឹមអាយុ១៨ឆ្នាំ ហើយការសិក្សាគឺមានរយៈពេល៤ឆ្នាំ (យ៉ង ធី និងស៊ិនសំណាង, ១៩៩៨)។ នៅឆ្នាំ១៩៣៥ អគ្គទេសាភិបាលបារាំងបានសម្រេចកែប្រែរយៈពេលបណ្តុះបណ្តាលគរុសិស្សដូចជា គរុសិស្សទាំងអស់ត្រូវរៀនរយៈពេល៤ឆ្នាំ ហើយត្រូវរៀបចំប្រឡងយកសញ្ញាបត្របឋមសិក្សាជាន់ខ្ពស់តែមួយមុខប៉ុណ្ណោះ ប៉ុន្តែត្រូវរៀនមុខវិជ្ជាគរុកោសល្យមួយឆ្នាំ នៅឆ្នាំទី៥ ហើយនៅដំណាច់ឆ្នាំ គរុសិស្សត្រូវប្រឡងយកប្រកាសនីយប័ត្រគរុកោសល្យសម្បទា។ ប្រសិនបើគរុសិស្សណាធ្លាក់ មិនជាប់ប្រកាសនីយប័ត្រគរុកោសល្យនេះទេ នោះនឹងត្រូវតែងតាំងជាគ្រូជំនួយនៅពេលចេញទៅបម្រើការងារ (យ៉ង ធី និងស៊ិនសំណាង, ១៩៩៨) ។

នៅឆ្នាំ១៩៤២ ផ្នែកគរុវិជ្ជាបានបែកចេញពីវិទ្យាល័យព្រះស៊ីសុវត្ថិ ហើយត្រូវបង្កើតជាសាលាគរុកោសល្យដាច់ដោយឡែកដែលមានរយៈពេលរៀន៥ឆ្នាំដដែល។ នៅខែកក្កដា ឆ្នាំ១៩៥៩ សាលាគរុកោសល្យបានប្រែក្លាយជាវិទ្យាស្ថានជាតិគរុកោសល្យវិញ តាមព្រះរាជក្រមលេខ៤៣៨ នស ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៥៩ (យ៉ង ធី និងស៊ិនសំណាង, ១៩៩៨)។ ក្រៅពីវិទ្យាស្ថានជាតិគរុកោសល្យ នៅមានមជ្ឈមណ្ឌលអប់រំគ្រូបង្រៀនមួយចំនួនទៀតដូចជា មណ្ឌលអប់រំគ្រូនៅកំពង់កន្ទួតបង្កើតឡើងនៅឆ្នាំ១៩៥៧ មណ្ឌលអប់រំគ្រូទន្លេបាទីបង្កើតឡើងនៅឆ្នាំ១៩៦៥ មានតួនាទីសម្រាប់បណ្តុះបណ្តាលគ្រូបឋមសិក្សា (ជា សោភារី និងហ៊ុយ ស៊ីវន, ២០០៧)។

ឆ្នាំ១៩៦៥ វិទ្យាស្ថានជាតិគរុកោសល្យបានប្រែឈ្មោះជាមហាវិទ្យាល័យ ទទួលបន្ទុកបណ្តុះបណ្តាលគ្រូបង្រៀនកម្រិត១ (គ្រូបង្រៀននៅបឋមសិក្សា) និងគ្រូបង្រៀនកម្រិត២ (គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិ)។ នៅឆ្នាំ១៩៧០រដ្ឋាភិបាលបានបង្កើតសាលាគរុកោសល្យមួយទៀតនៅទីក្រុងភ្នំពេញឈ្មោះថា សាលាគរុវិជ្ជាជាន់ខ្ពស់ទទួលបន្ទុកបណ្តុះបណ្តាលគ្រូបង្រៀនកម្រិត៣ (គ្រូបង្រៀននៅវិទ្យាល័យ) (ជា សោភារី និងហ៊ុយ ស៊ីវន, ២០០៧) ។

ចាប់ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ប្រទេសកម្ពុជាត្រូវបានដឹកនាំដោយពួកផ្តាច់ការប៉ុលពត។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងៗត្រូវបានបំផ្លិចបំផ្លាញស្ទើរគ្មានសល់។

ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ វិស័យអប់រំកម្ពុជាត្រូវបានរៀបចំ និងស្តារឡើងវិញ ដោយមានគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនសំខាន់ពីរគឺមហាវិទ្យាល័គរុកោសល្យ និងសាលាគរុវិជ្ជាជាន់ខ្ពស់។ មហាវិទ្យាល័យគរុកោសល្យពេលនោះមានឈ្មោះថាសាលាគរុកោសល្យ និងវិក្រឹត្យការមជ្ឈឹម បន្ទាប់មកមានឈ្មោះថាសាលាជាន់ខ្ពស់កម្មាភិបាលគ្រប់គ្រងអប់រំ សម្រាប់បណ្តុះបណ្តាលកម្មាភិបាលគ្រប់គ្រងអប់រំ។ បច្ចុប្បន្នសាលានេះមានឈ្មោះថា វិទ្យាស្ថានជាតិអប់រំ ចំណែកឯសាលាគរុវិជ្ជាជាន់ខ្ពស់វិញមានតួនាទីបណ្តុះបណ្តាលគ្រូបង្រៀនមធ្យមសិក្សាកម្រិត២ (គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិ) និងគ្រូបង្រៀនមធ្យមសិក្សាកម្រិត៣ (គ្រូបង្រៀននៅវិទ្យាល័យ) បច្ចុប្បន្នសាលានេះមានឈ្មោះថាសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៣)។ ដោយមានការយកចិត្តទុកដាក់ខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនគ្រប់ភូមិកម្រិតសិក្សាត្រូវបានបង្កើតឡើង និងមានភារកិច្ចដូចជា៖

- សាលាគរុកោសល្យ និងវិក្រិតការមជ្ឈឹមបានបង្កើតឡើងនៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ ១៩៧៩ សព្វថ្ងៃនេះមានឈ្មោះថាវិទ្យាស្ថានជាតិអប់រំ មានភារកិច្ច៖

១. បណ្តុះបណ្តាលគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិរយៈពេលពីរឆ្នាំ ផ្នែកឯកទេសផ្សេងៗតាមរយៈការជ្រើសរើសដោយប្រឡងថ្នាក់ជាតិ ក្នុងចំណោមសិស្សមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។

២.បណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តមតាមរូបមន្តបរិញ្ញាបត្រ+១ រយៈពេលបណ្តុះបណ្តាលមួយឆ្នាំ ជ្រើសរើសតាមការប្រឡងថ្នាក់ជាតិក្នុងចំណោមអ្នកមានសញ្ញាបត្រចេញ

ពីសាកលវិទ្យាល័យ ឬវិទ្យាស្ថាននានា ដើម្បីក្លាយជាគ្រូបង្រៀនរបស់រដ្ឋតាមគម្រោងផែនការរបស់ក្រសួង និងគ្រូបង្រៀនឯកជនតាមរយៈការបង់ថ្លៃសេវាសិក្សា (អនុក្រឹត្យលេខ០៤ អនកប្រកចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៤)។

- សាលាគរុកោសល្យ និងវិក្រឹតការរាជធានី/ខេត្ត ត្រូវបានបង្កើតឡើងនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៩ សម្រាប់វិក្រឹតការគ្រូបង្រៀនរយៈពេលខ្លី នៅតាមរាជធានី/ខេត្ត ក្រោយមកទើបមានសេចក្តីសម្រេចអនុញ្ញាត ឱ្យបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតសិក្សាទី១ រយៈពេលវែងនៅឆ្នាំ១៩៨៣ ហើយសព្វថ្ងៃមានភារកិច្ចបណ្តុះបណ្តាលគ្រូបឋមសិក្សា។

-មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ បានបង្កើតឡើងនៅឆ្នាំ១៩៨៥មានភារកិច្ចបណ្តុះបណ្តាលគ្រូបង្រៀនមធ្យមសិក្សាកម្រិតទី២ (គ្រូមធ្យមសិក្សាបឋមភូមិ)

- មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែង បានបង្កើតឡើងនៅឆ្នាំ១៩៨៤ មានភារកិច្ចបណ្តុះបណ្តាលគ្រូបង្រៀនបឋមសិក្សានៅខេត្តភូមិភាគឥសាន។

- សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹមបានបង្កើតឡើងនៅឆ្នាំ១៩៨៥ មានភារកិច្ចបណ្តុះបណ្តាលគ្រូបង្រៀនមត្តេយ្យសិក្សា។

សព្វថ្ងៃយើងមានគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនចំនួន**២៤** ដែលកំពុងដំណើរការបណ្តុះបណ្តាល និងផ្គត់ផ្គង់គ្រូបង្រៀននៅគ្រប់កម្រិតភូមិសិក្សាទូទាំងប្រទេស ក្នុងនោះសាលាគរុកោសល្យនិងវិក្រិតការខេត្តចំនួន**១៦** មជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួន**០៤** សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹមចំនួន**០១** វិទ្យាស្ថានជាតិអប់រំចំនួន**០១** និងវិទ្យាស្ថានគរុកោសល្យរាជធានី/ខេត្តចំនួន**០២** (វិទ្យាស្ថានគរុកោសល្យ, ផែនការអនុវត្តកម្មវិធីអប់រំ, ២០១៨) ដែលបានដំណើរការបណ្តុះបណ្តាលគ្រូបង្រៀនគ្រប់កម្រិតភូមិសិក្សាតាមរូបមន្តផ្សេងៗជាបន្តបន្ទាប់៖

- សម្រាប់ប្រព័ន្ធបណ្តុះបណ្តាលគ្រូបឋមសិក្សាមានរូបមន្ត ៧+១/៣+១ រូបមន្ត ៧+១/៥+១ រូបមន្ត៨+១/៤+១ រូបមន្ត ៨+១/៥+៣ រូបមន្ត៨+២ រូបមន្ត ១១+២/៧+១ រូបមន្ត១២+២/៩+២ និងសព្វថ្ងៃ១២+២/១២+៤

- សម្រាប់ប្រព័ន្ធបណ្តុះបណ្តាលគ្រូមធ្យមសិក្សាបឋមភូមិមានរូបមន្ត ៩+១ រូបមន្ត ៧+៣ រូបមន្ត ៨+៣ រូបមន្ត ១១+២ រូបមន្ត ១២+២ និងសព្វថ្ងៃតាមរូបមន្ត១២+២/១២+៤

- សម្រាប់ប្រព័ន្ធបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិមានរូបមន្ត ១០+៣ រូបមន្ត ១០+៤, រូបមន្ត ១១+៣ និងសព្វថ្ងៃតាមរូបមន្តបរិញ្ញា+១

- សម្រាប់ប្រព័ន្ធបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាមានរូបមន្ត ៨+១ រូបមន្ត ១១+១ រូបមន្ត ១២+១/៩+២ និងសព្វថ្ងៃតាមរូបមន្ត១២+២។ (នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ, ប្រព័ន្ធធានាគុណភាពការងារបណ្តុះបណ្តាលគ្រូបង្រៀន, ២០១៣)។

ក្នុងពេលបច្ចុប្បន្នយើងសង្កេតឃើញថាសញ្ញាបត្រ ដែលទទួលបានក្រោយពីបញ្ចប់ការបណ្តុះបណ្តាលដោយជោគជ័យ នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូទាំង៤កម្រិតមានដូចជាគ្រូមត្តេយ្យសិក្សា គ្រូបឋមសិក្សា (១២+២) និងគ្រូកម្រិតឧត្តមនៅមិនទាន់មានបញ្ជាក់ថាសញ្ញាទាំងនោះមានតម្លៃស្មើ ឬសមមូលនឹងសញ្ញាបត្រអ្វីមួយនៅឡើយទេ គឺមានតែគ្រូកម្រិតមូលដ្ឋាន (១២+២) ដែលសញ្ញាបត្រមានតម្លៃស្មើ ឬសមមូលនឹងសញ្ញាបត្របរិញ្ញាបត្ររង ហើយគ្រូបឋមសិក្សា (១២+៤) និងគ្រូមធ្យមសិក្សាបឋមភូមិ (១២+៤) មានតម្លៃស្មើ ឬសមមូលនឹងសញ្ញាបត្របរិញ្ញាបត្រ (វិទ្យាស្ថានគរុកោសល្យ, ផែនការអនុវត្តកម្មវិធីអប់រំ, ២០១៨)។

# ជំពូកទី៣៖ វិធីសាស្ត្រនៃការស្រាវជ្រាវ

នៅក្នុងជំពូកនេះ នឹងធ្វើការបង្ហាញអំពីរបៀបនៃការស្រាវជ្រាវ ឧបករណ៍ស្រាវជ្រាវ វិធីទាំងមូលក្នុងការប្រមូលទិន្នន័យ វិភាគទិន្នន័យ លក្ខណៈរបស់ភាគសំណាក និងក្រមសីលធម៌ក្នុងការចុះប្រមូលទិន្នន័យ។

## ៣.១ ការរៀបចំការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ នឹងអនុវត្តក្នុងទម្រង់ជាករណីសិក្សានៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងវិទ្យាស្ថានគរុកោសល្យបាត់ដំបង។ ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវដែលបានបញ្ជាក់ក្នុងជំពូកទី១ការសិក្សានេះត្រូវបានប្រើប្រាស់វិធីសាស្ត្រពីរប្រភេទក្នុងការចុះប្រមូលទិន្នន័យគឺ ការសិក្សាតាមបែបបរិមាណវិស័យ(Quantitative Method) និងតាមបែបគុណវិស័យ (Qualitative Method) ឬហៅម្យ៉ាងទៀតថាវិធីចម្រុះ (Mixed Methods)។ Creswell និង Plano បានអះអាងថា វិធីចម្រុះមានឥទ្ធិពលណាស់ក្នុងការសិក្សា ពីព្រោះវិធីនេះធ្វើឱ្យអ្នកសិក្សាយល់ស៊ីជម្រៅជាងការប្រើប្រាស់វិធីតែមួយប្រភេទ (Creswell, 2014)។

## ៣.២ ឧបករណ៍ស្រាវជ្រាវ

ចំពោះឧបករណ៍ស្រាវជ្រាវវិញ អ្នកស្រាវជ្រាវបានរៀបចំបង្កើតជាកម្រងសំណួរដែលមានលក្ខណៈជាទម្រង់បិទ និងទម្រង់បើកសម្រាប់ឱ្យក្រុមគោលដៅធ្វើការបំពេញ និងឆ្លើយសំណួរទៅតាមការយល់ឃើញរបស់ពួកគេ។ កម្រងសំណួរនេះជាប្រភេទ Likert Scale (ពីកម្រិត១ដល់៥៖ ១.មិនយល់ស្របទាំងស្រុង ២.មិនយល់ស្រប ៣.ធម្មតា ៤.យល់ស្រប និង៥.យល់ស្របទាំងស្រុង) កម្រងសំណួរនេះត្រូវបានដកស្រង់ និងកែសម្រួលចេញពីស្តង់ដាធានាគុណភាពផ្ទៃក្នុងរបស់វិទ្យាស្ថានគរុកោសល្យ ស្តង់ដាស្តីពីការគ្រប់គ្រងតាមសាលារៀន(SBM) ស្តង់ដាទទួលស្គាល់គុណភាពឧត្តមសិក្សា និងយកតាមលំនាំកម្រងសំណួរវាយតម្លៃលទ្ធផលសិក្សា របស់គរុនិស្សិតនៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញផងដែរ។ កម្រងសំណួរទាំងនោះមានបីប្រភេទដូចជា៖ទី១.កម្រងសំណួរសម្ភាសន៍សម្រាប់គណៈគ្រប់គ្រង ប្រធាន/អនុប្រធានការិយាល័យ ទី២.កម្រងសំណួរបំពេញសម្រាប់ប្រធាន/អនុប្រធានដេប៉ាតឺម៉ង់ គ្រូឧទ្ទេស និងទី៣.កម្រងសំណួរបំពេញសម្រាប់គរុនិស្សិត។ នៅក្នុងកម្រងសំណួរនីមួយៗអ្នកស្រាវជ្រាវបានបែងចែកដូចតទៅ៖

- **កម្រងសំណួរសម្រាប់សម្ភាសន៍គណៈគ្រប់គ្រងប្រធាន/អនុប្រធានការិយាល័យមាន ៤សំណួរ៖**

  ១.ការយល់ឃើញរបស់អ្នកចូលរួមចំពោះការអនុវត្តកម្មវិធីបណ្តុះបណ្តាលបរិញ្ញាបត្រអប់រំ។

  ២. បញ្ហាប្រឈមនានាក្នុងដំណើរការអនុវត្តកម្មវិធីបណ្តុះបណ្តាល។

  ៣.ថវិកាគាំទ្រវិទ្យាស្ថានកន្លងមកថាតើគ្រប់គ្រាន់ឬទេ? បានមកពីប្រភពណាខ្លះ? និងមានបញ្ហាពាក់ព័ន្ធនឹងរឿងថវិកានេះដែរឬទេ?

  ៤.មតិផ្សេងៗរបស់អ្នកចូលរួមសម្រាប់រយៈពេលខាងមុខ ថាតើវិទ្យាស្ថានត្រូវមានផែនការអ្វីខ្លះដើម្បីជំរុញការងារបណ្តុះបណ្តាលឱ្យមានភាពរលូន និងអភិវឌ្ឍន៍។

- **កម្រងសំណួរបំពេញសម្រាប់ប្រធាន/អនុប្រធានដេប៉ាតឺម៉ង់ គ្រូឧទ្ទេសមានបីផ្នែក**

**ផ្នែកទី១៖** ព័ត៌មានទូទៅរបស់អ្នកចូលរួម (សំណាក) មានដូចជា ភេទ និងឋានៈ។

**ផ្នែកទី២៖** ដំណើរការអនុវត្តកម្មវិធីបណ្តុះបណ្តាល ដែលមាន៧ចំណុចធំៗដូចជា ការងារគ្រប់គ្រងនិងដឹកនាំ គុណភាពបុគ្គលិកអប់រំ កម្មវិធីសិក្សា គុណភាពគរុនិស្សិត ការបង្រៀននិងរៀន ធនធានសិក្សា និងធនធានរូបវន្តដែលទាក់ទងទៅនឹងវិទ្យាស្ថាន។

**ផ្នែកទី៣៖** មតិយោបល់របស់អ្នកចូលរួមជាទម្រង់សំណួរបើកដែលទាក់ទងទៅនឹង

- បញ្ហាប្រឈមនានារបស់ប្រធាន/អនុប្រធានដេប៉ាតឺម៉ង់ គ្រូឧទ្ទេសជួបប្រទះក្នុងអំឡុងពេលបណ្តុះបណ្តាលនៅវិទ្យាស្ថានគរុកោសល្យ។
- មតិយោបល់ផ្សេងៗរបស់ប្រធាន/អនុប្រធានដេប៉ាតឺម៉ង់ គ្រូឧទ្ទេស ដើម្បីជួយជំរុញការងារបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រនៅវិទ្យាស្ថានគរុកោសល្យឱ្យកាន់តែល្អប្រសើរ និងមានការអភិវឌ្ឍសម្រាប់រយៈពេលខាងមុខ។

- **កម្រងសំណួរបំពេញសម្រាប់គរុនិស្សិត មានបីផ្នែកគឺ៖**

  **ផ្នែកទី១៖** ពត៌មានទូទៅរបស់អ្នកចូលរួម (សំណាក) មានដូចជាភេទ និងកម្រិតបណ្តុះបណ្តាល។

  **ផ្នែកទី២៖** ដំណើរការអនុវត្តកម្មវិធីបណ្តុះបណ្តាលដែលមានចំណុចមួយចំនួនដូចជាការងារគ្រប់គ្រងនិងដឹកនាំ គុណភាពគ្រូឧទ្ទេស កម្មវិធីសិក្សា គុណភាពគរុនិស្សិត ការបង្រៀននិងរៀន ធនធានសិក្សា និងធនធានរូបវន្តដែលទាក់ទងទៅនឹងវិទ្យាស្ថាន។

**ផ្នែកទី៣៖** មតិយោបល់របស់អ្នកចូលរួមជាទម្រង់សំណួរបើកដែលទាក់ទងទៅនឹង

- បញ្ហាប្រឈមនានាដែលគរុនិស្សិតបានជួបប្រទះ ក្នុងអំឡុងពេលទទួលការបណ្តុះបណ្តាលនៅវិទ្យាស្ថានគរុកោសល្យ។
- មតិយោបល់របស់គរុនិស្សិតដើម្បីជួយជំរុញការងារបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រនៅវិទ្យាស្ថានគរុកោសល្យឱ្យកាន់តែល្អប្រសើរ និងមានការអភិវឌ្ឍសម្រាប់រយៈពេលខាងមុខ។

## ៣.៣ ការប្រមូលទិន្នន័យ

### ក.ទំហំនៃភាគសំណាក និងមុខសញ្ញាដែលត្រូវប្រមូលទិន្នន័យ

ទំហំភាគសំណាកដែលអ្នកស្រាវជ្រាវជ្រើសរើសយកមកធ្វើការស្រាវជ្រាវរួមមាន៖ គណៈគ្រប់គ្រងចំនួន**០៨រូប** ប្រធាន/អនុប្រធានការិយាល័យចំនួន**៦រូប** គ្រូឧទ្ទេសបង្រៀនបរិញ្ញាបត្រអប់រំ១២+៤ចំនួន**៤៨រូប** និងគរុនិស្សិត១២+៤ចំនួន**២៤៦** រូប។ ការជ្រើសរើសអ្នកចូលរួមមកធ្វើជាភាគសំណាក ត្រូវធ្វើឡើងដោយប្រើប្រាស់កម្មវិធី Taro Yamane ដើម្បីធ្វើការជ្រើសរើសទំហំសំណាកឱ្យមានលក្ខណៈច្បាស់លាស់ដោយប្រើរូបមន្ត $n=\frac{N}{1+N(e)2}$។ ចំពោះការជ្រើសរើសទំហំសំណាក Sample Size for Frequency in a Population (n) គឺប្រើតាមកម្មវិធីសមាមាត្រ (Propotion) ដោយមានការបង្ហាញពីកម្រិតនៃភាពជឿជាក់ (Confidence Levels) រហូតទៅដល់៩៥% និងមានកម្រិតលំអៀងត្រឹមតែ ០.៥% ប៉ុណ្ណោះ។

**តារាងទី៣៖ ចំនួនសំណាកដែលត្រូវបានជ្រើសរើសក្នុងសិក្សាស្រាវជ្រាវ**

| ល.រ | សំណាកដែលត្រូវបានជ្រើសរើស | វិ.គរុ.រាជធានីភ្នំពេញ | | វិ.គរុ.បាត់ដំបង | | សរុប | | %នៃចំនួនសំណាកសរុប |
|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | |
| ១ | គណៈគ្រប់គ្រង | ៥ | ១ | ៣ | ១ | ៨ | ២ | ៣% |
| ២ | ប្រធាន/អ.ការិយាល័យ | ៣ | ១ | ៣ | ០ | ៦ | ១ | ២% |
| ៣ | ប្រធាន/អនុ.ដេ.តីម៉ង់ និងគ្រូឧទ្ទេស | ២៥ | ៦ | ២៣ | ៥ | ៤៨ | ១១ | ១៥% |
| ៤ | គរុនិស្សិតកម្រិតបឋមសិក្សា | ៧៥ | ៤៩ | ៧៥ | ៥៣ | ១៥០ | ១០២ | ៤៩% |
| ៥ | គរុនិស្សិតកម្រិតមូលដ្ឋាន | ៤៦ | ២០ | ៥០ | ៣៣ | ៩៦ | ៥៣ | ៣១% |
| **សរុប** | | **១៥៤** | **៧៧** | **១៥៤** | **៩២** | **៣០៨** | **១៦៩** | **១០០%** |

### ខ. ការសិក្សាសាកល្បង

មុនពេលចុះប្រមូលទិន្នន័យពិតប្រាកដ អ្នកស្រាវជ្រាវបានធ្វើការសិក្សាសាកល្បងក្នុងទម្រង់តូចមួយ ដោយធ្វើការជ្រើសរើសសំណាកដូចជា អនុប្រធានការិយាល័យ០១នាក់ គ្រូឧទ្ទេសចំនួន០២នាក់ គរុនិស្សិតកម្រិតបឋមសិក្សាចំនួន១០នាក់ និងគរុនិស្សិតកម្រិតមធ្យមសិក្សាបឋមភូមិចំនួន១០នាក់ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ដើម្បីសម្ភាសជាមួយអនុប្រធានការិយាល័យ ព្រមស្នើឱ្យគ្រូឧទ្ទេស និងគរុនិស្សិតជួយបំពេញនូវកម្រងសំណួរ ជាទម្រង់សាកល្បង។ គោលបំណងនៃការសម្ភាស និងការសាកល្បងកម្រងសំណួរនេះគឺដើម្បីធានាអំពីប្រសិទ្ធិភាព និងភាពពិតប្រាកដនៃកម្រងសំណួរថា តើអាចយកមកប្រមូលទិន្នន័យជាក់ស្តែងបានដែរឬទេ។ ក្នុងការសាកល្បងនេះ អ្នកស្រាវជ្រាវបានរកឃើញថាកម្រងសំណួរដែលបានចងក្រងមុនដំបូងនៅមានចំណុចខ្វះខាតខ្លះៗ ដូចជាសំណួរខ្លះមិនចាំបាច់ កម្រងសំណួរនៅមិនទាន់អាចឆ្លើយតបច្រើនទាក់ទងនឹងប្រធានបទ ពាក្យគន្លឹះខ្លះៗ អ្នក

ចូលរួមពិបាកយល់ន័យ។ ក្រោយពីការសាកល្បងរួចអ្នកស្រាវជ្រាវបានបានទទួលនូវគំនិតយោបល់ និងព័ត៌មានត្រលប់ល្អៗជាច្រើនសម្រាប់ធ្វើការកែតម្រូវលើឧបករណ៍ស្រាវជ្រាវនេះ។ អ្នកស្រាវជ្រាវក៏យកបញ្ហាទាំងនោះទៅពិភាក្សាជាមួយសាស្ត្រាចារ្យដឹកនាំ ដើម្បីទទួលបានយោបល់ត្រលប់បន្ថែមក្នុងការកែលម្អកម្រងសំណួរឡើងវិញ ដោយអ្នកសិក្សាស្រាវជ្រាវបានធ្វើការកែតម្រូវនូវចំណុចមួយចំនួនដូចជា លុបចោលនូវសំណួរមិនចាំបាច់ និងបន្ថែមនូវសំណួរដែលចាំបាច់ ព្រមទាំងបញ្ជាក់ពីអត្ថន័យនៃពាក្យគន្លឹះដែលមានក្នុងកម្រងសំណួរដើម្បីឱ្យសំណាកងាយយល់ និងអាចឆ្លើយតបទៅនឹងប្រធានបទដែលបានលើកឡើង។ ក្រោយពីទទួលបានការណែនាំ ឯកភាពពីគ្រូដឹកនាំ និងគ្រូដឹកនាំរងរួចមក អ្នកស្រាវជ្រាវក៏ចាប់ផ្តើមចុះប្រមូលទិន្នន័យតែម្តង។

## ៣.៤ ដំណាក់កាលនៃការប្រមូលទិន្នន័យ

ក្រោយពីទទួលបានការឯកភាពពីសាស្ត្រាចារ្យដឹកនាំ និងដឹកនាំរងព្រមទាំងទទួលបានលិខិតអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា លេខ១៨៨៥ អយក.វជអ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ និងលិខិតឧទ្ទេសនាមពីឯកឧត្តមនាយកវិទ្យាស្ថានជាតិអប់រំតាមរយៈលិខិតអនុញ្ញាតលេខ ១១៩ វជអ.ផក ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩ ស្នើទៅគណៈគ្រប់គ្រងនៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងវិទ្យាស្ថានគរុកោសល្យបាត់ដំបង ដើម្បីជួយសម្រួលដល់ការចុះស្រាវជ្រាវប្រមូលទិន្នន័យនៅវិទ្យាស្ថានគរុកោសល្យទាំងពីរតែម្តង ដើម្បីសុំការសហការក្នុងការសម្ភាសជាមួយគណៈគ្រប់គ្រង ប្រធាន/អនុប្រធានការិយាល័យ ប្រធាន/អនុប្រធានដេប៉ាតឺម៉ង់ ព្រមទាំងការបំពេញកម្រងសំណួររបស់គ្រូឧទ្ទេស និងគរុសិស្ស។

## ៣.៥ ការវិភាគទិន្នន័យ

ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវទី១ ដែលទាក់ទងទៅនឹងស្ថានភាពបច្ចុប្បន្នរបស់វិទ្យាស្ថានគរុកោសល្យទាំងពីរ ក្នុងការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំថាមានលក្ខណៈបែបណា អ្នកស្រាវជ្រាវបានធ្វើការវិភាគទិន្នន័យតាមបែបបរិមាណវិស័យដោយប្រើជាប្រភេទ Scoring Likert Scale Based (កម្រិត១ដល់៥)។ ទិន្នន័យតាមបែបបរិមាណវិស័យត្រូវបានប្រមូលមកពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ (គ្រូឧទ្ទេសបង្រៀន ១២+៤ និងគរុសិស្ស១២+៤ជំនាន់ទី១)។ ជាដំបូងអ្នកសិក្សាស្រាវជ្រាវបានធ្វើការវិភាគដាច់ដោយឡែកពីគ្នាទៅតាមប្រភេទសំណាកនីមួយៗ បន្ទាប់មកអ្នកស្រាវជ្រាវបានសំយោគ

បញ្ចូលគ្នាដោយផ្តោតសំខាន់ទៅលើផ្នែកនីមួយៗនៃកម្រងសំណួរ។ ត្រង់ចំណុចនេះអ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្មវិធីSPSS សម្រាប់ស្វែងរកកម្រិតពិន្ទុជាមធ្យម(Mean) គម្លាតស្តង់ដា (Standard deviation) លំដាប់ថ្នាក់ (compute veriable) និងកម្មវិធីMicrosoft Excel សម្រាប់សង់តារាងក្នុងការបកស្រាយព័ត៌មាន។

ការវាយតម្លៃត្រូវធ្វើឡើងដោយផ្អែកលើសៀវភៅត្រួតពិនិត្យ តាមដាន និងវាយតម្លៃកម្មវិធីសិក្សារបស់វិទ្យាស្ថានគរុកោសល្យ ដែលការវាយតម្លៃនេះមានដូចជា៖

- ពិន្ទុ៤.០០ឬខ្ពស់ជាងគឺ**ល្អណាស់** មិនមានអ្វីត្រូវយកចិត្តទុកដាក់
- ពិន្ទុទាបជាង៤.០០ប៉ុន្តែធំជាងឬស្មើ៣.៥០គឺ**ល្អ** មិនមានអ្វីត្រូវយកចិត្តទុកដាក់ទេ
- ពិន្ទុក្រោម៣.៥០ប៉ុន្តែធំជាងឬស្មើ៣.០០គឺជាចំណុចដែល**ត្រូវយកចិត្តទុកដាក់**
- ពិន្ទុក្រោម៣.០០ មានន័យថា**មិនគ្រប់គ្រាន់**។ (វិទ្យាស្ថានគរុកោសល្យ, ត្រួតពិនិត្យតាមដាននិងវាយតម្លៃកម្មវិធីសិក្សា, ២០១៨)

ស្របគ្នានេះដែរដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវទី២ ដែលទាក់ទងទៅនឹងបញ្ហាប្រឈមនានារបស់វិទ្យាស្ថានគរុកោសល្យទាំងពីរ ក្នុងការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំ អ្នកស្រាវជ្រាវបានធ្វើការវិភាគទិន្នន័យតាមបែបសំណួរបើក។ នៅក្នុងការវិភាគតាមបែបសំណួរបើកនេះ ជាដំបូងអ្នកស្រាវជ្រាវបានស្រង់យកនូវបញ្ហាប្រឈមនានារបស់សំណាកនីមួយៗមកបង្ហាញ បន្ទាប់មកចាប់ជាក្រុមទៅតាមប្រភេទបញ្ហាប្រឈមធំៗ និងតាមប្រភេទសំណាកទើបធ្វើការសន្និដ្ឋានរួមទៅលើបញ្ហាប្រឈមទាំងនោះ។ ដោយផ្អែកលើចម្លើយដែលបានមកពីការបំពេញកម្រងសំណួរបូករួមទាំងព័ត៌មានដែលបានមកពីការសម្ភាសជាមួយគណៈគ្រប់គ្រងប្រធាន/អនុប្រធានការិយាល័យ ប្រធាន/អនុប្រធានដេប៉ាតឺម៉ង់ គ្រូឧទ្ទេសបង្រៀន១២+៤ និងគរុនិស្សិត១២+៤ ជំនាន់ទី១ ការវិភាគនេះគឺបានធ្វើឡើងដោយប្រើវិធីសាស្រ្តវិភាគទិន្នន័យតាមបែបគុណវិស័យ។

## ៣.៦ លក្ខណៈរបស់គំរូសំណាក

បច្ចុប្បន្នកម្មវិធីបណ្តុះបណ្តាលនៅវិទ្យាស្ថានគរុកោសល្យទាំងពីរគឺ មានលក្ខណៈដូចគ្នាគឺ បណ្តុះបណ្តាលគរុសិស្ស១២+២ (គរុសិស្សទាំងផ្នែកបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិត្រូវរៀនរយៈពេលពីរឆ្នាំដូចគ្នា ហើយសញ្ញាបត្រដែលទទួលបានមានតម្លៃស្មើនឹងបរិញ្ញាបត្ររងដូចគ្នា) និងគរុនិស្សិត១២+៤ (គរុស្សិតទាំងផ្នែកបឋមសិក្សា និងមធ្យម

សិក្សាបឋមភូមិត្រូវរៀនរយៈពេលបួនឆ្នាំដូចគ្នា សញ្ញាបត្រដែលទទួលបានមានតម្លៃស្មើនឹងបរិញ្ញាបត្រអប់រំ)។

## ក. វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ

វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៧៣អនក្រ.ប្រក ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដំឡើងកម្រិតបណ្តុះបណ្តាល និងបញ្ចូលមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ និងសាលាគរុកោសល្យនិងវិក្រឹតការរាជធានីភ្នំពេញទៅជាវិទ្យាស្ថានគរុកោល្យរាជធានីភ្នំពេញ។ ការប្រែក្លាយនេះគឺត្រូវរំសាយ និងរំលាយរចនាសម្ព័ន្ធរបស់អង្គភាពទាំងពីរទៅជាអង្គភាពតែមួយ រចនាសម្ព័ន្ធគ្រប់គ្រងតែមួយផងដែរ។

- **ទីតាំង៖** វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញមានទីតាំងស្ថិតនៅផ្លូវ២៧១ ភូមិទី១១ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ។
- **ស្ថានភាពបុគ្គលិក៖**
  ក្នុងឆ្នាំសិក្សា២០១៨- ២០១៩ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញមាន៖
  បុគ្គលិកសរុបចំនួន ១៤៧នាក់ ក្នុងនោះស្រីមានចំនួន ៦២នាក់ ចែកចេញជា៖

**តារាងទី៤៖ ស្ថានភាពបុគ្គលិកនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ**

| ល.រ | បុគ្គលិកអប់រំ | កម្រិតវប្បធម៌ | | | | | | | | សរុបរួម | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ម.សិក្សាទុតិយភូមិ | | បរិញ្ញាបត្រ | | បរិញ្ញាបត្រជាន់ខ្ពស់ | | បណ្ឌិត | | | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | គណៈគ្រប់គ្រង | ០០ | ០០ | ០០ | ០០ | ០៣ | ០១ | ០២ | ០០ | ០៥ | ០១ |
| ២ | បុគ្គ.ការិ. | ១១ | ០៦ | ០៧ | ០២ | ១៤ | ០៣ | ០០ | ០០ | ៣២ | ១១ |
| ៣ | គ្រូឧទ្ទេស | ០៧ | ០២ | ៥៥ | ២៩ | ៤៧ | ១៩ | ០០ | ០០ | ១០៩ | ៥០ |
| **សរុបរួម** | | | | | | | | | | **១៤៧** | **៦២** |

- **ស្ថានភាពគរុសិស្ស- គរុនិស្សិត**

ក្នុងឆ្នាំសិក្សា២០១៨-២០១៩វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបឋមសិក្សា និងគ្រូបង្រៀនកម្រិតមូលដ្ឋានដែលរួមមាន៖

➢ **ការបណ្តុះបណ្តាលគ្រូបឋមសិក្សា**

- ការបណ្តុះបណ្តាលគ្រូបឋមសិក្សា១២+២ ឆ្នាំទី២មាន០៤ថ្នាក់ ដែលមានគរុសិស្សចំនួន៩២នាក់ (ស្រី៥៧នាក់ ប្រុស៣៥នាក់) មកពីរាជធានីភ្នំពេញ និងខេត្តកោះកុង។ ឆ្នាំទី១មាន០២ថ្នាក់ដែលមានចំនួន៥០នាក់ (ស្រី៣២នាក់ ប្រុស១៨នាក់) ជូនរាជធានីភ្នំពេញ និងខេត្តកោះកុង។
- ការបណ្តុះបណ្តាលគ្រូកម្រិតបឋម១២+៤ គរុនិស្សិតដែលបានប្រឡងចូលសិក្សាមានចំនួន១៤៩នាក់ស្មើនឹង០៦ថ្នាក់ (ស្រី៩៤នាក់ ប្រុស៥៥នាក់) ជូនរាជធានីភ្នំពេញ ខេត្តកោះកុង កំពង់ចាម ត្បូងឃ្មុំ ក្រចេះ ព្រៃវែង ស្វាយរៀង កណ្តាល កំពង់ស្ពឺ តាកែវ កំពត កែប ព្រះសីហនុ ស្ទឹងត្រែង រតនៈគីរី មណ្ឌលគីរី ព្រះវិហារ កំពង់ឆ្នាំង និងកំពង់ធំ។

➢ **ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋាន**

- ការបណ្តុះបណ្តាលគ្រូកម្រិតមូលដ្ឋាន១២+២ ឆ្នាំទី២មាន០៦ថ្នាក់ ដែលមានគរុសិស្សចំនួន៩៦នាក់ (ស្រី៥៣នាក់ ប្រុស៤៣នាក់) មកពីខេត្តស្ទឹងត្រែង ព្រះវិហារ កោះកុង រតនៈគីរី និងមណ្ឌលគីរី។ ឆ្នាំទី១មានចំនួន០៦ថ្នាក់ត្រូវជា៥៦នាក់ (ស្រី៣៥នាក់ ប្រុស២១នាក់) ជូនខេត្តស្ទឹងត្រែងព្រះវិហារ កោះកុង រតនៈគីរី និងមណ្ឌលគីរី។
- ការបណ្តុះបណ្តាលគ្រូកម្រិតបឋមសិក្សា១២+៤ គរុនិស្សិតដែលបានប្រឡងចូលសិក្សាមានចំនួន១០០នាក់ជូន១៣រាជធានី/ខេត្ត៖ រាជធានីភ្នំពេញ ខេត្តកណ្តាល កោះកុង កំពង់ស្ពឺ កំពង់ចាម ត្បូងឃ្មុំ ក្រចេះ ព្រៃវែង ស្វាយរៀង តាកែវ កំពត ព្រះសីហនុ និងកែប។

### ខ. វិទ្យាស្ថានគរុកោសល្យបាត់ដំបង

វិទ្យាស្ថានគរុកោសល្យបាត់ដំបងត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ៧២ អនក្រ.ប្រក ចុះថ្ងៃទី២២ខែឧសភាឆ្នាំ២០១៧ ស្តីពីការដំឡើងកម្រិតបណ្តុះបណ្តាល និង

បញ្ចូលមជ្ឈមណ្ឌលគរុកោសល្យភូមិភាគបាត់ដំបង និងសាលាគរុកោសល្យនិងវិក្រឹតការខេត្តបាត់ដំបងទៅជាវិទ្យាស្ថានគរុកោល្យបាត់ដំបង។

ការប្រែក្លាយនេះគឺត្រូវរំសាយ និងរំលាយរចនាសម្ព័ន្ធរបស់អង្គភាពទាំងពីរទៅជាអង្គភាពតែមួយ រចនាសម្ព័ន្ធគ្រប់គ្រងតែមួយផងដែរ។

- **ទីតាំងវិទ្យាស្ថានគរុកោសល្យបាត់ដំបងមានពីរទីតាំងគឺ៖**

**ទីតាំងទី១៖** នៅភូមិរំចេក៤ ឃុំរតនៈ ស្រុកបាត់ដំបង ខេត្តបាត់ដំបង (ទល់មុខវិទ្យាល័យនេតយ៉ង់) ដែលមានផ្ទៃដី**៥០ ២៧០**ម៉ែតការេ អគារសិក្សាចំនួន០៤ បន្ទប់សិក្សាចំនួន១៧បន្ទប់ ការិយាល័យចំនួន០៤ បន្ទប់ប្រជុំ០១ បណ្ណាល័យ០១ បន្ទប់ពិសោធន៍០១ បន្ទប់រោងជាង០១ បន្ទប់ព័ត៌មានវិទ្យា០៣ និងអន្តេវាសិកដ្ឋានចំនួន០២។

**ទីតាំងទី២៖** នៅភូមិអូរខ្ចាយ ឃុំព្រែកព្រះស្តេច ស្រុកបាត់ដំបង ខេត្តបាត់ដំបង ដែលមានផ្ទៃដីចំនួន១១ ៦៨១ម៉ែត្រការ៉េ មានអគារសិក្សាចំនួន០៨ បន្ទប់សិក្សាចំនួន១៨ បន្ទប់ ការិយាល័យចំនួន០៧ បន្ទប់ប្រជុំមួយ បណ្ណាល័យ០១ បន្ទប់ពិសោធន៍០២ រោងជាង ០១ បន្ទប់ព័ត៌មានវិទ្យា០១ និងគ្មានអន្តេវាសិកដ្ឋានទេ។

**តារាងទី៥៖ ស្ថានភាពបុគ្គលិកនៅវិទ្យាស្ថានគរុកោសល្យបាត់ដំបង**

| តួនាទី | ក្របខណ្ឌ | | | | | | សរុប | |
|---|---|---|---|---|---|---|---|---|
| | គ្រូកម្រិតឧត្តម | | គ្រូម.បឋមភូមិ | | គ្រូបឋមសិក្សា | | សរុប | ស្រី |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | | |
| នាយក | ០១ | ០០ | ០០ | ០០ | ០០ | ០០ | ០១ | ០០ |
| នាយក/នាយិកា រង | ០៣ | ០១ | ០០ | ០០ | ០០ | ០០ | ០៣ | ០១ |
| ប្រ.ការិ/ដេ.តឺម៉ង់ | ០៦ | ០១ | ០០ | ០០ | ០០ | ០០ | ០៦ | ០១ |
| អនុការិ/ដេ.តឺម៉ង់ | ១២ | ០៥ | ០៦ | ០០ | ០០ | ០០ | ១៨ | ០៥ |
| បុគ្គ.ការិ/ដេ.តឺម៉ង់ | ០៣ | ០០ | ១០ | ០៥ | ០៤ | ០៣ | ១៧ | ០៨ |
| បណ្ណារក្ស | ០០ | ០០ | ០២ | ០២ | ០០ | ០០ | ០២ | ០២ |
| គ្រូឧទ្ទេស | ៤១ | ១៥ | ១០ | ០៤ | ០០ | ០០ | ៥១ | ១៩ |
| **សរុបរួម** | ៦៦ | ២២ | ២៨ | ១១ | ០៤ | ០៣ | **៩៨** | **៣៦** |

- **ស្ថានភាពគរុសិស្ស គរុនិស្សិត ៖**

ក្នុងឆ្នាំសិក្សា២០១៨- ២០១៩ វិទ្យាស្ថានគរុកោសល្យបាត់ដំបង បណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបឋមសិក្សា និងកម្រិតមូលដ្ឋានដែលរួមមាន៖

➢ **ការបណ្តុះបណ្តាលគ្រូបឋមសិក្សា**

- ការបណ្តុះបណ្តាលគ្រូបឋមសិក្សា១២+២ ឆ្នាំទី២ មាន០៦ថ្នាក់ ដែលមានគរុសិស្សចំនួន១៥៧នាក់មកពីខេត្តបាត់ដំបង និងប៉ៃលិន។ ឆ្នាំទី១មានចំនួន៦០នាក់មកពីខេត្តបាត់ដំបង។
- ការបណ្តុះបណ្តាលគ្រូកម្រិតបឋម១២+៤ គរុនិស្សិតដែលបានប្រឡងចូលសិក្សាមានចំនួន១៥០នាក់ជូនខេត្តបាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងពោធិ៍សាត់។

➢ **ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋាន**

- ការបណ្តុះបណ្តាលគ្រូកម្រិតមូលដ្ឋាន១២+២ ឆ្នាំទី២មាន០៧ថ្នាក់ ដែលមានគរុសិស្សចំនួន១៩៨នាក់មកពីខេត្តពោធិ៍សាត់ បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងប៉ៃលិន។ ឆ្នាំទី១មានចំនួន៧៨នាក់ មកពីខេត្តបាត់ដំបងពោធិ៍សាត់ បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងប៉ៃលិន។
- ការបណ្តុះបណ្តាលគ្រូកម្រិតបឋម១២+៤ គរុនិស្សិតដែលបានប្រឡងចូលសិក្សាមានចំនួន១០០នាក់ជូន១២ខេត្ត/ក្រុងដូចជា៖ បាត់ដំបង ពោធិ៍សាត់ បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ ប៉ៃលិន កំពង់ឆ្នាំង រតនៈគីរី ស្ទឹងត្រែង មណ្ឌលគីរី ព្រះវិហារ និងកំពង់ធំ។

**តារាងទី៦៖ ឋានៈ និងកម្រិតបណ្តុះបណ្តាលនៃភាគសំណាក**

| ភាគសំណាក | ចំនួន |
|---|---|
| គ្រូឧទ្ទេស | ២២ |
| គ្រូឧទ្ទេសរង | ២៤ |
| គ្រូឧទ្ទេសជំនួយ | ២ |
| គរុនិស្សិតកម្រិតមូលដ្ឋាន | ៩៦ |
| គរុនិស្សិតកម្រិតបឋមសិក្សា | ១៥០ |
| **សរុប** | **២៩៤** |

## ៣.៧. ក្រមសីលធម៌នៃការស្រាវជ្រាវ

អ្នកសិក្សាស្រាវជ្រាវតែងយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើក្រមសីលធម៌ក្នុងការចុះស្រាវជ្រាវពីព្រោះ វាមានសារៈសំខាន់ណាស់ក្នុងការធានានូវប្រសិទ្ធភាពនៃការស្រាវជ្រាវក៏ដូចជាការបង្កើននូវទំនុកចិត្ត និងភាពជឿជាក់ដល់អ្នកចូលរួមផ្តល់ចម្លើយសម្រាប់ប្រើប្រាស់នៅក្នុងកិច្ចការស្រាវជ្រាវនេះ។ មុនពេលចុះទៅប្រមូលទិន្នន័យនៅវិទ្យាស្ថានគោលដៅទាំងពីរអ្នកសិក្សាស្រាវជ្រាវ បានទទួលលិខិតអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា លេខ១៨៨៥ អយក.វជអ និងលិខិតអនុញ្ញាតពីវិទ្យាស្ថានជាតិអប់រំលេខ១១៩ វជអ.ផក ដែលកំពុងសិក្សាយកទៅប្រគល់ជូនលោកនាយកវិទ្យាស្ថាន និងគណៈគ្រប់គ្រងនៃវិទ្យាស្ថានគរុកោសល្យទាំងពីរ ដើម្បីសុំការអនុញ្ញតឱ្យពួកគាត់ជួយសម្រួល និងសុំកិច្ចសហការពីពួកគាត់មុនពេលចុះធ្វើការប្រមូលទិន្នន័យ ដោយឱ្យសំណាកបំពេញកម្រងសំណួរ និងផ្តល់បទសម្ភាសន៍ក្នុងការចុះសិក្សាស្រាវជ្រាវនេះ។ ការធ្វើបែបនេះបានធ្វើឱ្យអ្នកសិក្សាស្រាវជ្រាវមានទំនុកចិត្តក្នុងការប្រមូលទិន្នន័យរបស់ខ្លួនដោយស្របច្បាប់ និងពេញចិត្ត។ ពេលចុះប្រមូលទិន្នន័យអ្នកស្រាវជ្រាវតែងតែបានធ្វើការណែនាំខ្លួនជាមុន និងប្រាប់ពីគោលបំណងនៃការស្រាវជ្រាវ រយៈពេលសុំសម្ភាស ការសន្យាលើលក្ខខណ្ឌមួយចំនួនដូចជារក្សាការសម្ងាត់ជូនពួកគាត់ ហើយព័ត៌មានដែលទទួលបាននឹងមិនយកទៅប្រើប្រាស់ក្នុងគោលបំណងផ្សេងទៀតឡើយ ពេលនោះអ្នកផ្តល់ចម្លើយក៏បានយល់នូវគោលបំណងរបស់អ្នកសិក្សាស្រាវជ្រាវ ហើយអ្នកស្រាវជ្រាវក៏រំពឹងដែរថានឹងទទួលបាននូវចម្លើយ ឬព័ត៌មានដែលពិតពីអ្នកចូលរួមផងដែរ។

# ជំពូកទី៤៖ លទ្ធផលស្រាវជ្រាវ

នៅក្នុងជំពូកនេះអ្នកស្រាវជ្រាវនឹងបង្ហាញអំពីលទ្ធផលនៃការស្រាវជ្រាវ ស្ដីពីស្ថានភាពបច្ចុប្បន្នរបស់វិទ្យាស្ថានគរុកោសល្យទាំងពីរ បញ្ហាប្រឈម មតិដើម្បីជំរុញការងារបណ្តុះបណ្តាលឱ្យកាន់តែល្អប្រសើរ និងមានការអភិវឌ្ឍសម្រាប់រយៈពេលខាងមុខ តាមរយៈការបំពេញកម្រងសំណួរ ការសម្ភាសន៍ និងការសង្កេតនៅតាមផ្នែកនីមួយៗនៃកម្រងសំណួរ។

**៤.១ លទ្ធផលការស្រាវជ្រាវសំណួរទី១៖ ស្ថានភាពបច្ចុប្បន្នរបស់ វិទ្យាស្ថានគរុកោសល្យទាំងពីរក្នុងការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំ**

**តារាងទី៧៖ ការងារគ្រប់គ្រង និងដឹកនាំ (N= ២៩៥)**

| ល.រ | ខ្លឹមសារ | មធ្យម | គម្លាតស្តង់ដា | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| ១ | នាយកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់និងសមស្របភារកិច្ចដែលខ្លួនទទួលខុសត្រូវ | ៤.១៧ | 0.៦១៩ | ល្អណាស់ | **១** |
| ២ | នាយករង/នាយិការងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងសមស្របភារកិច្ចដែលខ្លួនទទួលខុសត្រូវ | ៤.១១ | 0.៦០៥ | ល្អណាស់ | **២** |
| ៣ | វិទ្យាស្ថានមានរចនាសម្ព័ន្ធច្បាស់លាស់បង្ហាញពីសិទ្ធិអំណាច និងទំនាក់ទំនងការងារក្នុងវិទ្យាស្ថាន | ៣.៩០ | 0.៧១៦ | ល្អ | **៣** |
| ៤ | ការអភិវឌ្ឍរបស់វិទ្យាស្ថានមានសង្គតិភាពជាមួយនឹងចក្ខុវិស័យ បេសកកម្ម និងគោលដៅដែលបានកំណត់ | ៣.៨៥ | 0.៧៣៩ | ល្អ | **៤** |
| ៥ | បុគ្គ.ការិយាល័យសិក្សា ការិ.ធានាគុណភាពផ្ទៃក្នុង និងដេ.តឺម៉ង់មានគុណវុឌ្ឍិសមត្ថភាពនិងបទពិសោធស្របនឹងភារកិច្ចដែលខ្លួនទទួលខុសត្រូវ | ៣.៨១ | 0.៦៩៦ | ល្អ | **៥** |
| **សរុប** | | **៣.៩៧** | **0.៥០៥** | **ល្អ** | |

តាមតារាងខាងលើបង្ហាញថាចំណុចដែលទាក់ទងនឹងការងារគ្រប់គ្រង និងដឹកនាំក្នុងវិទ្យាស្ថានក្នុងពេលបច្ចុប្បន្នគឺ អ្នកចូលរួមយល់ឃើញថាចំណុចទី១.នាយកមានសមត្ថភាពគ្រប់គ្រាន់ និងសមស្របនឹងភារកិច្ចដែលពួកគាត់ទទួលខុសត្រូវដែល (M=៤.១៧) មានន័យថាល្អណាស់ រីឯចំណុចទី២.ទាក់ទងនឹងគុណសម្បត្តិនាយករង/នាយិការងក្នុងកម្រិត (M=៤.១១) មានន័យថាល្អណាស់ ចំណុចទី៣.ទាក់ទងនឹងរចនាសម្ព័ន្ធគ្រប់គ្រងក្នុងវិទ្យាស្ថាន (M=៣.៩០) មានន័យថាល្អ នៅចំណុចទី៤.សង្គតិភាពរបស់វិទ្យាស្ថានជាមួយនឹងចក្ខុវិស័យ បេសកកម្ម និងគោលដៅដែលបានកំណត់ (M=៣.៨៥) មានន័យថាល្អ និងចំណុចទី៥.គុណសម្បត្តិរបស់បុគ្គលិករដ្ឋបាល ការិយាល័យសិក្សា ការិយាល័យធានាគុណភាពផ្ទៃក្នុង និងដេប៉ាតឺម៉ង់ (M=៣.៨១) មានន័យថាល្អ ដែលចំណុចរងទាំង៥នេះមិនមានអ្វីត្រូវយកចិត្តទុកដាក់ទេ។

សរុបមកអ្នកស្រាវជ្រាវអាចសន្និដ្ឋានជារួមថា ស្ថានភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំនៅវិទ្យាស្ថានគរុកោសល្យទាក់ទងនឹងការងារគ្រប់គ្រង និងដឹកនាំវិទ្យាស្ថានក្នុងពេលបច្ចុប្បន្នគឺស្ថិតក្នុងកម្រិត (M=៣.៩៧) មានន័យថាល្អ មិនមានអ្វីដែលត្រូវយកចិត្តទុកដាក់លើចំណុចនេះទេ បើយោងតាមទស្សនៈរបស់អ្នកចូលរួម ដែលក្នុងនោះលក្ខណៈសម្បត្តិរបស់នាយកវិទ្យាស្ថានស្ថិតក្នុងលំដាប់ទី១ រីឯលក្ខណៈសម្បត្តិរបស់នាយករង/នាយិការងស្ថិតក្នុងលំដាប់ទី២ វិទ្យាស្ថានមានរចនាសម្ព័ន្ធច្បាស់លាស់បង្ហាញពីសិទ្ធិអំណាច និងទំនាក់ទំនងការងារក្នុងវិទ្យាស្ថានស្ថិតក្នុងលំដាប់ទី៣ ការអភិវឌ្ឍរបស់វិទ្យាស្ថានមានសង្គតិភាពជាមួយនឹងចក្ខុវិស័យ បេសកកម្ម និងគោលដៅដែលបានកំណត់ស្ថិតក្នុងលំដាប់ទី៤ រីឯបុគ្គលិកការិយាល័យសិក្សា ការិយាល័យធានាគុណភាពផ្ទៃក្នុង និងដេប៉ាតឺតឺម៉ង់មានគុណវុឌ្ឍិ សមត្ថភាព និងបទពិសោធស្របនឹងភារកិច្ចដែលខ្លួនទទួលខុសត្រូវស្ថិតក្នុងលំដាប់ទី៥។

**តារាងទី៨៖ គុណភាពគ្រូឧទ្ទេស (N= ២៩៤)**

| ល.រ | ខ្លឹមសារ | មធ្យម | គម្លាតស្តង់ដា | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| ១ | គ្រូឧទ្ទេសមានគុណវុឌ្ឍិ និងបទពិសោធន៍សមស្របទៅនឹងមុខជំនាញឯកទេស និងកម្រិតនៃភារកិច្ចការងាររបស់ពួកគាត់ | ៣.៩១ | 0.៧៨៣ | ល្អ | **១** |
| ២ | គ្រូឧទ្ទេសមានចំនួនច្រើនគ្រប់គ្រាន់ក្នុងការធានាប្រសិទ្ធភាពនៃការបង្រៀន ណែនាំគរុនិស្សិត និងការអនុវត្តនៅក្នុងវិទ្យាស្ថាន | ៣.២៩ | ១.០៣៩ | ត្រូវយកចិត្តទុកដាក់ | **៣** |
| ៣ | គ្រូឧទ្ទេសមានសមត្ថភាពឆ្លើយតបទៅនឹងតម្រូវការរបស់គរុ.ទាក់ទងនឹងកាបង្រៀន និងរៀន | ៣.៨៤ | 0.៧៨១ | ល្អ | **២** |
| **សរុប** | | **៣.៦៨** | **0.៧0២** | **ល្អ** | |

យោងតាមតារាងខាងលើបង្ហាញថាចំណុចដែលទាក់ទងនឹងគុណភាពគ្រូឧទ្ទេសគឺស្ថិតក្នុងកម្រិតល្អមានពីរចំណុចគឺ ចំណុចទី១.ទាក់ទងនឹងគុណវុឌ្ឍិរបស់គ្រូឧទ្ទេស (M=៣.៩១) មានន័យថាល្អ និងចំណុចទី៣.សមត្ថភាពគ្រូឧទ្ទេសក្នុងការឆ្លើយតបទៅនឹងតម្រូវការគរុនិស្សិត (M=៣.៨៤) មានន័យថាល្អ មិនមានអ្វីត្រូវយកចិត្តទុកដាក់លើចំណុចទាំងពីរនេះទេ ប៉ុន្តែត្រូវយកចិត្តទុកលើចំណុចទី២.ដែលលើកឡើងពីចំនួនគ្រូឧទ្ទេសក្នុងការធានាប្រសិទ្ធភាពនៃការបង្រៀននិងរៀនគឺ (M=៣.២៩) តែប៉ុណ្ណោះមានន័យថាគណៈគ្រប់គ្រង និងអ្នកពាក់ព័ន្ធត្រូវយកចិត្តទុកដាក់លើចំណុចនេះ។

សរុបមកអ្នកស្រាវជ្រាវអាចសន្និដ្ឋានជារួមថា ស្ថានភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំនៅវិទ្យាស្ថានគរុកោសល្យទាក់ទងនឹងគុណភាពគ្រូឧទ្ទេសគឺមានពីរចំណុចដែលអ្នកចូលរួមយល់ថាល្អមិនមានអ្វីត្រូវយកចិត្តទុកដាក់គឺគុណវុឌ្ឍិនិងសមត្ថភាពរបស់គ្រូឧទ្ទេស ប៉ុន្តែត្រូវយកចិត្តទុកដាក់លើចំនួនគ្រូឧទ្ទេសព្រោះមិនទាន់អាចឆ្លើយតបទៅនឹងតម្រូវការរបស់វិទ្យាស្ថាននៅឡើយទេ ទោះលទ្ធផលជារួម (M=៣.៦៨) មានន័យថាល្អក៏ដោយ។

**តារាងទី៩៖ កម្មវិធីសិក្សា (N= ២៩៥)**

| ល.រ | ខ្លឹមសារ | មធ្យម | គម្លាតស្តង់ដា | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| ១ | វិទ្យាស្ថានមានគណៈកម្មាធិការអភិវឌ្ឍកម្មវិធីសិក្សា ដែលប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព | ៣.៧២ | 0.៧២២ | ល្អ | ៣ |
| ២ | កម្មវិធីសិក្សាមានលក្ខណៈស្របតាមគោលនយោបាយជាតិ ក្របខណ្ឌគុណវុឌ្ឍិជាតិ ឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់សង្គម និងបំណិនសតវត្សរ៍២១ | ៣.៨៥ | 0.៧៥ | ល្អ | ១ |
| ៣ | មុខវិជ្ជានីមួយៗក្នុងកម្មវិធីសិក្សាមានការសសេរកម្មវិធីសិក្សាលម្អិតច្បាស់លាស់ដោយផ្អែកលើសៀវភៅគោលសៀវភៅយោង គេហទំព័រ និងឯកសារផ្សេងៗទៀត | ៣.៦៥ | 0.៨៩៦ | ល្អ | ៦ |
| ៤ | គ្រប់កម្មវិធីអប់រំមានការពិពណ៌នាច្បាស់លាស់អំពីលទ្ធផលសិក្សារបស់គរុនិស្សិត ដោយបញ្ជាក់ពី ចំណេះដឹង ជំនាញ និងឥរិយាបថ ដែលគរុនិស្សិតនឹងទទួលបាន | ៣.៧១ | 0.៧៥៨ | ល្អ | ៥ |
| ៥ | វិទ្យាស្ថានប្រើវិធីសាស្ត្រ និងមធ្យោបាយច្រើនយ៉ាងក្នុងការវាយតម្លៃលើការសិក្សារបស់គរុនិស្សិត ដោយអនុលោមតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ | ៣.៧៣ | 0.៧៥១ | ល្អ | ២ |
| ៦ | វិទ្យាស្ថានគរុកោសល្យពិនិត្យ និងកែលម្អកម្មវិធីអប់រំបានទៀងទាត់ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ | ៣.៧២ | 0.៧២៨ | ល្អ | ៣ |
| **សរុប** | | **៣.៧៣** | **0.៥៥២** | **ល្អ** | |

តាមតារាងខាងលើបង្ហាញថា ចំណុចដែលទាក់ទងនឹងកម្មវិធីសិក្សាអ្នកចូលរួមបានផ្តល់ពិន្ទុជាមធ្យមគឺល្អទាំងប្រាំមួយចំណុចតែម្តងមិនមានអ្វីត្រូវយកចិត្តទុកដាក់ទេ ដែលទី១.វិទ្យាស្ថានមានគណៈកម្មាធិការអភិវឌ្ឍកម្មវិធីសិក្សាដែលប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព (M=៣.៧២) មានន័យថាល្អ ចំណែកឯទី២.កម្មវិធីសិក្សាមានលក្ខណៈស្របតាមគោលនយោបាយជាតិក្របខណ្ឌគុណវុឌ្ឍិជាតិ និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សង្គម និងបំណិននៃការរៀនសតវត្សរ៍ទី២១ (M=៣.៨៥) មានន័យថាល្អ ទី៣.មុខវិជ្ជានីមួយៗក្នុងកម្មវិធីសិក្សាមានការសសេរកម្មវិធីសិក្សាលម្អិតច្បាស់លាស់ (M=៣.៦៥) មានន័យថាល្អ ទី៤គ្រប់កម្មវិធីអប់រំមានការពិពណ៌នាច្បាស់លាស់អំពីលទ្ធផលសិក្សារបស់គរុនិស្សិត (M=៣.៧១) មានន័យថាល្អ ទី៥.វិទ្យាស្ថានប្រើវិធីសាស្ត្រ និងមធ្យោបាយច្រើនយ៉ាងក្នុងការវាយតម្លៃលើការសិក្សារបស់គរុនិស្សិត (M=៣.៧៣) មានន័យថាល្អ និងទី៦.វិទ្យាស្ថានគរុកោសល្យពិនិត្យ និងកែលម្អកម្មវិធីអប់រំបានទៀងទាត់ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ (M=៣.៧២) មានន័យថាល្អ។

សរុបមកអ្នកស្រាវជ្រាវអាចសន្និដ្ឋានជារួមថា ស្ថានភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំនៅវិទ្យាស្ថានគរុកោសល្យទាក់ទងនឹងកម្មវិធីសិក្សា អ្នកចូលរួមបានផ្តល់ពិន្ទុជាមធ្យម (M=៣.៧៣) មានន័យថាល្អមិនមានអ្វីត្រូវយកចិត្តទុកដាក់ឡើយ ដែលក្នុងនោះចំណុចដែលពិន្ទុជាមធ្យមស្ថិតក្នុងលំដាប់ទី១គឺ កម្មវិធីសិក្សាមានលក្ខណៈស្របតាមគោលនយោបាយជាតិ ក្របខណ្ឌគុណវុឌ្ឍិជាតិ ឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់សង្គម និងបំណិនសតវត្សរ៍២១ រីឯវិទ្យាស្ថានប្រើវិធីសាស្ត្រ និងមធ្យោបាយច្រើនយ៉ាងក្នុងការវាយតម្លៃលើការសិក្សារបស់គរុនិស្សិតស្ថិតក្នុងលំដាប់ទី២ វិទ្យាស្ថានមានគណៈកម្មាធិការអភិវឌ្ឍកម្មវិធីសិក្សា ដែលប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងចំណុចមួយទៀតវិទ្យាស្ថានពិនិត្យ និងកែលម្អកម្មវិធីអប់រំបានទៀងទាត់ដោយមានការចូលរួមពីភាគីពាក់ព័ន្ធស្ថិតក្នុងលំដាប់ទី៣ដូចគ្នា កម្មវិធីអប់រំមានការពិពណ៌នាច្បាស់លាស់អំពីលទ្ធផលសិក្សារបស់គរុនិស្សិតស្ថិតក្នុងលំដាប់ទី៥ និងមុខវិជ្ជានីមួយៗក្នុងកម្មវិធីសិក្សាមានការសសេរកម្មវិធីសិក្សាលម្អិតច្បាស់លាស់ស្ថិតក្នុងលំដាប់ទី៦។

**តារាងទី១០៖ គុណភាពគរុនិស្សិត (N= ២៩៤)**

| ល.រ | ខ្លឹមសារ | មធ្យម | គម្លាត ស្តង់ដា | អត្ថ ន័យ | លំដាប់ |
|---|---|---|---|---|---|
| ១ | គោលនយោបាយឬគោលការណ៍ស្តីពីការជ្រើសរើសគរុនិស្សិតចូលរៀន បានកំណត់ច្បាស់លាស់ និងអនុវត្តបានត្រឹមត្រូវ | ៤.២១ | 0.៦៤២ | ល្អ ណាស់ | ៣ |
| ២ | គរុនិស្សិតត្រូវបានជ្រើសរើសតាមរយៈការប្រឡងប្រជែង និងការត្រួតពិនិត្យម៉ត់ចត់ ដើម្បីជ្រើសរើសយកអ្នកមានសមត្ថភាពពិតប្រាកដឱ្យចូលរៀន | ៤.៥១ | 0.៥៩៤ | ល្អ ណាស់ | ១ |
| ៣ | គរុនិស្សិតចូលរៀនថ្មីនៅគ្រប់កម្រិតសញ្ញាបត្រទទួលបានការណែនាំ ឬការតម្រង់ទិសពេញលេញ | ៣.៩៤ | 0.៧៤៨ | ល្អ | ៥ |
| ៤ | វិទ្យាស្ថានបង្កើត និងធានាដំណើរការប្រព័ន្ធប្រឹក្សាយោបល់លើការសិក្សា ហើយវាយតម្លៃលើប្រព័ន្ធនោះបានទៀងទាត់ | ៣.៥៧ | 0.៧៧១ | ល្អ | ៦ |
| ៥ | គរុនិស្សិតទទួលបានឱកាសក្នុងការចូលរួមក្នុងសកម្មភាពកម្មសិក្សាគរុកោសល្យ | ៤.២៦ | 0.៦១៤ | ល្អ ណាស់ | ២ |
| ៦ | គរុនិស្សិតទទួលបានឱកាសក្នុងការចូលរួមជួយបម្រើសហគមន៍និងសកម្មភាពសង្គមផ្សេងៗ | ៣.៩៩ | 0.៧៣៤ | ល្អ | ៤ |
| **សរុប** | | **៤.0៨** | **0.៤៥៦** | **ល្អណាស់** | |

ផ្អែកតាមតារាងខាងលើបង្ហាញថាចំណុចដែលទាក់ទងនឹងគុណភាពគរុនិស្សិតអ្នកចូលរួមបានផ្តល់ពិន្ទុជាមធ្យមក្នុងកម្រិតពីរផ្សេងគ្នាគឺល្អ និងល្អណាស់ មានន័យថាមិនមានអ្វីត្រូវយកចិត្តទុកដាក់ទេ ដែលទី១.គោលនយោបាយ ឬគោលការណ៍ស្តីពីការជ្រើសរើសគរុនិស្សិត (M=៤.២១) មានន័យថាល្អណាស់ ទី២.ការប្រឡងប្រជែង និងការត្រួតពិនិត្យ

ម៉ត់ចត់ដើម្បីជ្រើសរើសយកអ្នកមានសមត្ថភាពពិតប្រាកដឱ្យចូលរៀន (M=៤.៥១) មានន័យថាល្អណាស់ទី៣.គរុនិស្សិតចូលរៀនថ្មីនៅគ្រប់កម្រិតសញ្ញាបត្រទទួលបានការណែនាំ ឬការតម្រង់ទិស ពេញលេញ (M=៣.៩៤) មានន័យថាល្អ ទី៤.ប្រព័ន្ធប្រឹក្សាយោបល់លើការសិក្សា ហើយវាយតម្លៃលើប្រព័ន្ធនោះបានទៀងទាត់ (M=៣.៥៧) មានន័យថាល្អ ទី៥. គរុនិស្សិតទទួលបានឱកាសក្នុងការចូលរួមក្នុងសកម្មភាពកម្មសិក្សាគរុកោសល្យ (M=៤.២៦) មានន័យថាល្អណាស់ និងទី៦គរុនិស្សិតទទួលបានឱកាសក្នុងការចូលរួមជួយបម្រើសហគមន៍ និងសកម្មភាព សង្គមផ្សេងៗ (M=៣.៩៩) មានន័យថាល្អ។

សរុបមកអ្នកស្រាវជ្រាវអាចសន្និដ្ឋានជារួមថា ស្ថានភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំនៅវិទ្យាស្ថានគរុកោសល្យទាក់ទងនឹងគុណភាពគរុនិស្សិតអ្នកចូលរួមបានផ្តល់ពិន្ទុជាមធ្យម (M=៤.០៨) មានន័យថាល្អណាស់មិនមានអ្វីត្រូវយកចិត្តទុកដាក់លើចំណុចទាំងនេះទេ។

**តារាងទី១១ ៖ ការបង្រៀននិងរៀន (N= ២៩៤)**

| ល.រ | ខ្លឹមសារ | មធ្យម | គម្លាតស្តង់ដា | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| ១ | ដំណើរការនៃការបង្រៀននិងរៀន និងរង្វាយតម្លៃគរុនិស្សិតត្រូវបានពិនិត្យឡើងវិញ និងវាយតម្លៃដើម្បីធានាទំនាក់ទំនងនិងការបន្ស៊ីគ្នា | ៣.៧២ | 0.៦៧៥ | ល្អ | **៤** |
| ២ | លទ្ធផលនៃការស្រាវជ្រាវត្រូវបានប្រើដើម្បីលើកកម្ពស់ការបង្រៀននិងរៀន | ៣.៩៨ | 0.៦៨៤ | ល្អ | **១** |
| ៣ | ការរៀបចំ និងការអភិវឌ្ឍកម្មវិធីសិក្សាត្រូវបានបង្កើតឡើង និងលើកជាប្រធានបទក្នុងការវាយតម្លៃ និងការជំរុញឱ្យដល់គោលដៅ | ៣.៧១ | 0.៦៩៦ | ល្អ | **៥** |
| ៤ | ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពត្រូវបានដាក់បញ្ចូលក្នុងកម្មវិធី | ៣.៨៣ | 0.៧៣៦ | ល្អ | **៣** |

| | | | | | |
|---|---|---|---|---|---|
| | សិក្សា កម្មវិធីសិក្សាលម្អិត គម្រោងមេរៀនតាមមុខវិជ្ជា និងកិច្ចតែងការបង្រៀន | | | | |
| ៥ | សកម្មភាពអប់រំសម្រាប់ការអភិវឌ្ឍការងារប្រកបដោយចីរភាពត្រូវបានលើកកម្ពស់វិទ្យាស្ថានក្នុងការធានាបរិស្ថាន នៃការបង្រៀននិងរៀនប្រកបដោយប្រសិទ្ធភាព | ៣.៨៨ | 0.៦៦១ | ល្អ | **២** |
| **សរុប** | | **៣.៨២** | **0.៥១២** | **ល្អ** | |

តាមតារាងខាងលើបង្ហាញថាចំណុចដែលទាក់ទងនឹងការបង្រៀននិងរៀនអ្នកចូលរួមបានផ្តល់ពិន្ទុជាមធ្យមគឺល្អទាំងប្រាំចំណុចតែម្តង មិនមានអ្វីត្រូវយកចិត្តទុកដាក់ទេដែលទី១.ដំណើរការនៃការបង្រៀននិងរៀន និងរង្វាយតម្លៃគរុនិស្សិតត្រូវបានពិនិត្យឡើងវិញ និងវាយតម្លៃដើម្បីធានាទំនាក់ទំនង និងការបន្សុីគ្នា (M=៣.៧២) មានន័យថាល្អ ទី២.លទ្ធផលនៃការស្រាវជ្រាវត្រូវបានប្រើដើម្បីលើកកម្ពស់ការបង្រៀននិងរៀន (M=៣.៩៨) មានន័យថាល្អ ទី៣.ការរៀបចំ និងការអភិវឌ្ឍកម្មវិធីសិក្សាត្រូវបានបង្កើតឡើង និងលើកជាប្រធានបទក្នុងការវាយតម្លៃ និងការជំរុញឱ្យដល់គោលដៅ (M=៣.៧១) មានន័យថាល្អ ទី៤.ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត គម្រោងមេរៀនតាមមុខវិជ្ជា និងកិច្ចតែងការបង្រៀន (M=៣.៨៣) មានន័យថាល្អ និងទី៥.សកម្មភាពអប់រំសម្រាប់ការអភិវឌ្ឍការងារប្រកបដោយចីរភាពត្រូវបានលើកកម្ពស់វិទ្យាស្ថាន ក្នុងការធានាបរិស្ថាននៃការបង្រៀននិងរៀនប្រកបដោយប្រសិទ្ធភាព (M=៣.៨៨) មានន័យថាល្អ។

សរុបមកអ្នកស្រាវជ្រាវអាចសន្និដ្ឋានជារួមថា ស្ថានភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំនៅវិទ្យាស្ថានគរុកោសល្យទាក់ទងនឹងការបង្រៀននិងរៀនអ្នកចូលរួមបានផ្តល់ពិន្ទុជាមធ្យម (M=៣.៨២ SD=0.៥១២) មានន័យថាល្អ មិនមានអ្វីត្រូវយកចិត្តទុកដាក់លើចំណុចទាំងនេះទេ។

**តារាងទី១២៖ ធនធានសិក្សា (N= ២៩៥)**

| ល.រ | ខ្លឹមសារ | មធ្យម | គម្លាតស្តង់ដា | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| ១ | បណ្ណាល័យមានកន្លែងអានគ្រប់គ្រាន់និងបរិយាកាសអំណោយផលដល់ការសិក្សា និងស្រាវជ្រាវ។ | ៣.៥១ | 0.៩១២ | ល្អ | **៣** |
| ២ | បណ្ណាល័យមានសៀវភៅសិក្សា ឯកសារយោង ទស្សនាវដ្ដីវិទ្យាសាស្ត្រ និងសម្ភារសិក្សាផ្សេងៗសម្រាប់គាំទ្រដល់កម្មវិធីអប់រំ | ៣.៣៦ | 0.៨៩៥ | ត្រូវយកចិត្តទុកដាក់ | **៥** |
| ៣ | បណ្ណាល័យមានបណ្ណារក្សជំនាញ បុគ្គលិកបម្រើការគ្រប់គ្រាន់ និងទទួលបានការបណ្តុះបណ្តាលផ្នែកជំនាញគ្រប់គ្រងបណ្ណាល័យ ហើយមានសមត្ថភាពបម្រើតម្រូវការរបស់គរុនិស្សិត និងគ្រូបង្រៀននៅតាមដេប៉ាតឺម៉ង់ | ៣.៥៣ | 0.៨៧៧ | ល្អ | **២** |
| ៤ | គរុនិស្សិត និងគ្រូឧទ្ទេសទទួលបានការណែនាំ ការតម្រង់ទិសអំពីរបៀបប្រើប្រាស់បណ្ណាល័យ និងធនធានសិក្សាផ្សេងៗ | ៣.៣៦ | 0.៨៥៥ | ត្រូវយកចិត្តទុកដាក់ | **៥** |
| ៥ | គរុនិស្សិត និងគ្រូឧទ្ទេសទទួលបានឱកាសក្នុងការប្រើប្រាស់ធនធានសិក្សាក្នុងប្រព័ន្ធបណ្ណាល័យទូរនិម្មិត (បណ្ណាល័យ/គេហទំព័រផ្សេងៗតាមអ៊ីនធឺណែត) សម្រាប់បំពេញតម្រូវការសិក្សា និងស្រាវជ្រាវស្របតាមកម្មវិធីអប់រំ | ៣.៤១ | 0.៨៣៦ | ត្រូវយកចិត្តទុកដាក់ | **៤** |
| ៦ | មានសម្ភារឧបទ្ទេសគ្រប់គ្រាន់ក្នុងការបង្រៀនគរុនិស្សិត | ៣.0២ | 0.៨១៥ | ត្រូវយកចិត្តទុកដាក់ | **១០** |
| ៧ | វិទ្យាស្ថានមានបន្ទប់ពិសោធន៍ទូទៅ និងឯក | ៣.១៥ | 0.៥៩៨ | ត្រូវយក | **៨** |

| | | | | | |
|---|---|---|---|---|---|
| | ទេសប្រកបដោយបរិក្ខារពេញលេញសម្រាប់គាំទ្រដល់ការបង្រៀន ការសិក្សា និងការស្រាវជ្រាវស្របតាមកម្មវិធីអប់រំ | | | ចិត្ត ទុកដាក់ | |
| ៨ | វិទ្យាស្ថានមានគ្រូឧទ្ទេស ដែលមានគុណវុឌ្ឍិសមស្រប និងមានចំនួនគ្រប់គ្រាន់សម្រាប់បម្រើតម្រូវការ និងដំណើរការរបស់បន្ទប់ពិសោធ ដើម្បីគាំទ្រដល់ការបង្រៀននិងរៀន | ៣.៣៤ | 0. ៩០៧ | ត្រូវយក ចិត្ត ទុកដាក់ | **៧** |
| ៩ | មានធនធានបច្ចេកវិទ្យា និងអ៊ីនធឺណែតគ្រប់គ្រាន់សម្រាប់គាំទ្រការសិក្សាដោយរាប់បញ្ចូលទាំងបន្ទប់កុំព្យូទ័រសម្រាប់បម្រើតម្រូវការទូទៅ និងឯកទេសដើម្បីបំពេញតម្រូវការតាមកម្មវិធីអប់រំរបស់វិទ្យាស្ថាន | ៣.១៤ | 0.៩៥ | ត្រូវយក ចិត្ត ទុកដាក់ | **៩** |
| ១០ | វិទ្យាស្ថានមានបុគ្គលិកដែលបានឆ្លងកាត់ការបណ្តុះបណ្តាលគ្រប់គ្រាន់សម្រាប់គាំទ្រនិងជួយសម្រួលលើផ្នែកបច្ចេកទេសគ្រប់ម៉ោងសិក្សា | ៣.៦៦ | 0. ៨៣៥ | ល្អ | **១** |
| **សរុប** | | **៣.៣៥** | **0.៥៩១** | **ត្រូវយកចិត្ត ទុកដាក់** | |

តាមតារាងខាងលើបង្ហាញថា ចំណុចដែលទាក់ទងនឹងធនធានសិក្សាអ្នកចូលរួមបានផ្តល់ពិន្ទុជាមធ្យមគឺល្អមានបីចំណុច និងប្រាំពីរចំណុចទៀតគឺស្ថិតក្នុងកម្រិតត្រូវយកចិត្តទុកដាក់ ដែលទី១.បណ្ណាល័យមានកន្លែងអានគ្រប់គ្រាន់ និងបរិយាកាសអំណោយផលដល់ការសិក្សា និងស្រាវជ្រាវ (M=៣.៥១) មានន័យថាល្អ ទី២.បណ្ណាល័យមានសៀវភៅសិក្សា ឯកសារយោង ទស្សនាវដ្ដីវិទ្យាសាស្រ្ត និងសម្ភារសិក្សាផ្សេងៗសម្រាប់គាំទ្រដល់កម្មវិធីអប់រំ (M=៣.៣៦) មានន័យថាត្រូវយកចិត្តទុកដាក់ ទី៣.បណ្ណាល័យមានបណ្ណារក្សជំនាញ និងបុគ្គលិកបម្រើការគ្រប់គ្រាន់ព្រមទាំងទទួលបានការបណ្តុះបណ្តាលផ្នែកជំនាញគ្រប់គ្រងបណ្ណាល័យ ហើយមានសមត្ថភាពបម្រើតម្រូវការរបស់គរុនិស្សិត និង

គ្រូបង្រៀននៅតាមដេប៉ាតឺម៉ង់ (M=៣.៥៣) មានន័យថាល្អ ទី៤.គរុនិស្សិត និងគ្រូឧទ្ទេស ទទួលបានការណែនាំ និងការតម្រង់ទិសអំពីរបៀបប្រើប្រាស់បណ្ណាល័យ និងធនធានសិក្សាផ្សេងៗ (M=៣.៣៦) មានន័យថាត្រូវយកចិត្តទុកដាក់ ទី៥.គរុនិស្សិត និងគ្រូឧទ្ទេស ទទួលបានឱកាសក្នុងការប្រើប្រាស់ធនធានសិក្សាក្នុងប្រព័ន្ធបណ្ណាល័យទូរនិម្មិត សម្រាប់បំពេញតម្រូវការសិក្សា និងស្រាវជ្រាវស្របតាមកម្មវិធីអប់រំ (M=៣.៤១) មានន័យថាត្រូវយកចិត្តទុកដាក់ ទី៦.មានសម្ភារឧបទ្ទេសគ្រប់គ្រាន់ក្នុងការបង្រៀនគរុនិស្សិត (M=៣.០២) មានន័យថាត្រូវយកចិត្តទុកដាក់ ទី៧.មានបន្ទប់ពិសោធន៍ទូទៅ និងឯកទេសប្រកបដោយបរិក្ខារពេញលេញសម្រាប់គាំទ្រដល់ការបង្រៀនការសិក្សា និងការស្រាវជ្រាវស្របតាមកម្មវិធីអប់រំ (M=៣.១៥) មានន័យថាត្រូវយកចិត្តទុកដាក់ ទី៨.មានគ្រូឧទ្ទេសដែលមានគុណវុឌ្ឍិសមស្រប និងមានចំនួនគ្រប់គ្រាន់សម្រាប់បម្រើតម្រូវការ និងដំណើរការរបស់បន្ទប់ពិសោធន៍ដើម្បីគាំទ្រដល់ការបង្រៀននិងរៀន (M=៣.៣៥) មានន័យថាត្រូវយកចិត្តទុកដាក់ ទី៩.មានធនធានបច្ចេកវិទ្យា និងអ៊ីនធឺណែតគ្រប់គ្រាន់សម្រាប់គាំទ្រការសិក្សាដោយរាប់បញ្ចូលទាំងបន្ទប់កុំព្យូទ័រសម្រាប់បម្រើតម្រូវការទូទៅ និងឯកទេស (M=៣.១៤) មានន័យថាត្រូវយកចិត្តទុកដាក់ និងទី១០.មានបុគ្គលិកដែលបានឆ្លងកាត់ការបណ្តុះបណ្តាលគ្រប់គ្រាន់សម្រាប់គាំទ្រ និងជួយសម្រួលលើផ្នែកបច្ចេកទេសគ្រប់ម៉ោងសិក្សា (M=៣.៦៦) មានន័យថាល្អ។

សរុបមកអ្នកស្រាវជ្រាវអាចសន្និដ្ឋានជារួមថាស្ថានភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំនៅវិទ្យាស្ថានគរុកោសល្យទាក់ទងនឹងធនធានសិក្សាអ្នកចូលរួមបានផ្តល់ពិន្ទុជាមធ្យម(M=3.35 SD=0.៥៩១) មានន័យថាគណៈគ្រប់គ្រង និងពាក់ព័ន្ធត្រូវយកចិត្តទុកដាក់លើចំណុចធនធានសិក្សានេះ។

**តារាងទី១៣៖ ធនធានរូបវន្ត (N= ២៩៥)**

| ល.រ | ខ្លឹមសារ | មធ្យម | គម្លាតស្តង់ដា | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| ១ | វិទ្យាស្ថានមានធនធានរូបវន្តគ្រប់គ្រាន់សម្រាប់បំពេញបេសកកម្ម កម្មវិធីអប់រំ សកម្មភាពផ្សេងៗរួមទាំងសកម្មភាពសិក្សា កម្មវិធីសិក្សា និងកម្មវិធីសិក្សាបន្ថែមលើការសិក្សារបស់គរុនិស្សិតដែលកំពុងសិក្សាបច្ចុប្បន្ន | ៣.៣១ | 0.៨២ | ត្រូវយកចិត្តទុកដាក់ | **៣** |
| ២ | វិទ្យាស្ថានមានបរិស្ថានប្រកបដោយផាសុកភាព និងសុវត្ថិភាពដែលបំពេញតាមលក្ខខណ្ឌស្តីពីសុវត្ថិភាព | ៣.៤៥ | 0.៨៩៥ | ត្រូវយកចិត្តទុកដាក់ | **១** |
| ៣ | មានអន្តេវាសិកដ្ឋាន និងសម្ភារៈគ្រប់គ្រាន់សម្រាប់គរុនិស្សិតស្នាក់នៅ | ២.៦២ | ១.0៥៤ | មិនគ្រប់គ្រាន់ | **៤** |
| ៤ | វិទ្យាស្ថានមានផែនការមេធនធានរូបវន្តរយៈពេលវែង រយៈពេលខ្លីសម្រាប់អភិវឌ្ឍធនធានរូបវន្តរបស់ខ្លួន | ៣.៤១ | 0.៧៧៤ | ត្រូវយកចិត្តទុកដាក់ | **២** |
| **សរុប** | | **៣.២0** | **0.៦១៥** | **ត្រូវយកចិត្តទុកដាក់** | |

តាមតារាងខាងលើបង្ហាញថា ចំណុចដែលទាក់ទងនឹងធនធានរូបវន្តអ្នកចូលរួមបានផ្តល់ពិន្ទុជាមធ្យមក្នុងកម្រិតពីរគឺ ត្រូវយកចិត្តទុកដាក់ និងមិនគ្រប់គ្រាន់ដែលទី១.មានធនធានរូបវន្តគ្រប់គ្រាន់ (M=៣.៣១) មានន័យថាត្រូវយកចិត្តទុកដាក់ ទី ២.មានបរិស្ថានប្រកបដោយផាសុកភាព និងសុវត្ថិភាព (M=៣.៤៥) មានន័យថាត្រូវយកចិត្តទុកដាក់ ទី៣.មានអន្តេវាសិកដ្ឋាន និងសម្ភារៈគ្រប់គ្រាន់សម្រាប់គរុនិស្សិតស្នាក់នៅ (M=២.៦២) មានន័យថាមិនគ្រប់គ្រាន់ និងទី៤.វិទ្យាស្ថានមានផែនការមេធនធានរូបវន្ត

រយៈពេលវែង រយៈពេលខ្លីសម្រាប់អភិវឌ្ឍធនធានរូបវន្តរបស់ខ្លួន (M=៣.៨១) មានន័យថាត្រូវយកចិត្តទុកដាក់។

សរុបមកអ្នកស្រាវជ្រាវអាចសន្និដ្ឋានជារួមថា ស្ថានភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំនៅវិទ្យាស្ថានគរុកោសល្យទាក់ទងនឹងធនធានរូបវន្តអ្នកចូលរួមបានផ្តល់ពិន្ទុជាមធ្យម (M=៣.២០ SD=0.៦១៥) មានន័យថាគណៈគ្រប់គ្រង និងអ្នកពាក់ព័ន្ធត្រូវយកចិត្តទុកដាក់លើចំណុចធនធានរូបវន្តនេះនេះ។

**តារាងទី១៥៖ សរុបរួម (N= ២៩៤)**

| ល.រ | ខ្លឹមសារ | មធ្យម | គម្លាតស្តង់ដា | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| ១ | ការងារគ្រប់គ្រងនិងដឹកនាំ | ៣.៩៧ | 0.៥០៥ | ល្អ | ២ |
| ២ | គុណភាពគ្រូឧទ្ទេស | ៣.៦៨ | 0.៧០២ | ល្អ | ៥ |
| ៣ | កម្មវិធីសិក្សា | ៣.៧៣ | 0.៥៥២ | ល្អ | ៤ |
| ៤ | គុណភាពគរុនិស្សិត | ៤.០៨ | 0.៤៥៦ | ល្អណាស់ | ១ |
| ៥ | ការបង្រៀននិងរៀន | ៣.៨២ | 0.៥១២ | ល្អ | ៣ |
| ៦ | ធនធានសិក្សា | ៣.៣៥ | 0.៥៩១ | ត្រូវយកចិត្តទុកដាក់ | ៦ |
| ៧ | ធនធានរូបវន្ត | ៣.២០ | 0.៦១៥ | ត្រូវយកចិត្តទុកដាក់ | ៧ |
| **សរុបរួម** | | **៣.៦៩** | **0.៥៦២** | **ល្អ** | |

ផ្អែកតាមតារាងនេះអ្នកស្រាវជ្រាវអាចសន្និដ្ឋានថាក្នុងចំណោមប្រាំពីរចំណុចធំៗនេះចំណុចដែលអ្នកចូលរួមយល់ថាស្ថិតក្នុងកម្រិតល្អណាស់គឺមានមួយចំណុចគុណភាពគរុនិស្សិត (M=៤.០៨ SD=0.៤៥៦) ដែលស្ថិតក្នុងលំដាប់ទី១ ហើយស្ថិតក្នុងកម្រិតល្អមាន៤ចំណុចគឺ ទី១.ការងារគ្រប់គ្រងនិងដឹកនាំ (M=៣.៩៧ SD=0.៥០៥) ដែលស្ថិតក្នុងលំដាប់ទី២ ទី៥.ការបង្រៀននិងរៀន (M=៣.៨២ SD=0.៥១២) ស្ថិតក្នុងលំដាប់ទី៣ ចំណុចទី៣.កម្មវិធីសិក្សា (M=៣.៧៣ SD=0.៥៥២) ស្ថិតក្នុងលំដាប់ទី៤ និងចំណុចទី២គុណភាពគ្រូ

ឧទ្ទេស(M=៣.៦៨ SD=0.៧០២) ស្ថិតក្នុងលំដាប់ទី៥ និងពីរចំណុចទៀតស្ថិតក្នុងកម្រិតត្រូវយចិត្តទុកដាក់គឺ ចំណុចទី៦ ធនធានសិក្សា (M=៣.៣៥ SD=0.៥៩១) ស្ថិតក្នុងលំដាប់ទី៦ និងចំណុចទី៧.ធនធានសិក្សា (M=៣.២០ SD=0.៦១៥) ស្ថិតក្នុងលំដាប់ទី៧។

សរុបមកអ្នកស្រាវជ្រាវអាចសន្និដ្ឋានថា ស្ថានភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំនៅវិទ្យាស្ថានគរុកោសល្យ ដោយផ្អែកលើការយល់ឃើញរបស់អ្នកចូលរួមគឺ ស្ថិតក្នុងកម្រិតពិន្ទុមធ្យម (M=៣.៦៩ SD=0.៥៦២) មានន័យជារួមថាល្អ ដែលក្នុងនោះល្អណាស់មានមួយចំណុចគឺគុណភាពគរុនិស្សិត កម្រិតល្អមានបួនចំណុចគឺការងារគ្រប់គ្រង ការបង្រៀននិងរៀន កម្មវិធីសិក្សានិងគុណភាពគ្រូឧទ្ទេស ហើយចំណុចដែលគណៈគ្រប់គ្រង និងអ្នកពាក់ព័ន្ធត្រូវយកចិត្តទុកដាក់គឺ ចំនួនគ្រូឧទ្ទេសបម្រើការងារក្នុងវិទ្យាស្ថាន ធនធានសិក្សានិងធនធានរូបវន្ត។ ហើយបើពិនិត្យបន្ថែមលើសូចនាទាំង ៣៩ ក្នុងកម្រងសំណួរនៃផ្នែកទាំង៧ ចំណុចដែលស្ថិតក្នុងកម្រិតមធ្យមខ្ពស់ជាងគេគឺគរុនិស្សិតត្រូវបានជ្រើសរើសតាមរយៈការប្រឡងប្រជែង និងការត្រួតពិនិត្យម៉ត់ចត់ក្នុងការជ្រើសរើសអ្នកមានសមត្ថភាពពិតប្រាកដឱ្យចូលរៀន (Mean= ៤.៥១) រីឯចំណុចដែលពិន្ទុស្ថិតក្នុងកម្រិតទាបបំផុតគឺ អន្តេវាសិកដ្ឋាន និងសម្ភារៈក្នុងអន្តេវាសិកដ្ឋាន(Mean= ២.៦២) ប៉ុណ្ណោះ។

**៤.២ លទ្ធផលការស្រាវជ្រាវសំណួរទី២៖ បញ្ហាប្រឈមនានារបស់វិទ្យាស្ថានគរុកោសល្យទាំងពីរ ក្នុងការអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំ**

**១.គណៈគ្រប់គ្រង ប្រធាន/អនុប្រធានការិយាល័យ ប្រធាន/អនុប្រធានដេប៉ាតឺម៉ង់ និងគ្រូឧទ្ទេស៖**

- **ក្របខណ្ឌកម្មវិធីសិក្សា៖** មានមតិខ្លះៗលើកឡើងថាក្របខណ្ឌកម្មវិធីសិក្សាត្រូវបានយកមកអនុត្តមានលក្ខណៈតក់ក្រហាល់ ដោយបង្កើតឡើងនៅឆ្នាំ២០១៧ ហើយត្រូវយកមកអនុវត្តនៅឆ្នាំ២០១៨តែម្តង។ ក្រសួងជាអ្នកបង្កើត និងផ្តល់ឱ្យវិទ្យាស្ថានទាំងពីរអនុវត្តតាម កំណត់មិនទាន់ច្បាស់ថាមុខវិជ្ជាណាជាមុខវិជ្ជាជម្រើសមួយណាជាមុខវិជ្ជាគោល ប៉ុន្តែគរុនិស្សិតត្រូវរៀនទាំងអស់។ ការអនុវត្តប្រព័ន្ធក្រេឌីត ជាប្រព័ន្ធថ្មីខុសពីការអនុវត្តពីអតីតកាល (គ្រូឧទ្ទេសអនុវត្តតាមប្រព័ន្ធម៉ោង) ធ្វើឱ្យអ្នកអនុវត្តយល់មិនទាន់ច្បាស់ពីប្រព័ន្ធថ្មីនេះ។

- **កម្មវិធីសិក្សាលម្អិតៈ** មានមតិជាច្រើនបានលើកឡើងថាកម្មវិធីសិក្សាលម្អិតធ្វើហើយមួយឆ្នាំ យកមកអនុវត្តមួយឆ្នាំ គ្មានពេលកែលម្អជាមុន ធ្វើបណ្ដើរ កែលម្អបណ្ដើរដូច្នេះទាំងខ្លឹមសារ និងវិធីសាស្រ្តអាចមិនទាន់ច្បាស់លាស់ល្អ។ ខ្វះអ្នកជំនាញចូលរួមជួយ គ្រូឧទ្ទេសបម្រើការនៅវិទ្យាស្ថានដែលចូលរួមធ្វើកម្មវិធីសិក្សាមិនបានបណ្ដុះបណ្ដាលជាមុនពីរបៀបធ្វើកម្មវិធីនេះ ធ្វើតាមការយល់ឃើញផ្ទាល់ខ្លួន និងត្រូវពឹងពាក់ច្រើនលើអ្នកពាក់ព័ន្ធពីខាងក្រៅ ដើម្បីចូលរួមបង្កើតកម្មវិធីសិក្សាលម្អិតនេះឡើង។
- **បរិមាណ និងគុណវុឌ្ឍិគ្រូឧទ្ទេសមិនទាន់មានគ្រប់គ្រាន់ៈ** យោងតាមមតិជាច្រើនរបស់គណៈគ្រប់គ្រង និងគ្រូឧទ្ទេសជាច្រើនបានលើកឡើងថា សមត្ថភាពគ្រូឧទ្ទេសនៅវិទ្យាស្ថានបច្ចុប្បន្ននៅមានកម្រិតនៅឡើយ (គ្រូឧទ្ទេសចាស់ចំណេះដឹងឯកទេសរបស់គាត់ខ្លះនៅមានកម្រិត មិនមានការបណ្ដុះបណ្ដាល ឬតម្រង់ទិសជាមុនពីការបង្រៀនកម្រិតឧត្ដមសិក្សា គ្រូថ្មីខ្វះបទពិសោធ) មិនទាន់អាចបង្រៀនសិស្សឱ្យមានសមត្ថភាពខ្លាំងបាន លើសពីនេះទៅទៀតបរិមាណគ្រូឧទ្ទេសមិនទាន់មានគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងវិទ្យាស្ថាននៅឡើយ។ ក្នុងនោះលោក **សិត សេង** នាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញក៏បានលើកឡើងដែរថា« ក្នុងឆ្នាំសិក្សា២០១៨-២០១៩គ្រូឧទ្ទេសនៅស្រពេចស្រពិលលើការបង្រៀននៅឡើយ ដោយប្ដូរពីបរិបទពីការបង្រៀនតាមម៉ោងទៅជាប្រព័ន្ធក្រេឌីតភ្លាមៗ មិនទាន់បានបណ្ដុះបណ្ដាលជាមុន»។
- **គ្រូឧទ្ទេសរបស់វិទ្យាស្ថានមួយចំនួនជាប់ជាគ្រូបង្គោលក្នុងគម្រោងនានារបស់ក្រសួងអប់រំ យុវជន និងកីឡាៈ** គ្រូឧទ្ទេសខ្លះត្រូវចុះបេសកកម្មក្នុងគម្រោងទាំងនោះជាប្រចាំ ច្រើនថ្ងៃក្នុង១ខែៗ ដែលធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលនៅវិទ្យាស្ថានគរុកោសល្យ។
- **លិខិតបទដ្ឋានគតិយុត្តិខ្លះមិនបានចែងច្បាស់លាស់ៈ** វិទ្យាស្ថានគរុកោសល្យជាគ្រឹះស្ថានឧត្ដមសិក្សា តែពុំទាន់លិខិតបទដ្ឋានណាមួយចែងថាគ្រឹះស្ថាននេះ មានសិទ្ធិចេញសញ្ញាបត្របរិញ្ញាបត្រអប់រំឱ្យគរុនិស្សិត ឬអត់ ម្យ៉ាងទៀតគរុនិស្សិតដែលបញ្ចប់ការបណ្ដុះនឹងទទួលបានក្របខ័ណ្ឌអ្វី ដែលមានភាពមិនច្បាស់លាស់សម្រាប់វិទ្យាស្ថានក្នុងការអនុវត្តទៅថ្ងៃខាងមុខ។

- **ការជ្រើសរើសគ្រូឧទ្ទេសថ្មីសម្រាប់បម្រើការនៅវិទ្យាស្ថានមានដំណើរការយឺតយ៉ាវៈ** ប្រើពេលយូរដើម្បីសម្រេចលទ្ធផលនៃការជ្រើសរើស ខណៈដែលវិទ្យាស្ថានកំពុងត្រូវការគ្រូឧទ្ទេសដើម្បីបំពេញការងារ លើសពីនេះទៅទៀតលោក**ជុំ សុផល** នាយកវិទ្យាស្ថានគរុកោសល្យបាត់ដំបងបានលើកឡើងថា ក្នុងឆ្នាំសិក្សា២០១៨-២០១៩ នៅវិទ្យាស្ថានគរុកោសល្យបាត់ដំបង ក្រសួង អប់រំ យុវជន និងកីឡា ប្រកាសជ្រើសរើសរើសគ្រូថ្មីចំនួន២២នាក់ បេក្ខជនដាក់ពាក្យបានតែ១១នាក់ ហើយជ្រើសរើសបានតែ០៧នាក់តែប៉ុណ្ណោះ។
- **ធនធានសិក្សា ហេដ្ឋារចនាសម្ព័ន្ធ ធនធានរូបវន្តៈ** មានការខ្វះខាត មិនអាចឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងក្នុងវិទ្យាស្ថានបាននៅឡើយ ដូចជាខ្វះសម្ភារឧបទ្ទេសសម្រាប់ការបង្រៀននិងរៀន បន្ទប់សិក្សា បន្ទប់ពិសោធន៍ Internet បរិស្ថានសិក្សាមិនទាន់សមស្របទៅនឹងគ្រឹះស្ថានឧត្តមសិក្សា។

**២.គរុនិស្សិតៈ**

គរុនិស្សិតជាច្រើនបានលើកឡើងពីបញ្ហាប្រឈមសំខាន់ៗដែលពួកគេបានជួបប្រទះក្នុងអំឡុងពេលទទួលការបណ្តុះបណ្តាល ដែលបញ្ហាទាំងនោះមានដូចជាៈ បណ្ណាល័យមិនមានឯកសារគ្រប់គ្រាន់ក្នុងការស្រាវជ្រាវ ពុំមានសៀវភៅគោលច្បាស់លាស់ កិច្ចការស្រាវជ្រាវច្រើន ខ្វះឯកសារជាភាសាជាតិ សមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសនៅមានកម្រិត គ្រូឧទ្ទេសពុំសូវមានពេលវេលាគ្រប់គ្រាន់ក្នុងការបង្រៀន គ្រូឧទ្ទេសមួយចំនួនពុំមានឯកសារត្រឹមត្រូវ ធនធានសិក្សា សម្ភារៈឧបទ្ទេស កុំព្យូទ័រ សម្ភារពិសោធន៍មានមិនគ្រប់តម្រូវការ និងមិនគ្រប់គ្រាន់ក្នុងការបង្រៀននិងរៀន ខ្វះInternetក្នុងការស្រាវជ្រាវ ខ្វះកុំព្យូទ័រប្រើប្រាស់ក្រៅម៉ោងមុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាន ធនធានរូបវន្តមិនមានគ្រប់គ្រាន់(ខ្វះអគារសម្រាប់សិក្សា ខ្វះកន្លែងស្នាក់នៅ ដោយត្រូវចំណាយលុយផ្ទាល់ខ្លួនដើម្បីជួលកន្លែងស្នាក់នៅ )។

**៤.៣ មតិដើម្បីជំរុញការងារបណ្តុះបណ្តាលឱ្យកាន់តែមានភាពល្អប្រសើរ និងមានការអភិវឌ្ឍសម្រាប់រយៈពេលខាងមុខៈ**

**១.មតិគណៈគ្រប់គ្រង ប្រធាន/អនុប្រធានដេប៉ាតឺម៉ង់/គ្រូឧទ្ទេស**

- អនុវត្តផែនការយុទ្ធសាស្ត្រ៥ឆ្នាំ (២០១៩- ២០២៣) ទាំង១០ចំណុចរបស់វិទ្យាស្ថានឱ្យមានប្រសិទ្ធភាពគឺៈ

- អភិបាលកិច្ច ការដឹកនាំ និងគ្រប់គ្រង៖ ដោយជំរុញការប្រតិបត្តិប្រកបដោយប្រសិទ្ធភាព និងគុណភាព
- ធនធានគ្រូឧទ្ទេស៖ បង្កើនចំនួនគ្រូឧទ្ទេសដែលមានគុណវុឌ្ឍិកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ឬបណ្ឌិតត្រូវឯកទេសឱ្យបានគ្រប់គ្រាន់ អភិវឌ្ឍបន្ថែមគុណវុឌ្ឍិគ្រូឧទ្ទេសដែលមានស្រាប់
- កម្មវិធីអប់រំ៖ ជំរុញការអនុវត្តក្របខណ្ឌកម្មវិធីអប់រំ កម្មវិធីសិក្សាលម្អិត ការអនុវត្តកម្មសិក្សាគរុកោសល្យ ប្រកបដោយគុណភាព និងប្រសិទ្ធិភាព
- បរិស្ថានសិក្សា៖ អភិវឌ្ឍធនធានសិក្សា ធនធានរូបវន្តដើម្បីគាំទ្រការបង្រៀននិងរៀន បង្កើតសេវានិស្សិតប្រកបដោយភាពកក់ក្តៅ និងទំនុកចិត្ត
- ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ៖ បង្កើតកម្មវិធីអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំជាប្រចាំ
- ការធានាគុណភាពផ្ទៃក្នុង៖ បង្កើតប្រព័ន្ធធានាគុណភាពផ្ទៃក្នុងឱ្យមានប្រសិទ្ធិភាព
- កិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធ៖ លើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយនឹងស្ថាប័នពាក់ព័ន្ធជាតិ តំបន់ និងអន្តរជាតិ
- ការស្រាវជ្រាវអប់រំ៖ លើកទឹកចិត្តបុគ្គលិកអប់រំដើម្បីធ្វើការស្រាវជ្រាវលើការបង្រៀននិងរៀន
- ការងារវិក្រឹតការគ្រូបង្រៀន៖ បង្កើតវិក្រឹតការដល់គ្រូកម្រិតបឋម និងមូលដ្ឋាន
- ការផ្សព្វផ្សាយស្នាដៃអប់រំ៖ លើកកម្ពស់ការផលិត និងផ្សព្វផ្សាយស្នាដៃអប់រំ

➢ ត្រូវមានប្រព័ន្ធតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងកែលម្អជាប្រចាំ

➢ ប្រែក្លាយវិទ្យាស្ថានទៅជាអង្គភាពថវិកា

**២.មតិគរុនិស្សិត**

គរុនិស្សិតក៏បានលើកឡើងផងដែរថាដើម្បីជំរុញការងារបណ្តុះបណ្តាលឱ្យកាន់តែមានភាពល្អប្រសើរ និងមានការអភិវឌ្ឍសម្រាប់រយៈពេលខាងមុខ វិទ្យាស្ថានក៏ដូចជាអ្នកពាក់ព័ន្ធគួរយកយកចិត្តទុដាក់លើចំណុចមួយចំនួនដូចជា៖ គ្រូឧទ្ទេសត្រូវមានចំនួនបានសមស្រប មានកម្រិតគុណវុឌ្ឍិសមស្របទៅនឹងកម្រិតបណ្តុះបណ្តាល បណ្ណាល័យគួរមានឯកសារឱ្យបានគ្រប់គ្រាន់ងាយស្រួលក្នុងការស្រាវជ្រាវ ផ្តល់កន្លែងស្នាក់នៅសម្រាប់គរុនិស្សិតឱ្យបានសមរម្យនិងគ្រប់គ្រាន់ ផ្តល់សេវាInternetឱ្យបានគ្រប់គ្រាន់ងាយស្រួល

ក្នុងការស្រាវជ្រាវ បង្កើនម៉ោងសិក្សាលើភាសាបរទេស និងបច្ចេកវិទ្យាពត៌មាន ផ្តល់ឯកសារជាភាសាជាតិឱ្យបានគ្រប់គ្រាន់ ធនធានសិក្សា ធនធានរូបវន្ត និងបរិស្ថានសិក្សា គួរមានឱ្យបានសមស្រប ឆ្លើយតបទៅនឹងការបង្រៀននិងរៀន ក៏ដូចជាការសិក្សានាសតវត្សរ៍ទី២១ផងដែរ។

# ជំពូក៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ

នៅក្នុងជំពូកនេះ អ្នកស្រាវជ្រាវនឹងធ្វើការបូកសរុបលទ្ធផលដែលបានរកឃើញរួចទាញជាសេចក្តីសន្និដ្ឋានរួមមួយ ស្តីអំពីស្ថានភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងវិទ្យាស្ថានគរុកោសល្យបាត់ដំបង និងបញ្ហាប្រឈមនានាដែលកើតមាននៅក្នុងវិទ្យាស្ថានទាំងពីរ។ បន្ទាប់ពីធ្វើសេចក្តីសន្និដ្ឋានរួចហើយអ្នកស្រាវជ្រាវនឹងលើកជាសំណូមពរជូនទៅដល់ភាគីពាក់ព័ន្ធនានា ដើម្បីចូលរួមចំណែកជួយគាំទ្រ និងពង្រឹងការអនុវត្តការបណ្តុះបណ្តាលគ្រូបង្រៀនបរិញ្ញាបត្រអប់រំនៅវិទ្យាស្ថានទាំងពីរឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។

## ៥.១ សេចក្តីសន្និដ្ឋាន

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះបានបង្ហាញឱ្យឃើញថា ស្ថានភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំ នៅវិទ្យាស្ថានគរុកោសល្យដោយផ្អែកលើការបំពេញកម្រងសំណួររបស់អ្នកចូលរួមថា ចំណុចដែលអ្នកចូលរួមយល់ថាស្ថិតក្នុងកម្រិតល្អណាស់គឺ មានមួយចំណុចគុណភាពគរុនិស្សិត ហើយស្ថិតក្នុងកម្រិតល្អមាន ៤ចំណុចគឺ ទី១.ការងារគ្រប់គ្រងនិងដឹកនាំ ទី២.ការបង្រៀននិងរៀន ទី៣.កម្មវិធីសិក្សា និងទី៤.គុណភាពគ្រូឧទ្ទេស និងពីរចំណុចទៀតស្ថិតក្នុងកម្រិតត្រូវយកចិត្តទុកដាក់គឺ ធនធានសិក្សានិងធនធានរូបវន្ត។ ហើយបើពិនិត្យបន្ថែមលើសូចនាទាំង៣៩ក្នុងកម្រងសំណួរនៃផ្នែកទាំង៧ចំណុចដែលស្ថិតក្នុងកម្រិតមធ្យមខ្ពស់ជាងគេគឺ គរុនិស្សិតត្រូវបានជ្រើសរើសតាមរយៈការប្រឡងប្រជែង និងការត្រួតពិនិត្យម៉ត់ចត់ក្នុងការជ្រើសរើសអ្នកមានសមត្ថភាពពិតប្រាកដឱ្យចូលរៀន (Mean=៤.៥១) រីឯចំណុចដែលពិន្ទុស្ថិតក្នុងកម្រិតទាបបំផុតគឺអន្តេវាសិកដ្ឋាន និងសម្ភារៈក្នុងអន្តេវាសិកដ្ឋាន (Mean=២.៦២) ប៉ុណ្ណោះ។

ចំពោះបញ្ហាប្រឈមដែលកើតមានក្នុងវិទ្យាស្ថានគរុកោសល្យទាំងពីរ គណៈគ្រប់គ្រង ប្រធាន/អនុប្រធានការិយាល័យ ប្រធាន/អនុប្រធានដេប៉ាតឺម៉ង់ គ្រូឧទ្ទេសបានលើកឡើងមានដូចជា ក្របខណ្ឌកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត បរិមាណ និងគុណវុឌ្ឍិគ្រូឧទ្ទេសមិនទាន់មានគ្រប់គ្រាន់និងសមស្រប គ្រូឧទ្ទេសរបស់វិទ្យាស្ថានមួយចំនួនជាប់ជាគ្រូបង្គោលក្នុងគម្រោងនានារបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលពួកគាត់ត្រូវចុះបេសកកម្មក្នុងគម្រោងទាំងនោះជាប្រចាំច្រើនថ្ងៃក្នុង១ខែៗ គ្រូឧទ្ទេសខ្លះត្រូវចូលរួមសិក្ខា

សាលាច្រើនដើម្បីធ្វើកម្មវិធីសិក្សា និងបំប៉នសមត្ថភាពបណ្ដើរធ្វើការបណ្ដើរ ដែលធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលនៅវិទ្យាស្ថាន លិខិតបទដ្ឋានគតិយុត្តិខ្លះៗមិនបានចែងច្បាស់លាស់ ការជ្រើសរើសគ្រូឧទ្ទេសថ្មីសម្រាប់បម្រើការនៅវិទ្យាស្ថានមានដំណើរការយឺតយ៉ាវ ខណៈដែលវិទ្យាស្ថានកំពុងត្រូវការគ្រូឧទ្ទេសដើម្បីបំពេញការងារ ធនធានសិក្សា ហេដ្ឋារចនាសម្ព័ន្ធ និងធនធានរូបវន្តមានការខ្វះខាតមិនអាចឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងក្នុងវិទ្យាស្ថាន រីឯគរុនិស្សិតក៏ជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនផងដែរ ដែលមានដូចជា៖ បណ្ណាល័យមិនមានឯកសារគ្រប់គ្រាន់ក្នុងការស្រាវជ្រាវ ពុំមានសៀវភៅគោលច្បាស់លាស់ ខ្វះឯកសារជាភាសាជាតិ កិច្ចការស្រាវជ្រាវច្រើនសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសនៅមានកម្រិត គ្រូឧទ្ទេសពុំសូវមានពេលវេលាគ្រប់គ្រាន់ក្នុងការបង្រៀន គ្រូឧទ្ទេសមួយចំនួនពុំមានឯកសារត្រឹមត្រូវ ធនធានសិក្សា កុំព្យូទ័រ សម្ភារពិសោធន៍ មានមិនគ្រប់តម្រូវការ និងមិនគ្រប់គ្រាន់ក្នុងការបង្រៀននិងរៀនខ្វះInternet (ត្រូវចំណាយលុយផ្ទាល់ខ្លួនដើម្បីទិញសេវា) ក្នុងការស្រាវជ្រាវ ខ្វះកុំព្យូទ័រប្រើប្រាស់ក្រៅម៉ោងមុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាន ធនធានរូបវន្តមិនមានគ្រប់គ្រាន់ (ខ្វះអគារសម្រាប់សិក្សា កន្លែងស្នាក់នៅ (ត្រូវចំណាយលុយផ្ទាល់ខ្លួនដើម្បីទៅជួលកន្លែងស្នាក់នៅខាងក្រៅ)។

ដើម្បីជំរុញ ការងារបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំនៅវិទ្យាស្ថានគរុកោសល្យឱ្យកាន់តែមានភាពល្អប្រសើរថែមទៀត អ្នកចូលរួមបានផ្តល់ជាយោបល់ដូចជា៖ អនុវត្តផែនការយុទ្ធសាស្ត្រ៥ឆ្នាំ (២០១៩- ២០២៣) ទាំង១០ចំណុចរបស់វិទ្យាស្ថានឱ្យមានប្រសិទ្ធភាព ត្រូវមានប្រព័ន្ធតាមដាន ត្រួតពិនិត្យ វាយតម្លៃនិងកែលម្អជាប្រចាំ បង្កើនចំនួនគ្រូឧទ្ទេសដែលមានគុណវុឌ្ឍិកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ឬបណ្ឌិតត្រូវឯកទេសឱ្យបានគ្រប់គ្រាន់ដោយធ្វើការជ្រើសរើសគ្រូឧទ្ទេសថ្មីដែលត្រូវនឹងឯកទេស អភិវឌ្ឍបន្ថែមគុណវុឌ្ឍិគ្រូឧទ្ទេសដែលមានស្រាប់នៅក្នុងវិទ្យាស្ថាន ប្រែក្លាយវិទ្យាស្ថានទៅជាអង្គភាពថវិកា បណ្ណាល័យគួរមានឯកសារឱ្យបានគ្រប់គ្រាន់ងាយស្រួលក្នុងការស្រាវជ្រាវ ផ្ដល់កន្លែងស្នាក់នៅឱ្យបានសមរម្យនិងគ្រប់គ្រាន់ ផ្តល់សេវាInternetឱ្យបានគ្រប់គ្រាន់ងាយស្រួលក្នុងការស្រាវជ្រាវ ធនធានសិក្សា និងធនធានរូបវន្តគួរមានឱ្យបានសមស្រប ឆ្លើយតបទៅនឹងការបង្រៀននិងរៀន ក៏ដូចជាការសិក្សានាសតវត្សរ៍ទី២១ បង្កើនម៉ោងសិក្សាលើភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មាន ផ្តល់ឯកសារជាភាសាជាតិឱ្យបានច្រើន។

សរុបមកអ្នកស្រាវជ្រាវអាចសន្និដ្ឋានជារួមថា ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំនៅវិទ្យាស្ថានគរុកោសល្យ ដោយផ្អែកលើការយល់ឃើញរបស់អ្នកចូលរួម គឺជាកម្មវិធីមួយដែលល្អ ព្រោះធ្វើឱ្យគុណវុឌ្ឍិគ្រូបង្រៀននៅប្រទេសកម្ពុជាមានមានកម្រិតស្មើឬប្រហាក់ប្រហែលប្រទេសក្នុងតំបន់ និងពិភពលោក (បរិញ្ញាបត្រឡើងទៅ) ឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណនីតិកាលទីប្រាំមួយរបស់រដ្ឋាភិបាល ដែលលើកឡើងពី ការអភិវឌ្ឍធនធានមនុស្ស ម្យ៉ាងវិញទៀតក្រោយទទួលការបណ្តុះបណ្តាលគរុនិស្សិតមានសមត្ថភាពជាប្រព័ន្ធទាំងចំណេះដឹងឯកទេស វិធីសាស្ត្របង្រៀន កម្មសិក្សាគរុកោសល្យ ការស្រាវជ្រាវបច្ចេកវិទ្យាព័ត៌មាន និងទទួលបានសញ្ញាបត្រកម្រិតបរិញ្ញាបត្រអប់រំ ហើយអាចរៀនបន្តបរិញ្ញាបត្រជាន់ខ្ពស់លើឯកទេសបានតែម្តង។ មិនតែប៉ុណ្ណោះវិទ្យាស្ថានគរុកោសល្យទាំងពីរនេះមានដំណើរការដោយរលូន ទោះបីវិទ្យាស្ថានគរុកោសល្យទាំងពីរជាវិទ្យាស្ថានដំបូងគេបង្អស់នៅប្រទេសកម្ពុជា និងជួបប្រទះនូវបញ្ហាប្រឈមខ្លះៗក៏ដោយ ក៏គណៈគ្រប់គ្រង បុគ្គលិកអប់រំ គ្រូឧទ្ទេសទាំងអស់បានខិតខំ សាមគ្គី សហការ ប្រឹងប្រែងអនុវត្តតាមតួនាទី និងភារកិច្ចរបស់ពួកគាត់រៀងៗខ្លួនដោះស្រាយបញ្ហាចំពោះមុខជាបណ្តើរៗដើម្បីឱ្យគុណភាពនៃការបណ្តុះបណ្តាលប្រកបដោយគុណភាព និងសម្រេចបាននូវកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

### ៥.២ សំណូមពរ

ដើម្បីចូលរួមចំណែកជួយបង្កើនគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំនៅវិទ្យាស្ថានគរុកោសល្យ ឱ្យកាន់តែប្រសើរឡើងប្រកបដោយគុណភាព អ្នកសិក្សាស្រាវជ្រាវបានលើកជាសំណូមពរមួយចំនួនដូចខាងក្រោម៖

**ក. ចំពោះក្រសួងអប់រំ យុវជន និងកីឡា៖**

- ធ្វើវិសោធនកម្មលិខិតបទដ្ឋានគតិយុត្តិមួយចំនួនទាក់ទងនឹងវិទ្យាស្ថានដូចជា (គរុនិស្សិតដែលបញ្ចប់ការបណ្តុះទទួលបានក្របខ័ណ្ឌអ្វី? ជាគ្រឹះស្ថានឧត្តមសិក្សា? វិទ្យាស្ថានមានសិទ្ធិចេញសញ្ញាបត្រជូនគរុនិស្សិត ឬអត់?)
- ជ្រើសរើសបុគ្គលិកអប់រំបន្ថែមឱ្យបានគ្រប់គ្រាន់ មានគុណវុឌ្ឍិសមស្រប និងបណ្តុះបណ្តាលគ្រូឧទ្ទេសដែលមានស្រាប់ឱ្យមានសមត្ថភាពឆ្លើយតបទៅនឹងតម្រូវការក្នុងវិទ្យាស្ថាន

- គួរស្វែងរកដៃគូអភិវឌ្ឍនានាដើម្បីជួយគាំទ្រលើសេវាអ៊ីនធឺណែត កុំព្យូទ័រសម្រាប់គរុនិស្សិតសិក្សាស្រាវជ្រាវ ធនធានសិក្សា និងធនធានរូបវន្តឱ្យបានគ្រប់គ្រាន់
- ប្រែក្លាយវិទ្យាស្ថានទៅជាអង្គភាពថវិកា

**ខ. ចំពោះគណៈគ្រប់គ្រងវិទ្យាស្ថានគរុកោសល្យទាំងពីរ៖**

- ធ្វើសហប្រតិបត្តិការ និងចុះអនុសារណៈជាមួយដៃគូរជាតិ និងអន្តរជាតិដើម្បីពង្រឹងបន្ថែមលើសមត្ថភាពបុគ្គលិកអប់រំ និងគរុនិស្សិត
- គួរស្វែងរកដៃគូអភិវឌ្ឍនានាដើម្បីជួយគាំទ្រលើសេវាអ៊ីនធឺណែត កុំព្យូទ័រសម្រាប់គរុនិស្សិតសិក្សាស្រាវជ្រាវ ធនធានសិក្សា និងធនធានរូបវន្តឱ្យបានគ្រប់គ្រាន់

**គ.ចំពោះគ្រឹះស្ថានបណ្តុះបណ្តាលគ្រូក្រោយៗដែលនឹងក្លាយខ្លួនទៅជាវិទ្យាស្ថានគរុកោសល្យគួរត្រៀមទៅលើចំណុចមួយចំនួនដូចជា៖**

- គណៈគ្រប់គ្រងដែលមានចំនួន និងគុណវុឌ្ឍិសមស្របក្នុងការដឹកនាំវិទ្យាស្ថាន
- ចំនួន និងគុណវុឌ្ឍិគ្រូឧទ្ទេសត្រូវមានឱ្យបានសមស្របនឹងវិទ្យាស្ថាន
- ហេដ្ឋារចនាសម្ព័ន្ធរូបវន្តគួរសង់ឱ្យបានរួចជាស្រេចមុននឹងក្លាយទៅវិទ្យាស្ថាន
- ធនធានសម្ភារៈ និងធនធានថវិកាត្រូវមានឱ្យបានគ្រប់គ្រាន់ និងប្រភពច្បាស់លាស់
- ស្វែងយល់ពីវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបងឱ្យបានស៊ីជម្រៅលើចំណុចខ្លាំង ចំណុចខ្សោយ និងបញ្ហាប្រឈម
- បង្កើតវិទ្យាស្ថានថ្មី ដោយប្រកាសជ្រើសរើសបុគ្គលិកតាមតម្រូវការ បុគ្គលិកចាស់ផ្តល់ឱកាសឱ្យគាត់ជ្រើសរើសតាមការស្ម័គ្រចិត្តថាតើត្រូវទៅធ្វើការនៅវិទ្យាស្ថាន ឬផ្លាស់ទៅបម្រើការនៅអង្គភាពផ្សេង

**ឃ. ចំពោះអ្នកស្រាវជ្រាវបន្ត ៖**

ដើម្បីឱ្យការសិក្សាលើកក្រោយៗកាន់តែមានប្រសិទ្ធភាពអ្នកសិក្សាក្រោយៗគួរតែសិក្សាពី ៖

- ប្រសិទ្ធិភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំនៅវិទ្យាស្ថានគរុកោសល្យទាំងពីរ
- ពង្រីកសំណាកបន្ថែមករណីមានវិទ្យាស្ថានបង្កើតក្រោយៗទៀត

# ឯកសារយោង

ក្រសួងអប់រំ យុវជន ក្រសួងអប់រំ យុវជន និងកីឡា. (២០១៣). *គោលនយោបាយស្តីពីគ្រូបង្រៀន.* រាជធានីភ្នំពេញ: ក្រសួងអប់រំយុវជននិងកីឡា.

ក្រសួងអប់រំយុវជននិងកីឡា. (២០១០). *ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន.* ភ្នំពេញ: នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ.

ក្រសួងអប់រំយុវជននិងកីឡា. (២០១៨). *ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន.* ភ្នំពេញ: ក្រសួងអប់រំយុវជននិងកីឡា.

ជា សោភារី និងហ៊ុយ ស៊ីវន. (២០០៧). *ការវិវត្តន៍ប្រព័ន្ធអប់រំពីសាលាវត្តមកសាលាទំនើប.* រាជធានីភ្នំពេញ.

នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ. (២០០៩). *ការគ្រប់គ្រងរដ្ឋបាល.* រាជធានីភ្នំពេញ: នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ.

នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ. (២០១៣). *ប្រព័ន្ធធានាគុណភាពការងារបណ្តុះបណ្តាលគ្រូបង្រៀន.* រាជធានីភ្នំពេញ.

នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ. (២០១៦). *ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន.* ភ្នំពេញ: ក្រសួងអប់រំយុវជននិងកីឡា.

មាសសុភឿន. (២០១៧). *ការអនុវត្តតាមស្តង់ដាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន.* រាជធានីភ្នំពេញ: មាស សុភឿន.

យ៉ង ធី និងស៊ុនសំណាង. (១៩៩៨). *ប្រវត្តិនៃការអប់រំបឋមនិងមធ្យមសិក្សានៅកម្ពុជា.* រាជធានីភ្នំពេញ.

រាជរដ្ឋាភិបាលកម្ពុជា. (២០០៨). *អនុក្រឹត្យស្ដីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន.* រាជធានីភ្នំពេញ: រាជរដ្ឋាភិបាលកម្ពុជា.

រាជរដ្ឋាភិបាលកម្ពុជា. (២០១៩). *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣.* ភ្នំពេញ: រាជរដ្ឋាភិបាលកម្ពុជា.

វិទ្យាស្ថានគរុកោសល្យ. (២០១៧). *ក្របខណ្ឌកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំ.* រាជធានីភ្នំពេញ: វិទ្យាស្ថានគរុកោសល្យ.

វិទ្យាស្ថានគរុកោសល្យ. (២០១៨). *ត្រួតពិនិត្យតាមដាននិងវាយតម្លៃកម្មវិធីសិក្សា.* ភ្នំពេញ: វិទ្យាស្ថានគរុកោសល្យ.

វិទ្យាស្ថានគរុកោសល្យ. (២០១៨). *ផែនការអនុវត្តកម្មវិធីអប់រំ.* រាជធានីភ្នំពេញ: វិទ្យាស្ថានគរុកោសល្យ.

វិទ្យាស្ថានគរុកោសល្យ. (២០១៨). *សេចក្តីព្រាងស្តីពីសេចក្តីណែនាំការធានាគុណភាពផ្ទៃក្នុង.* រាជធានីភ្នំពេញ: វិទ្យាស្ថានគរុកោសល្យ.

វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ. (២០១៨). *ផែនការយុទ្ធសាស្ត្រ២០១៩-២០២៣.* រាជធានីភ្នំពេញ: វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ.

វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ. (២០១៩, មិថុនា ០៤). *វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ.*

វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ. (២០១៩). *សៀវភៅណែនាំកម្មសិក្សាគរុកោសល្យ.* រាជធានីភ្នំពេញ: វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ.

វិទ្យាស្ថានជាតិអប់រំ. (២០១៦). *សីលធម៌វិជ្ជាជីវៈគ្រូបង្រៀន.* រាជធានីភ្នំពេញ: វិទ្យាស្ថានជាតិអប់រំ.

john W Creswell. (2014). *RESEARCH DESIGN.* United State of America: Library of Congress.

Khnie,Lourdusany&Choon. (2005).

Sermsak Wisalaporn. (2005). *Regulation of the teacher Concil of Thailand on Professinal Standard and Ethics.* Bankork.

# កម្រងសំណួរសម្រាប់គរុនិស្សិត

## សេចក្តីណែនាំ៖

នាងខ្ញុំឈ្មោះ **ឆាយ បូនី** ជាគ្រូឧទ្ទេស នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ បច្ចុប្បន្នកំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ **ជំនាន់ទី៦** នៅវិទ្យាស្ថានជាតិអប់រំ ។ នាងខ្ញុំកំពុងធ្វើការស្រាវជ្រាវដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាក្រោមប្រធានបទ "**ស្ថានភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំនៅវិទ្យាស្ថានគរុកោសល្យ**"។ សូមគរុនិស្សិតទាំងអស់បំពេញព័ត៌មានដែលពិត និងដោយឆន្ទៈ ពីព្រោះ រាល់ព័ត៌មានទាំងអស់ដែលប្រមូលបានពីគរុនិស្សិតគឺជាព័ត៌មានសម្ងាត់ សម្រាប់យកមកវិភាគរកលទ្ធផលនៃប្រធានបទខាងលើតែមួយគត់ មិនមានបំណងអ្វីផ្សេងទៀតឡើយ។

## ផ្នែកទី១ ៖ ពត៌មានទូទៅរបស់អ្នកចូលរួម(គរុនិស្សិត)

1. ភេទ ក.☐ស្រី ខ. ☐ប្រុស
2. កម្រិតសញ្ញាបត្របច្ចុប្បន្ន: ក. ☐មធ្យមសិក្សាទុតិយភូមិ ខ. ☐បរិញ្ញាបត្ររង គ. ☐បរិញ្ញាបត្រ
3. បណ្តុះបណ្តាលគ្រូកម្រិត៖...............................មុខវិជ្ជា..............................

## ផ្នែកទី២៖ ដំណើរការអនុវត្តកម្មវិធីបណ្តុះបណ្តាល

សូមគូសរង្វង់ជុំវិញពិន្ទុតែមួយគត់(រាល់ព័ត៌មានទាំងឡាយណាដែលបានជ្រើសរើសលើសពីមួយ គឺទុកអាជាអាសាបង់)

| សូចនាករ | មិនយល់ស្រប | មិនយល់ស្រប | មធ្យម | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|
| **I.ការងារគ្រប់គ្រងនិងដឹកនាំ** | | | | | |
| ១.នាយកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងសមស្របភារកិច្ច | ១ | ២ | ៣ | ៤ | ៥ |

| | | | | | |
|---|---|---|---|---|---|
| ដែលខ្លួនទទួលខុសត្រូវ។ | | | | | |
| ២.នាយករង/នាយិការងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងសមស្របភារកិច្ចដែលខ្លួនទទួលខុសត្រូវ។ | ១ | ២ | ៣ | ៤ | ៥ |
| ៣.វិទ្យាស្ថានមានរចនាសម្ព័ន្ធច្បាស់លាស់បង្ហាញពីសិទ្ធិអំណាច និងទំនាក់ទំនងការងារក្នុងវិទ្យាស្ថាន។ | ១ | ២ | ៣ | ៤ | ៥ |
| ៤.ការអភិវឌ្ឍរបស់វិទ្យាស្ថានមានសង្គតិភាព (ភាពស៊ីចង្វាក់គ្នា) ជាមួយនឹងចក្ខុវិស័យ បេសកកម្ម និងគោលដៅដែលបានកំណត់។ | ១ | ២ | ៣ | ៤ | ៥ |
| ៥.បុគ្គលិករដ្ឋបាល ការិយាល័យសិក្សា ការិយាល័យធានាគុណភាពផ្ទៃក្នុង និងដេប៉ាតឺម៉ង់មានគុណវុឌ្ឍិ សមត្ថភាព និងបទពិសោធស្រុបនឹងភារកិច្ចដែលខ្លួនទទួលខុសត្រូវ។ | ១ | ២ | ៣ | ៤ | ៥ |
| **II. គុណភាពគ្រូឧទ្ទេស** | | | | | |
| ៦.គ្រូឧទ្ទេសមានគុណវុឌ្ឍិ និងបទពិសោធន៍សមស្របទៅនឹងមុខជំនាញឯកទេស និងកម្រិតនៃភារកិច្ចការងាររបស់ពួកគាត់ ។ | ១ | ២ | ៣ | ៤ | ៥ |
| ៧.គ្រូឧទ្ទេសមានចំនួនច្រើនគ្រប់គ្រាន់ ក្នុងការធានាប្រសិទ្ធភាពនៃការបង្រៀន ណែនាំគរុនិស្សិត និងការអនុវត្តនៅក្នុងវិទ្យាស្ថាន។ | ១ | ២ | ៣ | ៤ | ៥ |
| ៨.គ្រូឧទ្ទេសមានសមត្ថភាពឆ្លើយតបទៅនឹងតម្រូវការរបស់គរុនិស្សិតទាក់ទងនឹងការបង្រៀននិងរៀន | ១ | ២ | ៣ | ៤ | ៥ |
| **III.កម្មវិធីសិក្សា** | | | | | |
| ៩.វិទ្យាស្ថានមានគណៈកម្មាធិការអភិវឌ្ឍកម្មវិធីសិក្សាដែលប្រព្រឹត្តទៅប្រកបដោយ ប្រសិទ្ធភាព។ | ១ | ២ | ៣ | ៤ | ៥ |
| ១០.កម្មវិធីសិក្សាមានលក្ខណៈស្របតាមគោលនយោបាយជាតិ ក្របខណ្ឌគុណវុឌ្ឍិជាតិ និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សង្គម និងឆ្លើយតបនឹងបំណិននៃការរៀនសតវត្សរ៍ទី២១។ | ១ | ២ | ៣ | ៤ | ៥ |
| ១១. មុខវិជ្ជានីមួយៗក្នុងកម្មវិធីសិក្សាមានការសសេរកម្មវិធីសិក្សាលម្អិតច្បាស់លាស់ ដោយផ្អែកលើសៀវភៅគោល សៀវភៅយោង គេហទំព័រ ព្រមទាំងឯកសារសិក្សានិងបង្រៀនផ្សេងៗទៀត។ | ១ | ២ | ៣ | ៤ | ៥ |
| ១២. គ្រប់កម្មវិធីអប់រំមានការពិពណ៌នាច្បាស់លាស់អំពីលទ្ធផល | ១ | ២ | ៣ | ៤ | ៥ |

| | | | | | |
|---|---|---|---|---|---|
| សិក្សារបស់ គរុនិស្សិត ដោយបញ្ជាក់ពី ចំណេះដឹង ជំនាញ និងឥរិយាបថដែលគរុនិស្សិតនឹងទទួលបាន។ | | | | | |
| ១៣. វិទ្យាស្ថានប្រើវិធីសាស្ត្រ និងមធ្យោបាយច្រើនយ៉ាងក្នុងការវាយតម្លៃលើការសិក្សា របស់គរុនិស្សិត ដោយអនុលោមតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់។ | ១ | ២ | ៣ | ៤ | ៥ |
| ១៤. វិទ្យាស្ថានគរុកោសល្យពិនិត្យ និងកែលម្អកម្មវិធីអប់រំបានទៀងទាត់ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ។ | ១ | ២ | ៣ | ៤ | ៥ |
| **IV.គុណភាពគរុនិស្សិត** | | | | | |
| ១៥. គោលនយោបាយ ឬគោលការណ៍ស្តីពីការជ្រើសរើសគរុនិស្សិត ចូលរៀន បានកំណត់ ច្បាស់លាស់ និងអនុវត្តបានត្រឹមត្រូវ | ១ | ២ | ៣ | ៤ | ៥ |
| ១៦.គរុនិស្សិតត្រូវបានជ្រើសរើសតាមរយៈការប្រឡងប្រជែង និងការត្រួតពិនិត្យម៉ត់ចត់ដើម្បីជ្រើសរើសយកអ្នកមានសមត្ថភាពពិតប្រាកដឱ្យចូលរៀន។ | ១ | ២ | ៣ | ៤ | ៥ |
| ១៧. និស្សិតចូលរៀនថ្មីនៅគ្រប់កម្រិតសញ្ញាបត្រទទួលបានការណែនាំ ឬការតម្រង់ទិសពេញលេញ។ | ១ | ២ | ៣ | ៤ | ៥ |
| ១៨. វិទ្យាស្ថានបង្កើត និងធានាដំណើរការប្រព័ន្ធប្រឹក្សាយោបល់លើការសិក្សា ហើយវាយតម្លៃលើប្រព័ន្ធនោះបានទៀងទាត់។ | ១ | ២ | ៣ | ៤ | ៥ |
| ១៩.គរុនិស្សិតទទួលបានឱកាសក្នុងការចូលរួមក្នុងសកម្មភាពកម្មសិក្សាគរុកោសល្យ។ | ១ | ២ | ៣ | ៤ | ៥ |
| ២០.គរុនិស្សិតទទួលបានឱកាសក្នុងការចូលរួមជួយបម្រើសហគមន៍ និងសកម្មភាពសង្គមផ្សេងៗ។ | ១ | ២ | ៣ | ៤ | ៥ |
| **V.ការបង្រៀននិងរៀន** | | | | | |
| ២១.ដំណើរការនៃការបង្រៀននិងរៀន និងរង្វាយតម្លៃគរុនិស្សិតត្រូវបានពិនិត្យឡើងវិញ ព្រមទាំងវាយតម្លៃដើម្បីធានាទំនាក់ទំនងនិងការបន្សុីគ្នា។ | ១ | ២ | ៣ | ៤ | ៥ |
| ២២.លទ្ធផលនៃការស្រាវជ្រាវត្រូវបានប្រើដើម្បីលើកកម្ពស់ការបង្រៀននិងរៀន។ | ១ | ២ | ៣ | ៤ | ៥ |

| | | | | | |
|---|---|---|---|---|---|
| ២៣. ការរៀបចំនិងការអភិវឌ្ឍកម្មវិធីសិក្សាត្រូវបានបង្កើតឡើង និងលើកជាប្រធានបទ ក្នុងការវាយតម្លៃនិងការជំរុញឱ្យដល់គោលដៅ។ | ១ | ២ | ៣ | ៤ | ៥ |
| ២៤. ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត គម្រោងមេរៀនតាមមុខវិជ្ជា និងកិច្ចតែងការបង្រៀន។ | ១ | ២ | ៣ | ៤ | ៥ |
| ២៥.សកម្មភាពអប់រំសម្រាប់ការអភិវឌ្ឍការងារប្រកបដោយចីរភាពត្រូវបានលើកកម្ពស់ វិទ្យាស្ថានក្នុងការធានាបរិស្ថាន នៃការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព។ | ១ | ២ | ៣ | ៤ | ៥ |
| **VI. ធនធានសិក្សា** | | | | | |
| ២៦.បណ្ណាល័យមានកន្លែងអានគ្រប់គ្រាន់ និងបរិយាកាសអំណោយផលដល់ការសិក្សានិងស្រាវជ្រាវ។ | ១ | ២ | ៣ | ៤ | ៥ |
| ២៧. បណ្ណាល័យមានសៀវភៅសិក្សា ឯកសារយោង ទស្សនាវដ្តីវិទ្យាសាស្ត្រ និងសម្ភារសិក្សាផ្សេងៗសម្រាប់គាំទ្រដល់កម្មវិធីអប់រំ | ១ | ២ | ៣ | ៤ | ៥ |
| ២៨. បណ្ណាល័យមានបណ្ណារក្សជំនាញ និងបុគ្គលិកបម្រើការគ្រប់គ្រាន់ ថែមទាំងទទួលបានការបណ្តុះបណ្តាលផ្នែកជំនាញគ្រប់គ្រងបណ្ណាល័យ ហើយមានសមត្ថភាពបម្រើតម្រូវការរបស់គរុនិស្សិត និងគ្រូបង្រៀននៅតាមដេប៉ាតឺម៉ង់។ | ១ | ២ | ៣ | ៤ | ៥ |
| ២៩. គរុនិស្សិត និងគ្រូឧទ្ទេសទទួលបានការណែនាំ និងការតម្រង់ទិសអំពីរបៀបប្រើប្រាស់បណ្ណាល័យ និងធនធានសិក្សាផ្សេងៗ។ | ១ | ២ | ៣ | ៤ | ៥ |
| ៣០. គរុនិស្សិតនិងគ្រូឧទ្ទេសទទួលបានឱកាសក្នុងការប្រើប្រាស់ធនធានសិក្សាក្នុងប្រព័ន្ធបណ្ណាល័យទូរនិម្មិត (បណ្ណាល័យ/គេហទំព័រផ្សេងៗតាមអ៊ីនធឺណែត) សម្រាប់បំពេញតម្រូវការសិក្សា និងស្រាវជ្រាវស្របតាមកម្មវិធីអប់រំ។ | ១ | ២ | ៣ | ៤ | ៥ |
| ៣១. មានសម្ភារឧបទ្ទេសគ្រប់គ្រាន់ក្នុងការបង្រៀនគរុនិស្សិត | ១ | ២ | ៣ | ៤ | ៥ |
| ៣២.វិទ្យាស្ថានមានបន្ទប់ពិសោធន៍ទូទៅ និងឯកទេសប្រកបដោយបរិក្ខារពេញលេញ សម្រាប់គាំទ្រដល់ការបង្រៀនការសិក្សានិងការ | ១ | ២ | ៣ | ៤ | ៥ |

| | | | | | |
|---|---|---|---|---|---|
| ស្រាវជ្រាវស្របតាមកម្មវិធីអប់រំ។ | | | | | |
| ៣៣.វិទ្យាស្ថានមានគ្រូឧទ្ទេសដែលមានគុណវុឌ្ឍិសមស្រប និង មានចំនួនគ្រប់គ្រាន់ សម្រាប់បម្រើតម្រូវការនិងដំណើរការក្នុង បន្ទប់ពិសោធន៍ ដើម្បីគាំទ្រដល់ការបង្រៀននិងរៀន។ | ១ | ២ | ៣ | ៤ | ៥ |
| ៣៤.មានធនធានបច្ចេកវិទ្យានិងអ៊ីនធឺណែតគ្រប់គ្រាន់សម្រាប់គាំទ្រការសិក្សាដោយរាប់បញ្ចូលទាំងបន្ទប់កុំព្យូទ័រសម្រាប់បម្រើតម្រូវការទូទៅ និងឯកទេសដើម្បីបំពេញតម្រូវការ តាមកម្មវិធីអប់រំរបស់វិទ្យាស្ថាន។ | ១ | ២ | ៣ | ៤ | ៥ |
| ៣៥.វិទ្យាស្ថានមានបុគ្គលិកដែលបានឆ្លងកាត់ការបណ្តុះបណ្តាល គ្រប់គ្រាន់សម្រាប់គាំទ្រ និងជួយសម្រួលលើផ្នែកបច្ចេកទេសគ្រប់ម៉ោងសិក្សា។ | ១ | ២ | ៣ | ៤ | ៥ |
| **VII .ធនធានរូបវន្ត**(អគារ, ផាសុកភាព និងសុវត្ថិភាពបរិស្ថានសិក្សា) | | | | | |
| ៣៦.វិទ្យាស្ថានមានធនធានរូបវន្តគ្រប់គ្រាន់សម្រាប់បំពេញ បេសកកម្ម កម្មវិធីអប់រំ សកម្មភាពផ្សេងៗរួមទាំងសកម្មភាពសិក្សា កម្មវិធីសិក្សា និងកម្មវិធីសិក្សា បន្ថែមលើការសិក្សា របស់គរុនិស្សិតដែលកំពុងសិក្សា បច្ចុប្បន្ន។ | ១ | ២ | ៣ | ៤ | ៥ |
| ៣៧.វិទ្យាស្ថានមានបរិស្ថានប្រកបដោយផាសុកភាពនិងសុវត្ថិភាព ដែលបំពេញតាម លក្ខខណ្ឌស្តីពីសុវត្ថិភាព។ | ១ | ២ | ៣ | ៤ | ៥ |
| ៣៨.មានអន្តេវាសិកដ្ឋាន និងសម្ភារៈគ្រប់គ្រាន់សម្រាប់គរុនិស្សិត ស្នាក់នៅ | ១ | ២ | ៣ | ៤ | ៥ |
| ៣៩.វិទ្យាស្ថានមានផែនការមេធនធានរូបវន្តរយៈពេលវែង រយៈពេលខ្លីសម្រាប់អភិវឌ្ឍធនធានរូបវន្តរបស់ខ្លួន។ | ១ | ២ | ៣ | ៤ | ៥ |

**ផ្នែកទី៣ ៖មតិយោបល់របស់អ្នកចូលរួម**

១.ក្នុងដំណើរការអនុវត្តកម្មវិធីបណ្តុះបណ្តាលតើប្អូនៗគរុនិស្សិតជួបប្រទះនូវបញ្ហាប្រឈមអ្វីខ្លះ?

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

.......................................................................................................................។

២.តាមមតិយោបល់របស់ប្អូនតើត្រូវធ្វើដូចម្តេចដើម្បីជំរុញការងារបណ្តុះបណ្តាលនេះអោយកាន់តែមានភាពល្អប្រសើរ និងមានការអភិវឌ្ឍសម្រាប់រយៈពេលខាងមុខ?

...................................................................................................................................

...................................................................................................................................

...................................................................................................................................

...................................................................................................................................

..............................................................................................................................។

# កម្រងសំណួរសម្រាប់ប្រធាន/អនុប្រធានដេប៉ាតឺម៉ង់/គ្រូឧទ្ទេស

## សេចក្តីណែនាំ៖

នាងខ្ញុំឈ្មោះ **ឆាយ បូនី** ជាគ្រូឧទ្ទេសនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ បច្ចុប្បន្នកំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ **ជំនាន់ទី៦** នៅវិទ្យាស្ថានជាតិអប់រំ ។ នាងខ្ញុំកំពុងធ្វើការស្រាវជ្រាវដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាក្រោមប្រធានបទ "**ស្ថានភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំនៅវិទ្យាស្ថានគរុកោសល្យ**"។ សូមលោកគ្រូ អ្នកគ្រូទាំងអស់បំពេញព័ត៌មានដែលពិត និងដោយឆន្ទៈពីព្រោះ រាល់ព័ត៌មានទាំងអស់ដែលប្រមូលបានពីលោកគ្រូ អ្នកគ្រូគឺជាព័ត៌មានសម្ងាត់ សម្រាប់យកមកវិភាគរកលទ្ធផលនៃប្រធានបទខាងលើតែមួយគត់ មិនមានបំណងអ្វីផ្សេងទៀតឡើយ។

**ផ្នែកទី១៖ ព័ត៌មានទូទៅរបស់អ្នកចូលរួម(គ្រូឧទ្ទេស)**

១. ភេទ ក.☐ស្រី ខ. ☐ប្រុស

២. កម្រិតសញ្ញាបត្រ:ក.☐បរិញ្ញបត្រ ខ. ☐បរិញ្ញាបត្រជាន់ខ្ពស់ គ. ☐បណ្ឌិត

៣. ឋាន: ក. ☐គ្រូឧទ្ទេស ខ.☐គ្រូឧទ្ទេសរង គ.☐គ្រូឧទ្ទេសជំនួយ

**ផ្នែកទី២ ៖ដំណើរការអនុវត្តកម្មវិធីបណ្តុះបណ្តាល**

សូមគូសរង្វង់ជុំវិញពិន្ទុតែមួយគត់(រាល់ព័ត៌មានទាំងឡាយណាដែលបានជ្រើសរើសលើសពីមួយ គឺទុកអាជាអាសាបង់)

| សូចនាករ | មិនយល់ស្រប | មិនយល់ស្រប | ធម្មតា | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|
| **I. ការងារគ្រប់គ្រង និងដឹកនាំ** | | | | | |
| ១.នាយកមានលក្ខណ:សម្បត្តិគ្រប់គ្រាន់ និងសមស្របភារកិច្ច | ១ | ២ | ៣ | ៤ | ៥ |

| | | | | | |
|---|---|---|---|---|---|
| ដែលខ្លួនទទួលខុសត្រូវ។ | | | | | |
| ២.នាយករង/នាយិការងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់និងសមស្របភារកិច្ចដែលខ្លួនទទួលខុសត្រូវ។ | ១ | ២ | ៣ | ៤ | ៥ |
| ៣.វិទ្យាស្ថានមានរចនាសម្ព័ន្ធច្បាស់លាស់បង្ហាញពីសិទ្ធិអំណាច និងទំនាក់ទំនងការងារក្នុងវិទ្យាស្ថាន។ | ១ | ២ | ៣ | ៤ | ៥ |
| ៤. ការអភិវឌ្ឍរបស់វិទ្យាស្ថានមានសង្គតិភាព (ភាពស៊ីចង្វាក់គ្នា) ជាមួយនឹងចក្ខុវិស័យ បេសកកម្ម និងគោលដៅដែលបានកំណត់។ | ១ | ២ | ៣ | ៤ | ៥ |
| ៥.បុគ្គលិករដ្ឋបាល,ការិយាល័យសិក្សា ការិយាល័យធានាគុណភាពផ្ទៃក្នុង និងដេប៉ាតឺម៉ង់មានគុណវុឌ្ឍិ សមត្ថភាព និងបទពិសោធស្របនឹងភារកិច្ចដែលខ្លួនទទួលខុសត្រូវ។ | ១ | ២ | ៣ | ៤ | ៥ |
| **II. គុណភាពបុគ្គលិកអប់រំ** | | | | | |
| ៦.គ្រូឧទ្ទេសមានគុណវុឌ្ឍិ និងបទពិសោធន៍សមស្របទៅនឹងមុខជំនាញឯកទេស និងកម្រិតនៃភារកិច្ចការងាររបស់ពួកគាត់ ដោយឆ្លើយតបនឹងគុណវុឌ្ឍិអប្បរមាដែលតម្រូវដោយវិទ្យាស្ថានគរុកោសល្យ។ | ១ | ២ | ៣ | ៤ | ៥ |
| ៧.គ្រូឧទ្ទេសមានចំនួនច្រើនគ្រប់គ្រាន់ក្នុងការធានាប្រសិទ្ធភាពនៃការបង្រៀន ណែនាំគរុនិស្សិត និងការអនុវត្តនៅក្នុងវិទ្យាស្ថាន។ | ១ | ២ | ៣ | ៤ | ៥ |
| ៨.គ្រូឧទ្ទេសមានសមត្ថភាពឆ្លើយតបទៅនឹងតម្រូវការរបស់គរុនិស្សិតទាក់ទងនឹងការបង្រៀននិងរៀន។ | ១ | ២ | ៣ | ៤ | ៥ |
| **III. កម្មវិធីសិក្សា** | | | | | |
| ៩.វិទ្យាស្ថានមានគណៈកម្មាធិការអភិវឌ្ឍកម្មវិធីសិក្សាដែលប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព។ | ១ | ២ | ៣ | ៤ | ៥ |
| ១០.កម្មវិធីសិក្សាមានលក្ខណៈស្របតាមគោលនយោបាយជាតិ ក្របខណ្ឌគុណវុឌ្ឍិជាតិ ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សង្គម និងឆ្លើយតបនឹងបំណិននៃការរៀនសតវត្សរ៍ទី២១។ | ១ | ២ | ៣ | ៤ | ៥ |
| ១១.មុខវិជ្ជានីមួយៗក្នុងកម្មវិធីសិក្សាមានការសសេរកម្មវិធីសិក្សា | ១ | ២ | ៣ | ៤ | ៥ |

| | | | | | |
|---|---|---|---|---|---|
| លម្អិតច្បាស់លាស់ ដោយផ្អែកលើសៀវភៅគោល សៀវភៅយោង គេហទំព័រ ព្រមទាំងឯកសារសិក្សានិងបង្រៀនផ្សេងៗទៀត។ | | | | | |
| ១២.គ្រប់កម្មវិធីអប់រំមានការពិពណ៌នាច្បាស់លាស់អំពីលទ្ធផលសិក្សារបស់ គរុនិស្សិត ដោយបញ្ជាក់ពី ចំណេះដឹង ជំនាញ និងឥរិយាបថដែលគរុនិស្សិតនឹងទទួលបាន។ | ១ | ២ | ៣ | ៤ | ៥ |
| ១៣.វិទ្យាស្ថានប្រើវិធីសាស្ត្រ និងមធ្យោបាយច្រើនយ៉ាងក្នុងការវាយតម្លៃលើការសិក្សា របស់គរុនិស្សិត ដោយអនុលោមតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់។ | ១ | ២ | ៣ | ៤ | ៥ |
| ១៤.វិទ្យាស្ថានគរុកោសល្យពិនិត្យ និងកែលម្អកម្មវិធីអប់រំបានទៀងទាត់ដោយមានការ ចូលរួមពីភាគីពាក់ព័ន្ធ។ | ១ | ២ | ៣ | ៤ | ៥ |
| **IV. គុណភាពគរុនិស្សិត** | | | | | |
| ១៥.គោលនយោបាយឬគោលការណ៍ស្តីពីការជ្រើសរើសគរុនិស្សិតចូលរៀន បានកំណត់ ច្បាស់លាស់ និងអនុវត្តបានត្រឹមត្រូវ | ១ | ២ | ៣ | ៤ | ៥ |
| ១៦.គរុនិស្សិតត្រូវបានជ្រើសរើសតាមរយៈការប្រឡងប្រជែង និងការត្រួតពិនិត្យម៉ត់ចត់ ដើម្បីជ្រើសរើសយកអ្នកមានសមត្ថភាពពិតប្រាកដអោយចូលរៀន។ | ១ | ២ | ៣ | ៤ | ៥ |
| ១៧.និស្សិតចូលរៀនថ្មីនៅគ្រប់កម្រិតសញ្ញាបត្រទទួលបានការណែនាំ ឬការតម្រង់ទិសពេញលេញ។ | ១ | ២ | ៣ | ៤ | ៥ |
| ១៨.វិទ្យាស្ថានបង្កើត និងធានាដំណើរការប្រព័ន្ធប្រឹក្សាយោបល់លើការសិក្សា ហើយវាយតម្លៃលើប្រព័ន្ធនោះបានទៀងទាត់។ | ១ | ២ | ៣ | ៤ | ៥ |
| ១៩.គរុនិស្សិតទទួលបានឱកាសក្នុងការចូលរួមក្នុងសកម្មភាពកម្មសិក្សាគរុកោសល្យ។ | ១ | ២ | ៣ | ៤ | ៥ |
| ២០.គរុនិស្សិតទទួលបានឱកាសក្នុងការចូលរួមជួយបម្រើសហគមន៍ និងសកម្មភាព សង្គមផ្សេងៗ។ | ១ | ២ | ៣ | ៤ | ៥ |
| **V.ការបង្រៀននិងរៀន** | | | | | |
| ២១.ដំណើរការនៃការបង្រៀននិងរៀន រង្វាយតម្លៃគរុនិស្សិតត្រូវបានពិនិត្យឡើងវិញនិងវាយតម្លៃដើម្បីធានាទំនាក់ទំនងនិងការ | ១ | ២ | ៣ | ៤ | ៥ |

| | | | | | |
|---|---|---|---|---|---|
| បន្សុីគ្នា | | | | | |
| ២២.លទ្ធផលនៃការស្រាវជ្រាវត្រូវបានប្រើដើម្បីលើកកម្ពស់ការបង្រៀននិងរៀន។ | ១ | ២ | ៣ | ៤ | ៥ |
| ២៣. ការរៀបចំនិងការអភិវឌ្ឍកម្មវិធីសិក្សាត្រូវបានបង្កើតឡើង និងលើកជាប្រធានបទ ក្នុងការវាយតម្លៃ និងការជំរុញឱ្យដល់គោលដៅ។ | ១ | ២ | ៣ | ៤ | ៥ |
| ២៤.ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត គម្រោងមេរៀនតាមមុខវិជ្ជា និងកិច្ចតែងការបង្រៀន។ | ១ | ២ | ៣ | ៤ | ៥ |
| ២៥.សកម្មភាពអប់រំសម្រាប់ការអភិវឌ្ឍការងារប្រកបដោយចីរភាពត្រូវបានលើកកម្ពស់ វិទ្យាស្ថានក្នុងការធានាបរិស្ថាន នៃការបង្រៀននិងរៀនប្រកបដោយប្រសិទ្ធភាព។ | ១ | ២ | ៣ | ៤ | ៥ |
| **VI.ធនធានសិក្សា** | | | | | |
| ២៦.បណ្ណាល័យមានកន្លែងអានគ្រប់គ្រាន់ និងបរិយាកាសអំណោយផលដល់ការសិក្សា និងស្រាវជ្រាវ។ | ១ | ២ | ៣ | ៤ | ៥ |
| ២៧.បណ្ណាល័យមានសៀវភៅសិក្សា ឯកសារយោង ទស្សនាវដ្តីវិទ្យាសាស្ត្រ និងសម្ភារសិក្សាផ្សេងៗសម្រាប់គាំទ្រដល់កម្មវិធីអប់រំ | ១ | ២ | ៣ | ៤ | ៥ |
| ២៨.បណ្ណាល័យមានបណ្ណារក្សជំនាញ បុគ្គលិកបម្រើការគ្រប់គ្រាន់ និងទទួលបានការបណ្តុះបណ្តាលផ្នែកជំនាញគ្រប់គ្រងបណ្ណាល័យ ហើយមានសមត្ថភាពបម្រើតម្រូវការរបស់គរុនិស្សិត និងគ្រូបង្រៀននៅតាមដេប៉ាតឺម៉ង់។ | ១ | ២ | ៣ | ៤ | ៥ |
| ២៩.គរុនិស្សិតនិងគ្រូឧទ្ទេសទទួលបានការណែនាំ ការតម្រង់ទិសអំពីរបៀបប្រើប្រាស់បណ្ណាល័យ និងធនធានសិក្សាផ្សេងៗ។ | ១ | ២ | ៣ | ៤ | ៥ |
| ៣០.គរុនិស្សិត និងគ្រូឧទ្ទេសទទួលបានឱកាសក្នុងការប្រើប្រាស់ធនធានសិក្សាក្នុងប្រព័ន្ធបណ្ណាល័យទូរនិម្មិត (បណ្ណាល័យ/គេហទំព័រផ្សេងៗតាមអ៊ីនធឺណែត) សម្រាប់បំពេញតម្រូវការសិក្សា និងស្រាវជ្រាវស្របតាមកម្មវិធីអប់រំ។ | ១ | ២ | ៣ | ៤ | ៥ |

| | | | | | |
|---|---|---|---|---|---|
| ៣១. មានសម្ភារឧបទ្ទេសគ្រប់គ្រាន់ក្នុងការបង្រៀនគរុនិស្សិត | ១ | ២ | ៣ | ៤ | ៥ |
| ៣២. វិទ្យាស្ថានមានបន្ទប់ពិសោធន៍ទូទៅ និងឯកទេស ប្រកបដោយបរិក្ខារពេញលេញសម្រាប់គាំទ្រដល់ការបង្រៀនការសិក្សានិងការស្រាវជ្រាវស្របតាមកម្មវិធីអប់រំ។ | ១ | ២ | ៣ | ៤ | ៥ |
| ៣៣.វិទ្យាស្ថានមានគ្រូឧទ្ទេសដែលមានគុណវុឌ្ឍិសមស្រប និងមានចំនួនគ្រប់គ្រាន់សម្រាប់បម្រើតម្រូវការ និងដំណើរការរបស់បន្ទប់ពិសោធន៍ ដើម្បីគាំទ្រដល់ការបង្រៀននិងរៀន។ | ១ | ២ | ៣ | ៤ | ៥ |
| ៣៤.មានធនធានបច្ចេកវិទ្យានិងអ៊ីនធឺណិតគ្រប់គ្រាន់សម្រាប់គាំទ្រការសិក្សាដោយរាប់បញ្ចូលទាំងបន្ទប់កុំព្យូទ័រសម្រាប់បម្រើតម្រូវការទូទៅ និងឯកទេសដើម្បីបំពេញតម្រូវការ តាមកម្មវិធីអប់រំរបស់វិទ្យាស្ថាន។ | ១ | ២ | ៣ | ៤ | ៥ |
| ៣៥.វិទ្យាស្ថានមានបុគ្គលិកដែលបានឆ្លងកាត់ការបណ្តុះបណ្តាលគ្រប់គ្រាន់សម្រាប់គាំទ្រនិងជួយសម្រួលលើផ្នែកបច្ចេកទេសគ្រប់ម៉ោសិក្សា។ | ១ | ២ | ៣ | ៤ | ៥ |
| **VII ធនធានរូបវន្ត(អគារ ផាសុកភាព និងសុវត្ថិភាពបរិស្ថានសិក្សា)** | | | | | |
| ៣៦. វិទ្យាស្ថានមានធនធានរូបវន្តគ្រប់គ្រាន់សម្រាប់បំពេញបេសកកម្ម កម្មវិធីអប់រំ សកម្មភាពផ្សេងៗរួមទាំងសកម្មភាពសិក្សាកម្មវិធីសិក្សា និងកម្មវិធីសិក្សាបន្ថែមលើការសិក្សារបស់គរុនិស្សិតដែលកំពុងសិក្សាបច្ចុប្បន្ន។ | ១ | ២ | ៣ | ៤ | ៥ |
| ៣៧. វិទ្យាស្ថានមានបរិស្ថានប្រកបដោយផាសុកភាព និងសុវត្ថិភាពដែលបំពេញតាមលក្ខខណ្ឌស្តីពីសុវត្ថិភាព។ | ១ | ២ | ៣ | ៤ | ៥ |
| ៣៨.មានអន្តេវាសិកដ្ឋាន និងសម្ភារៈគ្រប់គ្រាន់សម្រាប់គរុនិស្សិតស្នាក់នៅ។ | ១ | ២ | ៣ | ៤ | ៥ |
| ៣៩.វិទ្យាស្ថានមានផែនការមេធនធានរូបវន្តរយៈពេលវែងរយៈពេលខ្លីសម្រាប់អភិវឌ្ឍ ធនធានរូបវន្តរបស់ខ្លួន។ | ១ | ២ | ៣ | ៤ | ៥ |

**ផ្នែកទី៣ ៖មតិយោបល់របស់អ្នកចូលរួម**

១.ក្នុងដំណើរការអនុវត្តកម្មវិធីបណ្តុះបណ្តាល តើលោកគ្រូ អ្នកគ្រូជួបប្រទះនូវបញ្ហាប្រឈមអ្វីខ្លះ?

......................................................................................................................

......................................................................................................................

......................................................................................................................

......................................................................................................................

......................................................................................................................។

២.តាមមតិយោបល់របស់លោកគ្រូ អ្នកគ្រូតើត្រូវធ្វើដូចម្តេចដើម្បីជំរុញការងារបណ្តុះបណ្តាល នេះអោយកាន់តែមានភាពល្អប្រសើរ និងមានការអភិវឌ្ឍ សម្រាប់រយ:ពេលខាងមុខ?

......................................................................................................................

......................................................................................................................

......................................................................................................................

......................................................................................................................

.................................................................................................................។

## ឧបករណ៍សម្រាប់សម្ភាសន៍

## គណៈគ្រប់គ្រង,ប្រធាន/អនុប្រធានការិយាល័យ

១. តើលោក លោកស្រីយល់យ៉ាងណាចំពោះការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលនេះ?

២.ក្នុងដំណើរការអនុវត្តកម្មវិធីបណ្ដុះបណ្ដាល តើលោក លោកស្រីជួបប្រទះនូវបញ្ហាប្រឈមអ្វីខ្លះ?

៣. តើលោក លោកស្រីគិតថាថវិកាគាំទ្រវិទ្យាស្ថានកន្លងមកគ្រប់គ្រាន់ដែរឬទេ?បានមកពីប្រភពណាខ្លះ?មានបញ្ហាពាក់ព័ន្ធនឹងរឿងថវិកានេះដែរឬទេ?

៤.តើវិទ្យាស្ថានមានផែនការអ្វីខ្លះដើម្បីជំរុញការងារបណ្ដុះបណ្ដាលឲ្យមានភាពរលូននិងមានការអភិវឌ្ឍសម្រាប់រយៈពេលខាងមុខ?

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខ [illegible] អយក.[illegible]

*ថ្ងៃព្រហស្បតិ៍ ៦កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២*
*រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៩*

**ជម្រាបមក**
**លោកនាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ**
**លោកនាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម**
**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត**

**កម្មវត្ថុ ៖** ការចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦។

**យោង ៖** កម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ឆ្នាំសិក្សា២០១៨-២០១៩។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកនាយក និងលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាជ្រាបថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ចំនួន៥១នាក់ ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម និងតាមរាជធានី-ខេត្ត ចាប់ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩។

អាស្រ័យហេតុនេះ សូមលោកនាយក និងលោកប្រធានជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមលោកនាយក និងលោកប្រធានទទួលនូវការរាប់អានពីខ្ញុំ ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

**ចម្លងជូន៖**
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- សាលារាជធានី-ខេត្តពាក់ព័ន្ធ
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក
  "ដើម្បីជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
**លេខ:** ១១៩ **ទជអ.ភក**

## លិខិតឧទ្ទេសនាម

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩

និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ នៅវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញនិងបាត់ដំបង សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម និងតាមរាជធានី-ខេត្តនានា ចាប់ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩៖

| ល.រ | គោត្តនាម និងនាម | ភេទ | សាលាគរុកោសល្យ និង រាជធានី-ខេត្ត |
|---|---|---|---|
| ១ | កុយ វ៉ាឡង់ទីណា | ប | ខេត្តកំពង់ធំ |
| ២ | គុជ សំអែល | ប | ខេត្តស្វាយរៀង |
| ៣ | ឃិន សម្បត្តិ | ប | ខេត្តតាកែវ |
| ៤ | ឯន ណាវី | ប | រាជធានីភ្នំពេញ |
| ៥ | ង៉ែត វ៉ាវុធ | ប | ខេត្តតាកែវ |
| ៦ | ងួន ផល្លី | ស | ខេត្តបាត់ដំបង |
| ៧ | ឆន ឈាង | ប | សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម |
| ៨ | ឆាយ បូនី | ស | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង |
| ៩ | ជា គត | ប | ខេត្តតាកែវ |
| ១០ | ជា វណ្ណារ៉ា | ប | ខេត្តកំពង់ឆ្នាំង |
| ១១ | ញ៉ែត សំអុល | ប | ខេត្តតាកែវ |
| ១២ | ទឹម ពិន្ទុ | ប | រាជធានីភ្នំពេញ ខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង ពោធិ៍សាត់ កំពង់ស្ពឺ កំពង់ធំ ស្ទឹងត្រែង ឧត្តរមានជ័យ និងខេត្តមណ្ឌលគិរី |
| ១៣ | ទុយ សុវណ្ណារិទ្ធ | ប | រាជធានីភ្នំពេញ ខេត្តកំពង់ចាម បាត់ដំបង និងខេត្តសៀមរាប |
| ១៤ | ធាម ហេង | ប | ខេត្តក្រចេះ |
| ១៥ | ប៉ុម សូគ៉ា | ប | ខេត្តកណ្ដាល |
| ១៦ | ផុន វណ្ណៈ | ប | ខេត្តកណ្ដាល |
| ១៧ | ផូ សុវណ្ណ | ប | រាជធានីភ្នំពេញ |

| | | | |
|---|---|---|---|
| ១៨ | ពុត ពិសី | ប | ខេត្តកំពត |
| ១៩ | ពេជ្រ វៀរ | ស | ខេត្តត្បូងឃ្មុំ |
| ២០ | ភោគ តុលា | ប | ខេត្តស្វាយរៀង |
| ២១ | លី កុសល | ប | ខេត្តកំពង់ចាម |
| ២២ | លឹម សេងហួត | ប | ខេត្តបាត់ដំបង |
| ២៣ | លុន ហ៊ាប | ប | ខេត្តកំពង់ចាម |
| ២៤ | លុយ គឹមសាន | ប | ខេត្តកណ្ដាល |
| ២៥ | វ៉ា សុភក្តិ | ប | ខេត្តព្រៃវែង |
| ២៦ | សន តារាស្មី | ប | ខេត្តកណ្ដាល |
| ២៧ | ស៊ើយ វង្សស៊ី | ប | ខេត្តស្ទឹងត្រែង |
| ២៨ | សាម សុនិត | ប | ខេត្តកំពង់ចាម |
| ២៩ | សុទ្ធ ស្រីនាង | ស | ខេត្តកំពង់ស្ពឺ |
| ៣០ | សៀង គឹមឈៀន | ប | ខេត្តកណ្ដាល |
| ៣១ | ស្រី មៅ | ប | រាជធានីភ្នំពេញ |
| ៣២ | ហ៊ែល ម៉ូណា | ប | រាជធានីភ្នំពេញ |
| ៣៣ | ហៃយ ចម្លង | ស | រាជធានីភ្នំពេញ |
| ៣៤ | ឡាយ វិរៈ | ប | ខេត្តឧត្តរមានជ័យ |
| ៣៥ | ឡុង ចំណាន | ប | ខេត្តកំពង់ចាម |
| ៣៦ | អ៊ិន ចាន់ថា | ប | ខេត្តស្វាយរៀង |
| ៣៧ | អ៊ីវ សុធី | ប | រាជធានីភ្នំពេញ |
| ៣៨ | អ៊ុំម សិរីវឌ្ឍ | ប | ខេត្តតាកែវ |
| ៣៩ | អ៊ុក រិទ្ធី | ប | ខេត្តសៀមរាប |
| ៤០ | អុន សេងទ្រី | ប | ខេត្តកំពង់ធំ |
| ៤១ | អៀង គឹមឈាន | ប | ខេត្តកំពង់ចាម |

ថ្ងៃសុក្រ ១៤កើត ខែពិសាខ ឆ្នាំកុរ ឯកស័កព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៩

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**កន្លែងទទួល៖**

-សាលារាជធានី-ខេត្តពាក់ព័ន្ធ

-អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក

-មន្ទីរ អ.យ.ក រាជធានី-ខេត្តពាក់ព័ន្ធ

"ដើម្បីសហការ"

-សាមីជន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ

-ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ: ៩៦២៤ អយក.ប្រក**
**(ការសម្ងាត់)**

**លិខិតឧទ្ទេសនាម**

**យោង ៖** -បទប្បញ្ញត្តិស្ដីពីការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
-ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** | ខុទ្ទកាល័យ អយក | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** | ខុទ្ទកាល័យ អយក | អនុប្រធាន |
| ៣-ឯកឧត្តម **យក់ ឌីយ** | ខុទ្ទកាល័យ អយក | សមាជិក |
| ៤-ឯកឧត្តម **ណាង សេងហាក់** | ខុទ្ទកាល័យ អយក | សមាជិក |
| ៥-ឯកឧត្តម **ម៉ក់ ខយ** | អគ្គនាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត **សៀង សុខណ្ណា** | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកដឹកនាំវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិត នៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។ ❦

ថ្ងៃ សុក្រ ១១កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៥៦២៩ អយក.ក្រស

(ការសម្ងាត់)

**លិខិតឧទ្ទេសនាម**

**យោង ៖** -បទប្បញ្ញត្តិស្ដីពីការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
-ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្ដម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ វីក | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្ដម ឡៅ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យួន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក នី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារុំម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត នី ឆាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត សិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈុក ច័ន្ទតាយា | នាយកដ្ឋានបណ្ដុះបណ្ដាលនិងក្រឹត្យការ | សមាជិក |
| ១៣-លោកបណ្ឌិត នី វដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្ដម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្ដមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៩៦៣១ **អយក.** ខស
(**ការសម្ងាត់**)

## លិខិតឧទ្ទេសនាម

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការកណ្តាល** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-លោកស្រី ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-លោក ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-លោក ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤-លោក លឹម ភ័ន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោក សៀង ភាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវមកបំពេញភារកិច្ចនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩ និងថ្ងៃបន្តបន្ទាប់ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១១កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh